សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# សន្តតិកម្មតាមមតកសាសន៍នៅកម្ពុជាបច្ចុប្បន្ន

ស្រាវជ្រាវពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៤

រៀបរៀងដោយ

និស្សិតឈ្មោះ៖ **ម៉ៃ ច័ន្ទតារាវុធ**

**ហូ ឡេងហុង**

សាស្ត្រាចារ្យណែនាំ

លោកស្រី **ម៉ួយ ធីតា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី១៩ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១០

ឆ្នាំសរសេរសារណា ២០១៤

# លិខិតថ្លែងអំណរគុណ

ខ្ញុំបាទ **ម៉ៃ ច័ន្ទតារាវុធ** និង ខ្ញុំបាទ **ហូ ឡេងហុង** ជានិស្សិតអាហារូបករណ៍ ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ ឆ្នាំទី ៤ ជំនាន់ទី ១៩ ក្នុងឆ្នាំសិក្សា ២០១៣-២០១៤

*សូមថ្លែងអំណរគុណ និង សម្តែងនូវការគោរពយ៉ាងស្មោះស្ម័គ្រជូនចំពោះ ៖*

លោកឪពុក **ម៉ៃ ច័ន្ទវុឌ្ឍី** និង អ្នកម្តាយ **យស់ ស៊ីយឿន** ដែលជាឪពុកម្តាយរបស់ខ្ញុំបាទ **ម៉ៃ ច័ន្ទតារាវុធ** និង លោកឪពុក **ហូ គឹមសាន់** និង អ្នកម្តាយ **លី មុំលាង** ដែលជាឪពុកម្តាយរបស់ខ្ញុំបាទ **ហូ ឡេងហុង**។ លោកឪពុក និង អ្នកម្តាយទាំងបួន បានផ្តល់កំណើត ចិញ្ចឹម បីបាច់ ថែរក្សា ជួយផ្គត់ផ្គង់ ជ្រោមជ្រែង ឧបត្ថម្ភទាំងផ្នែកស្មារតី សម្ភារៈ និង ថវិកាគ្រប់បែបយ៉ាង ដើម្បីឲ្យខ្ញុំបាទទាំងពីរនាក់មានឱកាសបានសិក្សារៀនសូត្រ ក្រេបជញ្ជក់នូវចំណេះដឹងគ្រប់បែបយ៉ាងតាំងពីបឋមវ័យ រហូតមកដល់ពេលសព្វថ្ងៃនេះ។

ជាបន្ត យើងខ្ញុំសូមថ្លែងអំណរគុណដល់ **ក្រសួង អប់រំយុវជន និងកីឡា** និង **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានផ្តល់អាហារូបករណ៍ ដល់រូបយើងខ្ញុំទាំងពីរនាក់ក្នុងអំឡុងពេល ៤ ឆ្នាំនេះ រហូតដល់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** បានដោយជោគជ័យ។

យើងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ** សាកលវិទ្យាធិការរង ថ្នាក់ដឹកនាំ និង សាស្ត្រាចារ្យនៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ទាំងអស់ ដែលបានផ្តល់ជាដំបូន្មាន ទ្រឹស្តី និង បទពិសោធន៍ល្អៗជាច្រើនក្នុងអំឡុងពេល ៤ ឆ្នាំដែលយើងខ្ញុំទាំងពីរនាក់បានសិក្សានៅក្នុងសាកលវិទ្យាល័យនេះ។ លោកទាំងអស់គឺជាគម្រូដ៏ល្អបំផុតសម្រាប់យើងខ្ញុំទាំងពីរនាក់ទុកដើមទុនក្នុងការបំពេញការងារតាមស្ថាប័ននានា ក្រោយពេលបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ។

ជាពិសេសជាងនេះទៅទៀត យើងខ្ញុំទាំងពីរនាក់សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **លោកស្រីសាស្ត្រាចារ្យ ម៉ួយ ធីតា** ប្រធានការិយាល័យសិក្សានៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលជាសាស្ត្រាចារ្យណែនាំសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំទាំងពីរនាក់។ លោកស្រីសាស្ត្រាចារ្យ បានលះបង់ពេលវេលា លះបង់កម្លាំងកាយ កម្លាំងចិត្ត ផ្តល់នូវដំបូន្មានល្អៗជាច្រើន ព្រមទាំងបានលើកទឹកចិត្ត និង ត្រួសត្រាយផ្លូវដល់យើងខ្ញុំទាំងពីរនាក់ចាប់តាំងពីពេលជ្រើសរើសប្រធានបទសារណា រហូតដល់ពេលដែលសារណារបស់យើងខ្ញុំបានចេញជាផ្លែផ្កានាពេលនេះ។

# អារម្ភកថា

ក្នុងអំឡុងពេល ៤ ឆ្នាំ នៃការសិក្សានៅថ្នាក់បរិញ្ញាបត្រនីតិសាស្រ្ត យើងខ្ញុំទាំងពីរនាក់ទទួលបាននូវទ្រឹស្តី និង បទពិសោធន៍ជាច្រើនពីមុខវិជ្ជាដែលមាននៅក្នុងកម្មវិធីសិក្សា។ ក្នុងចំណោមមុខវិជ្ជាដែលបានសិក្សាកន្លងមក យើងខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើផ្នែករដ្ឋប្បវេណី ទើបយើងខ្ញុំបានសម្រេចចិត្តយកប្រធានបទស្តីពី "**សន្តតិកម្មតាមមតកសាសន៍នៅកម្ពុជាបច្ចុប្បន្ន**" ធ្វើជាកម្មវត្ថុនៃការសិក្សាស្រាវជ្រាវក្នុងសារណាបញ្ចប់ការសិក្សានេះ។

យើងសង្កេតឃើញថាក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានបញ្ញត្តិនូវគោលការណ៍គ្រឹះជាច្រើន ជាពិសេសនៅក្នុងនោះ ក្រមរដ្ឋប្បវេណីនេះបានធ្វើការគោរពនូវគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជនបានយ៉ាងល្អបំផុត ចាប់តាំងពីរូបវន្តបុគ្គលចាប់កំណើតរហូតដល់ទទួលមរណភាពក្តី ក៏ក្រោយពេលទទួលមរណភាព ក្រមរដ្ឋប្បវេណីនៅតែគោរពឆន្ទៈចុងក្រោយរបស់មតកជន តាមរយៈការទទួលស្គាល់នូវរបបមតកសាសន៍។ នៅក្នុងកម្មវិធីសិក្សា យើងមិនបានធ្វើការសិក្សាឲ្យស៊ីជម្រៅនូវខ្លឹមសារនៃមតកសាសន៍ទាំងមូលឡើយ ដោយសារតែរយៈពេលមានកំណត់ ហើយយើងខ្ញុំស្រឡាញ់ និងមានបំណងស្វែងយល់ឲ្យកាន់តែច្បាស់ ទើបយើងខ្ញុំសម្រេចចិត្តជ្រើសរើសប្រធានបទមួយនេះយកមកសិក្សាស្រាវជ្រាវ ដើម្បីជាទុនមួយសម្រាប់ខ្លួនឯងក្នុងការយល់ដឹងបន្ថែមឲ្យបានកាន់តែច្បាស់នៅលើផ្នែកមតកសាសន៍នេះនេះ។ នៅក្នុងការចងក្រងសារណានេះឡើង យើងខ្ញុំបានពឹងផ្អែកទៅក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ជាចម្បង និង សៀវភៅនានាដែលមានពន្យល់ឲ្យកាន់តែច្បាស់ពីខ្លឹមសារនៃសន្តតិកម្មតាមមតកសាសន៍។ លើសពីនេះ នៅក្នុងការស្រាវជ្រាវនេះ យើងជួបប្រទះនឹងបញ្ហាមួយចំនួន ដូចជា ឯកសារយោងមិនសូវជាទូលំទូលាយ និង ខ្លឹមសារនៃច្បាប់ខ្លះមានភាពស្រពេចស្រពិល ។

ជាចុងបញ្ចប់ យើងខ្ញុំសង្ឃឹមថាសារណាបញ្ចប់ការសិក្សានេះនឹងចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ហើយសង្ឃឹមថាខ្លឹមសារនៃច្បាប់នៃផ្នែកសន្តតិកម្មនេះនឹងត្រូវបានពិនិត្យពិចារណា កែសម្រួលនូវចំណុចខ្វះខាតដែលកំពុងមាននេះ នាពេលអនាគតជាមិនខាន។ ទោះបីជាយ៉ាងណាក៏ដោយ សារណាបញ្ចប់ការសិក្សានេះប្រាកដជាមានកំហុសខុសឆ្គងដែលមិនអាចជៀសវាងបាន ហើយចាំបាច់មានការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់សាស្រ្តាចារ្យ សិស្សច្បង និង អ្នកស្រាវជ្រាវទាំងអស់ ដើម្បីឲ្យស្នាដៃស្រាវជ្រាវនេះកាន់តែល្អប្រសើរ។

យើងខ្ញុំរង់ចាំជានិច្ចនូវរាល់ការរិះគន់ក្នុងន័យស្ថាបនាទាំងឡាយដោយក្តីរីករាយ។

# មាតិកា


ទំព័រ

**សេចក្តីផ្តើម** ........................................ ១

**ជំពូកទី ១**

**មតកសាសន៍ និង លក្ខខណ្ឌសុពលភាពនៃមតកសាសន៍**

**ផ្នែកទី ១ ៖ ប្រទានកម្ម អច្ច័យទាន និង សន្តតិកម្ម** ........................................ ៣

កថាខណ្ឌទី ១ ៖ ប្រៀបធៀប ប្រទានកម្ម អច្ច័យទាន និង សន្តតិកម្ម ........................................ ៣

កថាខណ្ឌទី ២ ៖ អច្ច័យទាន ........................................ ៤

**ផ្នែកទី ២ ៖ លក្ខណៈនៃមតកសាសន៍ និង សមត្ថភាពក្នុងការធ្វើមតកសាសន៍** ........................................ ៦

កថាខណ្ឌទី ១ ៖ លក្ខណៈនៃមតកសាសន៍ ........................................ ៦

កថាខណ្ឌទី ២ ៖ សមត្ថភាពក្នុងការធ្វើមតកសាសន៍ ........................................ ៨

**ផ្នែកទី ៣ ៖ វិធីក្នុងការធ្វើមតកសាសន៍** ........................................ ១០

កថាខណ្ឌទី ១ ៖ ទម្រង់នៃមតកសាសន៍ ........................................ ១១

កថាខណ្ឌទី ២ ៖ ចំណុចដែលត្រូវសរសេរក្នុងមតកសាសន៍ ........................................ ២០

កថាខណ្ឌទី ៣ ៖ ការលុបចោលនូវមតកសាសន៍ ........................................ ២៣

**ជំពូកទី ២**

**នីតិវិធីក្នុងការប្រតិបត្តិមតកសាសន៍**

**ផ្នែកទី ១ ៖ នីតិវិធីត្រៀមដើម្បីអនុវត្តមតកសាសន៍** ........................................ ២៧

កថាខណ្ឌទី ១ ៖ ការពិនិត្យបញ្ជាក់ និង ការបើកលិខិតមតកសាសន៍ ........................................ ២៧

កថាខណ្ឌទី ២ ៖ ការយល់ព្រម និង បោះបង់សន្តតិកម្ម ........................................ ២៨

**ផ្នែកទី ២ ៖ នីតិវិធីនៃការគ្រប់គ្រងមត៌ក** ........................................ ៣០

កថាខណ្ឌទី ១ ៖ អ្នកដែលទទួលអាណត្តិពីមតកជន ........................................ ៣០

កថាខណ្ឌទី ២ ៖ ការកំណត់អ្នកប្រតិបត្តិមតកសាសន៍ ........................................ ៣១

កថាខណ្ឌទី ៣ ៖ សិទ្ធិអំណាច ឋានៈ និងតួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍ ........................................ ៣៣

កថាខណ្ឌទី ៤ ៖ សោហ៊ុយនៃការប្រតិបត្តិ និង កម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍ .... ៣៧

កថាខណ្ឌទី ៥ ៖ សិទ្ធិជ្រើសតាំងបន្ត ការលាឈប់ និង ការបញ្ឈប់អ្នកប្រតិបត្តិ ........................................ ៣៨

**ផ្នែកទី ៣ ៖ នីតិវិធីនៃការបែងចែកមត៌ក** ........................................................................ **៤០**

កថាខណ្ឌទី ១ ៖ ពេលដែលធ្វើការបែងចែកមត៌ក ........................................................ **៤០**

កថាខណ្ឌទី ២ ៖ វិធីនៃការបែងចែកមត៌ក ................................................................... **៤១**

កថាខណ្ឌទី ៣ ៖ ជនដែលទទួលស្គាល់ក្រោយការបែងចែកមត៌ក និង ការទាមទារ ...... **៤៥**

**សេចក្តីសន្និដ្ឋាន**........................................................................................................ **៤៧**

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

តាមរយៈការសិក្សាស្រាវជ្រាវ "**សន្តតិកម្ម**" ត្រូវបានគេទទួលស្គាល់តាំងពីយូរលង់ណាស់មកហើយ ចាប់តាំងពីមានរបបទ្រព្យសម្បត្តិឯកជន[1]។ កាលពីសម័យមុន ព្រះមហាក្សត្រ គឺជាម្ចាស់លើដែនដីទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សង្គមខ្មែរនាសម័យនោះ មានបែងចែកជាវណ្ណៈផ្សេងៗ រួមមាន ញាតិវង្សានុវង្ស វណ្ណៈក្សត្រា វណ្ណៈសមាជិកនៃក្រុមសាសនាផ្សេងៗ វណ្ណៈអ្នកដែលមានសេរី និងវណ្ណៈទាសាទាសី។ តាមរយៈការបែងចែកវណ្ណៈទាំងនេះ ស្តែងបញ្ជាក់ថាបុគ្គលម្នាក់ៗ មានសិទ្ធិមិនដូចគ្នានោះទេ ជាពិសេសសិទ្ធិទៅលើទ្រព្យសម្បត្តិឯកជន និងការធ្វើសន្តតិកម្មទៅឲ្យអ្នកជំនាន់ក្រោយរបស់ខ្លួន។ នាសម័យនោះ ប្រជារាស្ត្រមានសិទ្ធិត្រឹមតែសិទ្ធិភោគៈលើដីធ្លីតែប៉ុណ្ណោះ ពោលគឺពុំទាន់មានសិទ្ធិកម្មសិទ្ធិលើដីធ្លីនៅឡើយទេ ប៉ុន្តែប្រជារាស្ត្រអាចធ្វើការលក់ដូរដូល ឬ ធ្វើសន្តតិកម្មនូវសិទ្ធិភោគៈនេះបាន។ បន្ទាប់មកទៀត នាសម័យអាណានិគមនិយមបារាំងសិទ្ធិលើទ្រព្យសម្បត្តិឯកជនមានការប្រែប្រួល ដោយសារតែបារាំងបាននាំយកនូវក្រមរដ្ឋប្បវេណីរបស់ខ្លួន (ក្រមរដ្ឋប្បវេណី ១៩២០) មកប្រទេសកម្ពុជា។ ចាប់តាំងពីពេលនោះ ព្រះមហាក្សត្រលែងមានសិទ្ធិធ្វើជាម្ចាស់លើដីធ្លីនៅក្នុងព្រះរាជាណាចក្រកម្ពុជាទៀតហើយ ចំណែកកម្មសិទ្ធិឯកជន ត្រូវបានកំណត់ឡើងតាមក្រមរដ្ឋប្បវេណី ១៩២០ នេះ។ ក្រោយសម័យអាណានិគមនិយមបារាំងបន្តិចគឺនៅក្នុងសម័យសង្គមរាស្ត្រនិយម បទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណី ១៩២០ ដែលពាក់ព័ន្ធនឹងទ្រព្យសម្បត្តិឯកជននៅតែបានបន្តអនុវត្ត ប៉ុន្តែនាពេលដែលឈានចូលដល់សម័យកម្ពុជាប្រជាធិបតេយ្យអ្វីៗត្រូវបានផ្លាស់ប្តូរទាំងស្រុង។ នាសម័យនោះ ទ្រព្យសម្បត្តិឯកជនទាំងឡាយត្រូវបានហាមឃាត់លើកលែងតែ ចាន ឆ្នាំង សំលៀកបំពាក់មួយសម្រាប់លើខ្លួនជាដើមប៉ុណ្ណោះ ក្រៅពីនោះសុទ្ធសឹងជាទ្រព្យសម្បត្តិរបស់សមូហភាពទាំងអស់។ បន្ទាប់មកទៀតនៅសម័យរដ្ឋកម្ពុជា ច្បាប់ភូមិបាលក៏បានចាប់បដិសន្ធិឡើងដើម្បីកំណត់របបកម្មសិទ្ធិចំណែកកម្មសិទ្ធិឯកជន ដោយឈរលើមូលដ្ឋាននៃក្រមរដ្ឋប្បវេណី ១៩២០។ ក្រោយពីព្រះរាជាណាចក្រកម្ពុជាបានប្រកាសរដ្ឋធម្មនុញ្ញថ្មី ឆ្នាំ ១៩៩៣ របបកម្មសិទ្ធិឯកជនត្រូវបានបញ្ជាក់សារជាថ្មីថា របបកម្មសិទ្ធិឯកជនមានចំពោះតែប្រជាជនតែប៉ុណ្ណោះ។ ក្រោយពីការប្រកាសរដ្ឋធម្មនុញ្ញនេះ គេចាប់ផ្តើមរៀបចំច្បាប់ភូមិបាលឡើងវិញដោយប្រើរយៈពេលច្រើនឆ្នាំទើបអាចដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រីនាឆ្នាំ ១៩៩៨ ហើយមានការពិភាក្សាគ្នាជាច្រើនលើកច្រើនសារ ទើបអាចចេញច្បាប់ភូមិបាល ២០០១។ ប៉ុន្តែពេលវេលាចេះរំកិលទៅមុខរហូតដល់ឆ្នាំ ២០០៧ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានចាប់បដិសន្ធិឡើងក្រោមការឧបត្ថម្ភគាំទ្រពី

[1] សាស្ត្រាចារ្យ ណូម៉ូរ៉ា តូយ៉ូហ៊ីរ៉ូ, សេចក្តីផ្តើមនីតិរដ្ឋប្បវេណី (ភ្នំពេញ ៖ លើកទី ៥ , ២០១១) , ទំព័រទី ១៧០

ប្រទេសជប៉ុនជាមិត្ត ហើយនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ នេះ បានកំណត់យ៉ាងច្បាស់ពីកម្មសិទ្ធិឯកជន និងការធ្វើសន្តតិកម្ម[2]។

របបសន្តតិកម្មនៅក្នុងពិភពលោកចែកចេញជាពីរប្រភេទ គឺសន្តតិកម្មឈរលើគោលការណ៍ជម្រះបញ្ជី និង សន្តតិកម្មឈរលើគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ។ គោលការណ៍ជម្រះបញ្ជី គឺត្រូវជម្រះបញ្ជីទាំងអស់នូវសិទ្ធិលើបំណុល និង កាតព្វកិច្ចរបស់មតកជននៅពេលដែលសន្តតិកម្មកើតមានឡើង ហើយសន្តតិជននឹងស្នងតែទ្រព្យសកម្មតែប៉ុណ្ណោះ ប៉ុន្តែត្រូវឆ្លងកាត់នីតិវិធីស្មុគស្មាញជាច្រើន។ ចំណែកឯគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិវិញ គឺជាគោលការណ៍ដែលសន្តតិជនត្រូវទទួលទាំងស្រុងនូវសិទ្ធិ និង ករណីកិច្ចទាំងអស់របស់មតកជន។ ប្រទេសកម្ពុជាយើងទទួលយកការធ្វើសន្តតិកម្មដោយឈរលើគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ មូលហេតុដោយសារតែ ប្រជាជនធម្មតាភាគច្រើនគ្មានទ្រព្យសម្បត្តិសន្តតិកម្មច្រើនសម្រាប់ធ្វើការជម្រះបញ្ជីនោះទេ ហើយប្រសិនបើប្រជាជនដែលមានទ្រព្យសម្បត្តិច្រើន អាចជ្រើសយកការប្រើមតកសាសន៍ធ្វើជានីតិវិធីទូទាត់ដោយងាយស្រួល ដើម្បីសងបំណុលដោយទ្រព្យសម្បត្តិជាក់លាក់[3]។

ក្រមរដ្ឋប្បវេណី ២០០៧ បានបែងចែក "**សន្តតិកម្ម**" ជាពីរប្រភេទ គឺ សន្តតិកម្មតាមច្បាប់ និង សន្តតិកម្មមានបណ្តាំ។ សន្តតិកម្មដែលធ្វើឡើងដោយផ្អែកតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ហៅថា **សន្តតិកម្មតាមច្បាប់** ចំណែកឯសន្តតិកម្មដែលផ្អែកតាមឆន្ទៈរបស់មតកជន ហៅថា**សន្តតិកម្មតាមមតកសាសន៍**[4]។ ប្រធានបទនេះ យើងខ្ញុំនឹងសិក្សាតែ សន្តតិកម្មមានបណ្តាំ ឬ សន្តតិកម្មតាមមតកសាសន៍តែប៉ុណ្ណោះ។

តើការធ្វើសន្តតិកម្មតាមលិខិតមតកសាសន៍ដែលមានចែងក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ មាននីតិវិធីយ៉ាងដូចម្តេចខ្លះ?

យើងធ្វើការបែងចែងប្រធានបទ "**សន្តតិកម្មតាមមតកសាសន៍នៅកម្ពុជាបច្ចុប្បន្ន**" នេះជា ២ ជំពូក។ យើងនឹងធ្វើការសិក្សាទៅលើ តើអ្វីទៅជាលិខិតមតកសាសន៍ ហើយលិខិតមតកសាសន៍ត្រូវបំពេញល័ក្ខខ័ណ្ឌសុពលភាពអ្វីខ្លះទើបអាចបង្កើតឡើង (**ជំពូកទី ១**) និង សិក្សាទៅលើអានុភាពនៃមតកសាសន៍ និង នីតិវិធីនៃការប្រតិបត្តិមតកសាសន៍នោះ (**ជំពូកទី ២**)។

---

[2] East West Management Institute, Inc. និង គាំទ្រដោយគម្រោងអនុវត្តច្បាប់ភូមិបាលរបស់ធនាគារអភិវឌ្ឍន៍អាស៊ី, កែសម្រួលនៅឆ្នាំ ២០០៥,សៀវភៅសិក្សា និងស្រាវជ្រាវច្បាប់ភូមិបាលកម្ពុជា,ទំព័រទី ២២ ដល់ទំព័រទី ៣១។

[3] សមាជិកក្រុមការងារគ្រូបណ្តុះបណ្តាលនៃសាលាភូមិន្ទចៅក្រម ដោយមានការគាំទ្រពីទីសហប្រតិបត្តិការ JICA, *ក្រមរដ្ឋប្បវេណី ភាគ ៦* (លើកទី ១ ឆ្នាំ២០១២), ទំព័រទី១។

[4] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៩៥។

# ជំពូកទី ១

# មតកសាសន៍ និង ល័ក្ខខ័ណ្ឌសុពលភាពនៃមតកសាសន៍

មតកសាសន៍ គឺជាលិខិតបណ្តាំ ដែលបុគ្គលម្នាក់បានធ្វើឡើងតាមទម្រង់ដែលកំណត់ដោយច្បាប់ ដើម្បីសម្តែងឆន្ទៈចុងក្រោយអំពីការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួន បន្ទាប់ពីខ្លួនទទួលមរណភាព[5]។

តាមរយៈលិខិតបណ្តាំចុងក្រោយនេះ ម្ចាស់បណ្តាំអាចសម្តែងនូវឆន្ទៈរបស់ខ្លួនបានដោយសេរី [6] ក្នុងការចាត់ចែងនូវទ្រព្យសម្បត្តិដែលខ្លួនមានមុនពេលទទួលមរណភាព ទៅឲ្យបុគ្គលណាម្នាក់ ឬ ច្រើននាក់បាន ដើម្បីឲ្យខ្លួនស្លាប់ដោយស្ងប់ចិត្ត ហើយសង្ឃឹមថាសន្តតិជនរបស់ខ្លួនអាចប្រើប្រាស់ ចាត់ចែង អាស្រ័យផលលើទ្រព្យសម្បត្តិដែលទទួលបានពីការធ្វើសន្តតិកម្មនោះបាន។ ម្យ៉ាងវិញទៀត ការធ្វើលិខិតមតកសាសន៍នេះ ពិតជាបានចូលរួមជាចំណែកមួយក្នុងការកាត់បន្ថយជម្លោះរវាងសន្តតិជនក្នុងការបែងចែកទ្រព្យសម្បត្តិរបស់មតកជន ក្រោយពេលដែលមតកជននោះទទួលមរណភាព។

មុននឹងធ្វើការសិក្សាលំអិតអំពីមតកសាសន៍ និង ល័ក្ខខ័ណ្ឌសុពលភាពនៃមតកសាសន៍ ដើម្បីជៀសវាងការយល់ច្រឡំនៅពេលក្រោយ យើងគប្បីធ្វើការវែកញែកអំពីទំនាក់ទំនងនៃពាក្យ "ប្រទានកម្ម" "អច្ច័យទាន" និង "សន្តតិកម្ម" (**កថាខណ្ឌទី ១**) ក្នុង **ផ្នែកទី ១** ជាមុនសិន។

## ផ្នែកទី ១ ៖ ប្រទានកម្ម អច្ច័យទាន និង សន្តតិកម្ម

### កថាខណ្ឌទី ១ ៖ ប្រៀបធៀប ប្រទានកម្ម អច្ច័យទាន និង សន្តតិកម្ម

ប្រទានកម្ម អច្ច័យទាន និង សន្តតិកម្ម ពិតជាមានភាពស្រដៀងគ្នា និង ងាយយល់ច្រឡំណាស់ ប្រសិនបើយើងមិនធ្វើការវែកញែកឲ្យបានច្បាស់លាស់ អំពីអត្ថន័យនៃពាក្យទាំងបីនេះ។ ប៉ុន្តែមុននឹងធ្វើការវែកញែក ប្រៀបធៀបនូវភាពដូចគ្នា និង ភាពខុសគ្នារវាងពាក្យទាំងបីនេះ យើងគប្បីស្វែងយល់អត្ថន័យនៃពាក្យនីមួយៗសិន។

**ប្រទានកម្ម** គឺជាកិច្ចសន្យាមួយ ដែលត្រូវមានអានុភាពដោយភាគីម្ខាងបង្ហាញឆន្ទៈផ្តល់ទៅឲ្យភាគីម្ខាងទៀតនូវទ្រព្យសម្បត្តិដោយមិនគិតថ្លៃ ហើយភាគីម្ខាងទៀតយល់ព្រមទទួល[7]។ ចំណែក **អច្ច័យទាន** សំដៅទៅលើប្រទានកម្ម ដែលម្ចាស់បណ្តាំធ្វើទៅឲ្យមនុស្សម្នាក់ ឬ ច្រើននាក់នូវទ្រព្យ

[5] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, សទ្ធានុក្រមផ្នែករដ្ឋប្បវេណី ទំព័រទី ១៧។

[6] សមាជិកក្រុមការងារគ្រូបណ្តុះបណ្តាលនៃសាលាភូមិន្ទចៅក្រម ដោយមានការគាំទ្រពីទីសហប្រតិបត្តិការ JICA, *ក្រមរដ្ឋប្បវេណី ភាគ ៦* (លើកទី ១ ឆ្នាំ២០១២), ទំព័រទី ៣៦។

[7] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, សទ្ធានុក្រមផ្នែករដ្ឋប្បវេណី ទំព័រទី ១៤។

សម្បត្តិរបស់ខ្លួនតាមរយៈមតកសាសន៍[8]។ ដោយឡែក **សន្តតិកម្ម** គឺជាការផ្ទេរសិទ្ធិ និង ករណីកិច្ចរបស់មតកជនទៅឲ្យសន្តតិជនតាមឆន្ទៈ (មតកសាសន៍) ឬ តាមច្បាប់[9]។

យើងសង្កេតឃើញថា ក្នុងពាក្យ "**អច្ច័យទាន**" មានបង្កប់ទាំងពាក្យ ប្រទានកម្មផង និង មតកសាសន៍ផង ចំណែកឯពាក្យ "**សន្តតិកម្ម**" ក៏មានបង្កប់ពាក្យមតកសាសន៍ដែរ។

"**ប្រទានកម្ម**" គឺជាការធ្វើជាអំណោយនូវទ្រព្យសម្បត្តិដោយឆន្ទៈរបស់ភាគីម្ខាង ហើយភាគីម្ខាងទៀតត្រូវធ្វើការឆ្លើយតបថា យល់ព្រម ឬ មិនយល់ព្រម ចំពោះការធ្វើអំណោយនោះ ហើយអានុភាពនៃការធ្វើប្រទានកម្មកើតមាននៅពេលអ្នកធ្វើអំណោយនៅរស់ លើកលែងប្រទានកម្មដោយមូលហេតុមរណភាពរបស់ទាយក (អ្នកឲ្យ) ដែលមានអានុភាពនៅពេលអ្នកឲ្យនោះទទួលមរណភាព។ ប្រទានកម្មមានបង្កប់ល័ក្ខខ័ណ្ឌមួយគឺ ឆន្ទៈត្រូវគ្នារវាងអ្នកធ្វើអំណោយ និង អ្នកទទួលអំណោយ។

ចំណែកឯ "**អច្ច័យទាន**" គឺជាការធ្វើអំណោយនូវទ្រព្យសម្បត្តិរបស់មតកជនទៅឲ្យបុគ្គលណាម្នាក់ ហៅថា អច្ច័យលាភី (បុគ្គលដែលទទួលអច្ច័យទាន) ដែលត្រូវសរសេរសម្តែងនៅក្នុងលិខិតមតកសាសន៍។ អច្ច័យទាន ប្រៀបបីដូចជាប្រទានកម្មដោយមូលហេតុមរណភាពរបស់ទាយក ពោលគឺអានុភាពរបស់វាកើតឡើងនៅពេលដែលមតកជនទទួលមរណភាព។ ដោយឡែកនៅក្នុង **លិខិតមតកសាសន៍** វិញ ម្ចាស់បណ្តាំអាចសរសេរអំពីការធ្វើអច្ច័យទានទៅតតិយជន ឬ សន្តតិជន និង សរសេរពីការធ្វើសន្តតិកម្មទៅសន្តតិជនបាន។

ដូច្នេះ យើងអាចវែកញែកបានថា ជាទូទៅប្រទានកម្ម មានអានុភាពតាំងពីម្ចាស់ទ្រព្យសម្បត្តិបានធ្វើប្រទានកម្មពេលនៅរស់ម្ល៉េះ ចំណែក អច្ច័យទាន មានអានុភាពចាប់ពីពេលដែលម្ចាស់ទ្រព្យសម្បត្តិទទួលមរណភាព។ ដោយឡែក មតកសាសន៍វិញ គ្រាន់តែជាលិខិតបណ្តាំ ដែលមតកជនសរសេរជាភស្តុតាងក្នុងការចាត់ចែង អច្ច័យទាន និង សន្តតិកម្ម តែប៉ុណ្ណោះ។

ដោយសារតែ អច្ច័យទាន ជាផ្នែកមួយនៃមតកសាសន៍ យើងនឹងធ្វើការសិក្សាពីអច្ច័យទាន (**កថាខណ្ឌទី ២**) ជាបន្តបន្ទាប់។

**កថាខណ្ឌទី ២ ៖ អច្ច័យទាន**

តាមរយៈការឲ្យនិយមន័យខាងលើ **អច្ច័យទាន** សំដៅទៅលើប្រទានកម្ម ដែលម្ចាស់បណ្តាំធ្វើទៅឲ្យមនុស្សម្នាក់ ឬ ច្រើននាក់នូវទ្រព្យសម្បត្តិរបស់ខ្លួនតាមរយៈមតកសាសន៍។

[8] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, សទ្ទានុក្រមផ្នែករដ្ឋប្បវេណី ទំព័រទី ២៦។

[9] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, សទ្ទានុក្រមផ្នែករដ្ឋប្បវេណី ទំព័រទី ២១។

តើអច្ច័យទានមានប៉ុន្មានប្រភេទ ហើយអច្ច័យលាភី ដែលជាអ្នកទទួលអច្ច័យទានមានសិទ្ធិ និង កាតព្វកិច្ចយ៉ាងដូចម្តេចខ្លះ?

**ក.ប្រភេទនៃអច្ច័យទាន**

តាមរយៈការកំណត់របស់ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ អច្ច័យទាន ចែកចេញជាពីរប្រភេទគឺ ៖

- អច្ច័យទានសកល និង
- អច្ច័យទានមានកំណត់។

**អច្ច័យទានសកល** គឺជាប្រទានកម្មដែលម្ចាស់បណ្តាំធ្វើឲ្យមនុស្សម្នាក់ ឬ ច្រើននាក់នូវទ្រព្យសម្បត្តិទាំងអស់ ឬ មួយផ្នែក ដែលកំណត់ទៅតាមភាគ តាមរយៈមតកសាសន៍។ ចំណែកឯ**អច្ច័យទានមានកំណត់**វិញ គឺជាប្រទានកម្មដែលកំណត់ទ្រព្យសម្បត្តិជាក់លាក់ទៅឲ្យមនុស្សម្នាក់ ឬ ច្រើននាក់ តាមរយៈមតកសាសន៍[10]។

**ខ.អច្ច័យលាភី សិទ្ធិ និង កាតព្វកិច្ច**

**១.អច្ច័យលាភី**

អច្ច័យលាភី គឺជាបុគ្គលដែលបានទទួលអច្ច័យទាន។ បើសិនជាអច្ច័យលាភីបានទទួលមរណភាពមុនពេលម្ចាស់បណ្តាំទទួលមរណភាព នោះអច្ច័យទានពុំមានអានុភាពឡើយ។ ប៉ុន្តែមតកជនក៏អាចសម្តែងឆន្ទៈផ្សេងពីនេះនៅក្នុងលិខិតមតកសាសន៍ដែរ[11]។ ករណីដែលម្ចាស់បណ្តាំធ្វើអច្ច័យទានចំពោះទារកដែលនៅក្នុងគភ៌ បើសិនជាទារកមានកំណើតក្រោយពេលម្ចាស់បណ្តាំទទួលមរណភាព ហើយទារកនោះអាចរស់រានមានជីវិតបាន នោះអានុភាពនៃអច្ច័យទានក៏កើតមានឡើងដែរ[12]។

**២.សិទ្ធិ និង កាតព្វកិច្ចរបស់អច្ច័យលាភី**

អច្ច័យលាភី មានសិទ្ធិក្នុងការទទួល ឬ បោះបង់អច្ច័យទានបាន។ អច្ច័យលាភី អាចបោះបង់អច្ច័យទានសកលនៅពេលណាក៏បានដែរ ក្រោយពេលដែលម្ចាស់បណ្តាំទទួលមរណភាព។ ចំពោះការបោះបង់អច្ច័យទានសកលនេះ ត្រូវអនុវត្តដូចការបោះបង់សន្តតិកម្មដែរ[13]។ ដោយឡែកចំពោះការបោះបង់អច្ច័យទានមានកំណត់វិញ ពុំមានបញ្ញត្តិណាមួយនៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានចែងនោះទេ។

---

[10] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៩៩។

[11] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២០០។

[12] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩ កថាខណ្ឌទី ៣ ។

[13] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២០១។

ដើម្បីចៀសវាងភាពយឺតយ៉ាវនៃការធ្វើសន្តតិកម្ម បុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍ អាចដាស់តឿនឲ្យអច្ច័យលាភីធ្វើការទទួលស្គាល់ ឬ បោះបង់នូវអច្ច័យទានក្នុងអំឡុងពេលសមរម្យមួយ។ បើអច្ច័យលាភីមិនបានបង្ហាញឆន្ទៈ ចំពោះបុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធទៅនឹងអច្ច័យទាន នៅអំឡុងពេលដែលបានកំណត់នោះទេ គេចាត់ទុកថា អច្ច័យលាភីបានទទួលស្គាល់អច្ច័យទាននោះ[14]។ ករណីដែលអច្ច័យលាភីបានទទួលមរណភាព ដោយមិនបានបង្ហាញឆន្ទៈក្នុងការបោះបង់ ឬ ទទួលស្គាល់អច្ច័យទាននៅឡើយ នោះសន្តតិជនរបស់អច្ច័យលាភី អាចធ្វើការទទួលស្គាល់ ឬ បោះបង់អច្ច័យទានបានត្រឹមទំហំនៃសិទ្ធិលើសន្តតិកម្មរបស់ខ្លួនប៉ុណ្ណោះ។ ប៉ុន្តែប្រសិនបើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុវត្តតាមឆន្ទៈនោះ[15]។

ក្នុងករណីដែលអច្ច័យលាភីជាសន្តតិជន បើបានបោះបង់សន្តតិកម្ម បុគ្គលនោះត្រូវបានចាត់ទុកថាបានបោះបង់អច្ច័យទានផងដែរ ហើយអច្ច័យលាភីនោះ មិនអាចទទួលស្គាល់អច្ច័យទានដោយបោះបង់សន្តតិកម្មបានឡើយ[16]។

លើសពីនេះទៅទៀត អច្ច័យលាភីមានសិទ្ធិក្នុងការទាមទារផលប្រយោជន៍របស់ខ្លួន បន្ទាប់ពីអច្ច័យទានមានអានុភាព ពោលគឺបន្ទាប់ពីមតកជនទទួលមរណភាព។ ប៉ុន្តែ ប្រសិនបើអច្ច័យទានមានល័ក្ខខ័ណ្ឌបង្អង់ អច្ច័យលាភីអាចទាមទារឲ្យអនុវត្តអច្ច័យទានបានលុះត្រាតែល័ក្ខខ័ណ្ឌបង្អង់នោះត្រូវបានបំពេញសិន[17]។

អច្ច័យទានមានល័ក្ខខ័ណ្ឌជាច្រើនទៀតដែលជាលក្ខណៈពិសេស ប៉ុន្តែ យើងធ្វើការសិក្សាតែចំណុចសំខាន់ៗនៃអច្ច័យទានប៉ុណ្ណោះ។ ជាបន្តបន្ទាប់ យើងងាកមកធ្វើការសិក្សាពីលក្ខណៈមតកសាសន៍ (**កថាខណ្ឌទី ១**) និង សមត្ថភាពក្នុងការធ្វើមតកសាសន៍ (**កថាខណ្ឌទី ២**) នៅក្នុង **ផ្នែកទី ២** ខាងក្រោម។

## ផ្នែកទី ២ ៖ លក្ខណៈនៃមតកសាសន៍ និង សមត្ថភាពក្នុងការធ្វើមតកសាសន៍

### កថាខណ្ឌទី ១ ៖ លក្ខណៈនៃមតកសាសន៍

តាមរយៈមតកសាសន៍ មតកជនអាចសម្តែងឆន្ទៈ និង គោលបំណងចុងក្រោយបង្អស់របស់ខ្លួន ក្នុងការចាត់ចែងមតិករបស់ខ្លួនបាន។ មតកសាសន៍ មានលក្ខណៈដូចតទៅ ៖

[14] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២០២។
[15] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២០៣។
[16] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២០៥។
[17] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២០៦។

- មតកសាសន៍ ធ្វើឡើងដោយឯកតោភាគី
- ការអនុវត្តមតកសាសន៍ គឺជាសកម្មភាពក្រោយពេលមរណភាព
- មតកសាសន៍ ត្រូវធ្វើតាមទម្រង់
- ចំណុចនៃមតកសាសន៍ ត្រូវបានកំណត់ដោយច្បាប់
- មតកសាសន៍ គឺជាភាពផ្តាច់មុខរបស់បុគ្គល[18]។

**ក.មតកសាសន៍ ធ្វើឡើងដោយឯកតោភាគី**

មតកសាសន៍ ប្រៀបបីដូចជាប្រភេទនៃកិច្ចសន្យាមួយ ប៉ុន្តែមានលក្ខណៈជាឯកតោភាគី (កិច្ចសន្យាឯកតោភាគី)។ ម្ចាស់បណ្តាំ អាចបង្កើតមតកសាសន៍បានដោយខ្លួនឯង ដោយពុំចាំបាច់មានការទទួលស្គាល់ ឬ យល់ព្រមពីសន្តតិជនឡើយ។

**ខ.មតកសាសន៍ អនុវត្តក្រោយពេលមរណភាព**

លិខិតមតកសាសន៍ ត្រូវបានបង្កើតឡើងមុនពេលដែលម្ចាស់បណ្តាំនៃមតកសាសន៍ ទទួលមរណភាព ប៉ុន្តែមតកសាសន៍នឹងមានអានុភាពក្នុងការអនុវត្ត ក្រោយពេលដែលម្ចាស់បណ្តាំទទួលមរណភាព។ តាមរយៈអានុភាពនៃមតកសាសន៍នេះ នៅពេលដែលម្ចាស់បណ្តាំនៅរស់ ម្ចាស់បណ្តាំមានសេរីភាពក្នុងការកែប្រែ លុបចោលនូវមតកសាសន៍នៅពេលណាក៏បានដែរ។ មតកសាសន៍ដែលធ្វើការកែប្រែចុងក្រោយ គឺជាមតកសាសន៍ដែលនឹងមានអានុភាពក្នុងការអនុវត្ត ក្រោយពេលដែលម្ចាស់បណ្តាំទទួលមរណភាព។ ចំពោះនីតិវិធីលំអិតនៃការអនុវត្តមតកសាសន៍នឹងបកស្រាយនៅក្នុង **ជំពូកទី ២** ស្តីពីនីតិវិធីក្នុងការប្រតិបត្តិមតកសាសន៍។

**គ.មតកសាសន៍ ត្រូវធ្វើតាមទម្រង់**

ការបង្កើតមតកសាសន៍ ទាមទារឲ្យធ្វើតាមទម្រង់ និង វិធីដែលបានកំណត់ជាក់លាក់។ ដើម្បីសរបញ្ជាក់ថា មតកសាសន៍នោះពិតជាមតកសាសន៍ដែលចេញពីការពិចារណាយ៉ាងហ្មត់ចត់ និង ឆន្ទៈពិតប្រាកដរបស់មតកជន ឬ មិនមែននោះ ទើបតម្រូវឲ្យមតកសាសន៍ត្រូវតែធ្វើឡើងតាមទម្រង់ដែលបានកំណត់យ៉ាងច្បាស់លាស់មួយ ក្នុងគោលបំណងអាចមើលដឹងថាមានការក្លែងបន្លំ ឬ កែតម្រូវទៅលើមតកសាសន៍ ឬ អត់។ ចំពោះទម្រង់នៃមតកសាសន៍លំអិតនឹងបកស្រាយនៅក្នុង **កថាខណ្ឌទី ១** នៃ **ផ្នែកទី ៣** ស្តីពីទម្រង់នៃមតកសាសន៍ក្នុង **ជំពូកទី ១** នេះ។

[18] សមាជិកក្រុមការងារគ្រូបណ្តុះបណ្តាលនៃសាលាភូមិន្ទចៅក្រម ដោយមានការគាំទ្រពីទីសហប្រតិបត្តិការ JICA, *ក្រមរដ្ឋប្បវេណី ភាគ ៦* (លើកទី ១ ឆ្នាំ២០១២), ទំព័រទី ៣៦ និង ៣៧។

**ឃ.ចំណុចនៃមតកសាសន៍ ត្រូវបានកំណត់ដោយច្បាប់**

មតកជនបានទទួលមរណភាពរួចហើយ ទើបអាចបើកយកមតកសាសន៍មកអនុវត្ត នោះមានន័យថា ការសម្រេចនានាត្រូវបានកម្រិតតាមមតកសាសន៍ ដោយសារតែ មិនមានវត្តមានម្ចាស់បណ្តាំ (ប្រធាននៃសិទ្ធិ) ក្នុងពេលអនុវត្តមតកសាសន៍ឡើយ។ ដូច្នេះ នៅពេលបង្កើតមតកសាសន៍ ម្ចាស់បណ្តាំ ត្រូវតែសរសេររាល់គ្រប់ចំណុចដែលច្បាប់បានកំណត់ឲ្យគ្រប់ជ្រុងជ្រោយ ដើម្បីជៀសវាងអសុពលភាពនៃមតកសាសន៍នៅពេលក្រោយ។ ចំពោះចំណុចដែលត្រូវសរសេរក្នុងមតកសាសន៍នឹងបកស្រាយលំអិតនៅក្នុង **កថាខណ្ឌទី ២** នៃ **ផ្នែកទី ៣** ស្តីពីចំណុចដែលត្រូវសរសេរក្នុងមតកសាសន៍ក្នុង **ជំពូកទី ១** នេះ។

**ង.មតកសាសន៍ គឺជាភាពផ្តាច់មុខរបស់បុគ្គល**

ការអនុវត្តមតកសាសន៍ ជាសកម្មភាពមួយដែលបង្ហាញពីការគោរពតាមឆន្ទៈរបស់មតកជនក្រោយពេលទទួលមរណភាព។ អាស្រ័យហេតុនេះហើយ បានជាគេមិនអនុញ្ញាតឲ្យមានអ្នកតំណាងក្នុងការធ្វើមតកសាសន៍ជំនួសម្ចាស់បណ្តាំឡើយ។ ការសម្រេចនានា គឺជាស្វ័យសម្រេចរបស់ម្ចាស់បណ្តាំមុនពេលទទួលមរណភាពដោយផ្តាច់មុខ។

បន្ទាប់ពីបានសិក្សាពីលក្ខណៈរបស់មតកសាសន៍រួចមក យើងគប្បីយល់ដឹងថា តើជនណាខ្លះទើបអាចមានសមត្ថភាពក្នុងការធ្វើមតកសាសន៍ឡើង?

**កថាខណ្ឌទី ២ ៖ សមត្ថភាពក្នុងការធ្វើមតកសាសន៍**

មតកសាសន៍កំណត់យកឆន្ទៈរបស់ម្ចាស់បណ្តាំជាចម្បង។ នៅពេលបង្កើតមតកសាសន៍ ម្ចាស់បណ្តាំត្រូវតែមានសមត្ថភាពក្នុងការវិនិច្ឆ័យ ត្រិះរិះពិចារណាយ៉ាងច្បាស់លាស់ ទើបបញ្ជាក់ថាមតកសាសន៍ដែលបានបង្កើតឡើងនោះស្តែងចេញពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំ។

**ក.បុគ្គលដែលអាចធ្វើមតកសាសន៍**

បុគ្គលដែលជានីតិជន និងអនីតិជនដែលបានទទួលអគ្គាធីនភាព រួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬ អំណាចមេបា អាចធ្វើមតកសាសន៍បាន[19]។ អនីតិជនដែលទទួលបានអគ្គាធីនភាព ក៏ដូចជានីតិជនដែរ គឺអាចធ្វើមតកសាសន៍បាន ដោយសារតែគេចាត់ទុកថា ជនទាំងនេះជាជនដែលមានសមត្ថភាពឯករាជ្យខាងអំពើ[20] អាចធ្វើអ្វីៗបានដោយខ្លួនឯង ដោយពុំចាំបាច់មានការយល់ព្រមពីអ្នកដទៃឡើយ។

[19] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៦៨។

[20] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, សទ្ទានុក្រមផ្នែករដ្ឋប្បវេណី ទំព័រទី ១០។

លើសពីនោះ ទោះបីជាអ្នកនៅក្រោមអាណាព្យាបាលទូទៅ ឬ អ្នកនៅក្រោមហិតូបត្ថម្ភ ដែលបានទទួលការប្រកាសចាប់ផ្តើមអាណាព្យាបាល ឬ ហិតូបត្ថម្ភក៏ដោយ ក៏អាចធ្វើមតកសាសន៍បានដែរ។ ដើម្បីធ្វើមតកសាសន៍ ជនប្រភេទនេះត្រូវមានសមត្ថភាពខាងឆន្ទៈ ដោយឡែកចំពោះល័ក្ខខ័ណ្ឌក្នុងការធ្វើមតកសាសន៍ក្នុងករណីនេះនឹងធ្វើការបកស្រាយ នៅក្នុងទម្រង់មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ។

ការទទួលស្គាល់ឲ្យអ្នកដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព អាចធ្វើមតកសាសន៍បាន ដោយសារតែមតកសាសន៍នោះនឹងមានអានុភាព ក្រោយពេលដែលជនដែលត្រូវបានកម្រិតនូវសមត្ថភាពនោះបានទទួលមរណភាព ដូច្នេះ អានុភាពនៃមតកសាសន៍នោះមិនមានឥទ្ធិពលទៅលើជីវភាពរស់នៅរបស់បុគ្គលនោះទេ។ ស្របគ្នានេះដែរ ដោយសារជននៅក្រោមអាណាព្យាបាលទូទៅ ឬជននៅក្រោមហិតូបត្ថម្ភអាចធ្វើមតកសាសន៍បាន នោះអ្នកអាណាព្យាបាល ឬ ហិតូបត្ថម្ភកៈ មិនអាចធ្វើការលុបចោលមតកសាសន៍នោះបានឡើយ[21]។

### ខ.សមត្ថភាពនាពេលធ្វើមតកសាសន៍

ម្ចាស់បណ្តាំ ត្រូវមានសមត្ថភាពនៅពេលធ្វើមតកសាសន៍[22]។ ក្នុងករណីដែលម្ចាស់បណ្តាំគ្មានសមត្ថភាពខាងឆន្ទៈពេលធ្វើមតកសាសន៍ ដោយសារអ្នកនោះស្រវឹងស្រាខ្លាំង ឬ ដោយសារតែអ្នកនោះមានជម្ងឺវង្វេងដោយភាពចាស់ជរា មតកសាសន៍នោះត្រូវចាត់ទុកជាមោឃៈ។ ប្រសិនបើមានបុគ្គលអាចអះអាងថា នៅពេលធ្វើមតកសាសន៍ ម្ចាស់បណ្តាំខ្វះសមត្ថភាពខាងឆន្ទៈ បុគ្គលនោះត្រូវបញ្ជាក់ភស្តុតាងអំពីហេតុនោះ[23]។

បន្ទាប់ពីបានសិក្សាពីចរិកលក្ខណៈ និង សមត្ថភាពក្នុងការធ្វើមតកសាសន៍នៅក្នុង**ផ្នែកទី ២** រួចមក យើងនឹងធ្វើការសិក្សាលំអិតពីវិធីក្នុងការធ្វើមតកសាសន៍នៅក្នុង **ផ្នែកទី ៣** ខាងក្រោម។

[21] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ គន្ថីទី ៨-ទី ៩* (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០១០), ទំព័រទី ៣១។

[22] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៦៩ កថាខណ្ឌទី ១។

[23] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ គន្ថីទី ៨-ទី ៩* (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០១០), ទំព័រទី ៣១។

## ផ្នែកទី ៣ ៖ វិធីក្នុងការធ្វើមតកសាសន៍

មតកសាសន៍ ចាំបាច់ត្រូវធ្វើឡើងតាមទម្រង់ដែលបានកំណត់ដោយក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។ ចំពោះមតកសាសន៍ដែលពុំបានធ្វើឡើងតាមវិធីដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ទេ មតកសាសន៍នោះពុំមានអានុភាពក្នុងការអនុវត្តនោះឡើយ[24]។ ដើម្បីសរបញ្ជាក់ឆន្ទៈរបស់ម្ចាស់បណ្តាំឲ្យមានភាពច្បាស់លាស់ ជៀសវាងនូវទំនាស់នៅពេលក្រោយ និង ដើម្បីការពារកុំឲ្យមានការក្លែងបន្លំមតកសាសន៍ ទើបក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានធ្វើការកំណត់យ៉ាងលំអិតអំពីវិធីធ្វើមតកសាសន៍នេះ។

ក្នុងករណីមានមតកសាសន៍ច្រើន ចំពោះមតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំ តែត្រឹមត្រូវតាមចំណុចផ្សេងទៀតនៃទម្រង់ អាចចាត់ទុកថាមតកសាសន៍នោះមានសុពលភាពបាន លុះត្រាតែមតកសាសន៍នោះ មិនផ្ទុយនឹងមតកសាសន៍ផ្សេងទៀតដែលបានធ្វើដោយម្ចាស់បណ្តាំ។ នៅក្នុងករណីដែលមតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំមានចំនួនច្រើន ហើយបើមតកសាសន៍ទាំងនោះផ្ទុយគ្នា ដោយសារតែមិនដឹងថាមតកសាសន៍មួយណាធ្វើមុន មួយណាធ្វើក្រោយ ដូច្នេះ អានុភាពនៃមតកសាសន៍ទាំងនោះត្រូវកាត់បន្ថយគ្នាទៅវិញទៅមក យកគំនិតរួមមួយដែលស្របគ្នា[25]។

ដោយឡែកចំពោះបុគ្គលដែលបានកំណត់ខាងក្រោមនេះ ទោះបីក្នុងកាលៈទេសៈណាក៏ដោយ ក៏មិនអាចធ្វើជាសាក្សី ឬ ជាអ្នកសង្កេតការណ៍នៅពេលធ្វើមតកសាសន៍បានឡើយ ៖

- អនីតិជន ឬ ជននៅក្រោមអាណាព្យាបាលធម្មតា
- ជនដែលត្រូវសន្មតថាជាសន្តតិជន អច្ច័យលាភី សហព័ទ្ធ និងញាតិលោហិតខ្សែផ្ទាល់
- បើសារការីជាអ្នកពាក់ព័ន្ធក្នុងការធ្វើមតកសាសន៍ជាលិខិតយថាភូត ឬ មតកសាសន៍ដោយលិខិតសម្ងាត់ សហព័ទ្ធរបស់សារការី ញាតិលោហិតខ្សែផ្ទាល់ ក្រឡាបញ្ជី និង និយោជិតរបស់សារការីនោះ[26]។

មតកសាសន៍ ត្រូវធ្វើឡើងតាមទម្រង់ដែលបានកំណត់ដោយក្រមរដ្ឋប្បវេណី តើទម្រង់ទាំងនោះមានលក្ខណៈយ៉ាងដូចម្តេចខ្លះ? យើងនឹងធ្វើការសិក្សាបន្ទាប់នៅក្នុង **កថាខណ្ឌទី ១** ស្តីពីទម្រង់នៃមតកសាសន៍ខាងក្រោម។

[24] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧០ កថាខណ្ឌទី ១។
[25] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧០ កថាខណ្ឌទី ២។
[26] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧២។

**កថាខណ្ឌទី ១ ៖ ទម្រង់នៃមតកសាសន៍**

មតកសាសន៍ណា ដែលត្រូវនឹងទម្រង់ណាមួយដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ត្រូវចាត់ទុកថា មតកសាសន៍នោះមានសុពលភាពចំពោះទម្រង់[27]។ តាមរយៈការកំណត់របស់ក្រមរដ្ឋប្បវេណី មតកសាសន៍មានច្រើនបែបច្រើនទម្រង់ផ្សេងៗគ្នា ហើយម្ចាស់បណ្ដាំអាចធ្វើការជ្រើសរើសយកទម្រង់ណាមួយក៏បាន ដើម្បីធ្វើមតកសាសន៍។

ដូច្នេះ ដើម្បីងាយស្រួលយល់ច្បាស់ពីទម្រង់នៃមតកសាសន៍នីមួយៗដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ យើងធ្វើការបែងចែកទម្រង់មតកសាសន៍ទាំងនោះជាពីរធំៗ គឺ

- ទម្រង់នៃមតកសាសន៍ធម្មតា (**ក**) និង
- ទម្រង់នៃមតកសាសន៍ពិសេស (**ខ**)

**ក.ទម្រង់នៃមតកសាសន៍ធម្មតា**

ទម្រង់នៃមតកសាសន៍ធម្មតា ត្រូវបានបែងចែកជា ៣ (បី) ទម្រង់ ដែលមានដូចជា ៖

- មតកសាសន៍ដោយលិខិតយថាភូត
- មតកសាសន៍ដោយលិខិតឯកជន និង
- មតកសាសន៍ដោយលិខិតសម្ងាត់។

**១.មតកសាសន៍ដោយលិខិតយថាភូត**

មតកសាសន៍ដោយលិខិតយថាភូត សំដៅទៅលើលិខិតដែលត្រូវបានធ្វើឡើងដោយសារការី (សម្រាប់ជនជាតិខ្មែររស់នៅក្នុងប្រទេស) ឬ កុងស៊ុល (សម្រាប់ជនជាតិខ្មែររស់នៅបរទេស)[28]។ មតកសាសន៍ដោយលិខិតយថាភូត ត្រូវធ្វើដោយម្ចាស់បណ្ដាំ នៅចំពោះមុខសារការី ឬ កុងស៊ុល តាមទម្រង់នានាដែលបានកំណត់ដូចខាងក្រោម ៖

- ត្រូវមានវត្តមានរបស់សាក្សីយ៉ាងតិច ២ (ពីរ) នាក់
- ម្ចាស់បណ្ដាំត្រូវប្រាប់ផ្ទាល់មាត់ នូវខ្លឹមសារនៃមតកសាសន៍ចំពោះសារការី
- សារការីត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្ដាំនោះ ជាលាយល័ក្ខណ៍អក្សរ ហើយត្រូវសូត្រឲ្យម្ចាស់បណ្ដាំ និង សាក្សីនោះស្ដាប់
- បន្ទាប់ពីម្ចាស់បណ្ដាំ និង សាក្សី បានទទួលស្គាល់ថាកំណត់ជាលាយល័ក្ខណ៍អក្សរនោះត្រឹមត្រូវហើយ ជននីមួយៗនោះត្រូវធ្វើឲ្យមានភាពច្បាស់លាស់នៅលើឯកសារអំពីឈ្មោះ

[27] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧១។

[28] ច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១, មាត្រា ៩។

អាយុ និង លំនៅឋាន ហើយត្រូវចុះហត្ថលេខារៀងៗខ្លួន។ ប៉ុន្តែបើម្ចាស់បណ្តាំ មិនអាចសរសេរអក្សរ ឬ មិនអាចចុះហត្ថលេខាបានទេ សារការីអាចជំនួសការសរសេរ និង ហត្ថលេខាដូចកំណត់ខាងលើនេះ ដោយសរសេរឈ្មោះ អាយុ និង លំនៅឋានរបស់ជននោះ ហើយត្រូវសរសេរបន្ថែមនូវហេតុនោះផង

- សារការីត្រូវសរសេរថ្ងៃ ខែ ឆ្នាំ ហើយត្រូវចុះហត្ថលេខា[29]។

ចំពោះការប្រាប់ផ្ទាល់មាត់នូវខ្លឹមសារនៃមតកសាសន៍ ដែលបានរៀបរាប់នៅក្នុងចំណុចទីពីរខាងលើនេះ ជាទូទៅ គឺជាការនិយាយប្រាប់សារការីនូវខ្លឹមសារនៃបណ្តាំដែលម្ចាស់បណ្តាំបានសរសេរព្រាងដោយប្រើពាក្យពេចន៍សាមញ្ញ បន្ទាប់មកសារការីសរសេរបញ្ចូលក្នុងលិខិតយថាភូតនូវខ្លឹមសារទាំងនោះឲ្យមានន័យតាមផ្លូវច្បាប់។

ចំពោះការកំណត់សាក្សីវិញ ក្រមរដ្ឋប្បវេណីថ្មីឆ្នាំ ២០០៧ មិនបានបញ្ជាក់ឲ្យច្បាស់លាស់ថា តើអនក្ខរជនមានលក្ខណសម្បត្តិអាចធ្វើជាសាក្សី ឬ អត់ទេ ក៏ប៉ុន្តែយោងតាមក្រមរដ្ឋប្បវេណីចាស់ (ក្រមរដ្ឋប្បវេណី ១៩២០) មាត្រា ៥៥៧ បានទទួលស្គាល់ថា អនក្ខរជនក៏មានលក្ខណសម្បត្តិធ្វើជាសាក្សីដែរ។

ចំណុចដែលគួរធ្វើការពិចារណានោះត្រង់ថា ដើម្បីឲ្យសាក្សីទទួលស្គាល់ថា កំណត់ត្រាជាលាយល័ក្ខណ៍អក្សរនោះត្រឹមត្រូវ ដោយយោងតាមចំណុចទីបួនខាងលើ សាក្សីនោះមិនត្រឹមតែអាចស្តាប់តែខ្លឹមសារនៃមតកសាសន៍ដែលសារការីសូត្រឲ្យម្ចាស់បណ្តាំ និង សាក្សីនោះស្តាប់ប៉ុណ្ណោះទេ គឺគួរតែពិនិត្យមើលនូវខ្លឹមសារដែលបានសរសេរនោះដែរ។ ដូច្នេះ គប្បីឲ្យអ្នកចេះអក្សរធ្វើជាសាក្សីទើបជាការប្រសើរ[30]។

មតកសាសន៍ដោយលិខិតយថាភូត មាន **គុណសម្បត្តិ** និង **គុណវិបត្តិ** ដូចជា ៖

**គុណសម្បត្តិ**

- សារការីដែលជាអ្នកជំនាញខាងច្បាប់ជាអ្នកធ្វើមតកសាសន៍ប្រភេទនេះ នោះ មិនមានបញ្ហាអសុពលភាពដោយសារកង្វះលក្ខណៈទេ ដូច្នេះមតកសាសន៍ដោយលិខិតយថាភូត មានភាពត្រឹមត្រូវច្បាស់លាស់

---

[29] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៣។

[30] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ គន្ថីទី ៨-ទី ៩* (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០១០), ទំព័រទី ៣៩។

- ជនដែលមិនចេះអក្សរក៏អាចធ្វើមតកសាសន៍នេះបានដែរ ដោយសារតែ ម្ចាស់មតកសាសន៍គ្រាន់តែពន្យល់អំពីខ្លឹមសារនៃមតកសាសន៍ដោយផ្ទាល់មាត់ចំពោះសារការីតែប៉ុណ្ណោះ
- ពេលអនុវត្តមតកសាសន៍ មិនចាំបាច់មាននីតិវិធីពិនិត្យបញ្ជាក់នោះទេ។

**គុណវិបត្តិ**

- ចាំបាច់មានការអន្តរាគមន៍ពីសំណាក់សារការី នោះនាំឲ្យចំណាយថវិកា
- មានអ្នកទីបី ដែលជាសាក្សីបានដឹងអំពីខ្លឹមសារនៃមតកសាសន៍ដែលជាការសម្ងាត់របស់មតកជនធ្វើមុនពេលទទួលមរណភាព[31]។

**២.មតកសាសន៍ដោយលិខិតឯកជន**

មតកសាសន៍ដោយលិខិតឯកជន ត្រូវធ្វើឡើងដោយម្ចាស់បណ្តាំដោយផ្ទាល់។ ក្នុងនោះម្ចាស់បណ្តាំត្រូវសរសេរពាក្យពេចន៍ទាំងអស់ ព្រមទាំងចុះថ្ងៃខែឆ្នាំ និង ចុះហត្ថលេខាលើលិខិតនោះ។ មតកសាសន៍ដោយលិខិតឯកជនដែលត្រូវបានសរសេរជំនួសដោយអ្នកដទៃ ឬ ដែលត្រូវបានសរសេរដោយប្រើម៉ាស៊ីន (កុំព្យូទ័រជាដើម) នឹងត្រូវចាត់ទុកជាមោឃៈ[32]។

ប្រសិនបើមានការសង្ស័យពីបញ្ហាអំពីសុក្រឹតភាពនៃមតកសាសន៍ នៅពេលអនុវត្តមតកសាសន៍ នោះគេមិនអាចទាមទារឲ្យម្ចាស់បណ្តាំនោះធ្វើសេចក្តីថ្លែងការណ៍បានទេ ដោយសារតែម្ចាស់បណ្តាំបានទទួលមរណភាពហើយ។ ជាដំណោះស្រាយចាំបាច់ត្រូវផ្ទៀងមើលអក្សរ ដោយធ្វើការប្រៀបធៀបនឹងអក្សររបស់សាមីខ្លួនដែលធ្លាប់បានសរសេរក្នុងលិខិតផ្សេងៗ នាពេលនៅរស់តួយ៉ាង សំបុត្រ ឬ សៀវភៅកំណត់ហេតុជាដើម។ ដូច្នេះ បានជាតម្រូវឲ្យម្ចាស់បណ្តាំសរសេរខ្លឹមសារនៃមតកសាសន៍ និង ទាមទារឲ្យចុះហត្ថលេខាដោយសាមីខ្លួនផ្ទាល់។

ក្នុងករណីធ្វើមតកសាសន៍ដោយលិខិតឯកជននេះ ពុំចាំបាច់មានការចុះហត្ថលេខាសរសេរនាមត្រកូល នាមខ្លួន និង ផ្តិតមេដៃ ដោយសារការី និង សាក្សី ដូចមានចែងក្នុងមាត្រា ១១៨០ នៃក្រមរដ្ឋប្បវេណីនោះទេ ។

ចំពោះការបន្ថែម ការលុប ឬ ការកែប្រែផ្សេងទៀត នៅក្នុងមតកសាសន៍ដោយលិខិតឯកជននឹងពុំមានអានុភាពឡើយ បើម្ចាស់បណ្តាំមិនបានសរសេរបន្ថែមនូវហេតុនៃការកែប្រែនោះជាពិសេសបើមិនបានចុះហត្ថលេខាទេ [33] ។ មូលហេតុដែលទាមទារឲ្យមានការបញ្ជាក់ឲ្យបាន

[31] សមាជិកក្រុមការងារគ្រូបណ្តុះបណ្តាលនៃសាលាភូមិន្ទចៅក្រម ដោយមានការគាំទ្រពីទីសហប្រតិបត្តិការ JICA, *ក្រមរដ្ឋប្បវេណី ភាគ ៦* (លើកទី ១ ឆ្នាំ២០១២), ទំព័រទី ៣៨។

[32] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៤ កថាខណ្ឌទី ១។

[33] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៤ កថាខណ្ឌទី ២។

ច្បាស់លាស់បែបនេះ ដោយហេតុថា អាចមានករណីដែលតតិយជនធ្វើការផ្លាស់ប្តូរ តាមរយៈការសរសេរបន្ថែម ឬ លុបចោលពាក្យខ្លះក្នុងមតកសាសន៍។ ក្នុងករណីដែលម្ចាស់បណ្តាំខ្លួនឯងចង់ផ្លាស់ប្តូរ សរសេរបន្ថែម ឬ លុបចោលពាក្យពេចន៍ខ្លះ ត្រូវសរសេរបញ្ជាក់នូវការផ្លាស់ប្តូរនោះ ហើយចាំបាច់ត្រូវចុះហត្ថលេខាផងដែរ ដើម្បីបញ្ជាក់ឲ្យបានច្បាស់ថា តើការផ្លាស់ប្តូរ សរសេរបន្ថែម ឬ ការលុបចោលនោះ ធ្វើឡើងដោយសាមីខ្លួនមែន ឬ ទេ[34]។

មតកសាសន៍ដោយលិខិតឯកជន មាន **គុណសម្បត្តិ** និង **គុណវិបត្តិ** ដូចជា ៖

**គុណសម្បត្តិ**

- ម្ចាស់បណ្តាំ អាចធ្វើមតកសាសន៍ដោយលិខិតឯកជនបានដោយខ្លួនឯង ដោយពុំចាំបាច់មានអន្តរាគមន៍ពីសារការី ឬ វត្តមានរបស់សាក្សី
- ដោយសារគ្មានអន្តរាគមន៍ពីសារការី នោះមិនចាំបាច់ចំណាយសោហ៊ុយ
- ដោយសារតែគ្មានវត្តមានរបស់សាក្សី នោះអាចរក្សាការសម្ងាត់នៃខ្លឹមសារនៃមតកសាសន៍បាន។

**គុណវិបត្តិ**

- មិនសូវមានភាពត្រឹមត្រូវច្បាស់លាស់នោះទេ ព្រោះម្ចាស់បណ្តាំមិនមែនជាអ្នកច្បាប់ នោះអាចមានករណីអសុពលភាព ដោយសារតែអាចផ្ទុយនឹងទម្រង់
- បើសិនជាអ្នកដែលមិនចេះអក្សរ នោះមិនអាចធ្វើមតកសាសន៍ដោយលិខិតឯកជនបានទេ
- អាចបាត់បង់ អាចមានការក្លែងបន្លំ ឬ ធ្វើក្លែងក្លាយបាន
- ចាំបាច់ទាមទារឲ្យមានការត្រួតពិនិត្យបញ្ជាក់ ដើម្បីអនុវត្តមតកសាសន៍ដោយលិខិតឯកជននេះ[35]។

### ៣.មតកសាសន៍ដោយលិខិតសម្ងាត់

វិធីធ្វើមតកសាសន៍ដោយលិខិតសម្ងាត់នេះ ខុសពីវិធីធ្វើមតកសាសន៍ដោយលិខិតឯកជន ដោយសារតែម្ចាស់បណ្តាំអាចសរសេរដោយខ្លួនឯង ឬ អាចពឹងឲ្យអ្នកផ្សេងដែលខ្លួនជឿទុកចិត្តសរសេរជំនួស ឬ អាចប្រើម៉ាស៊ីនសរសេរជាដើមបាន។ ប៉ុន្តែ ប្រសិនបើសរសេរដោយខ្លួនឯងផ្ទាល់

[34] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ គន្ថីទី ៨-ទី ៩* (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០១០), ទំព័រទី ៣៧។

[35] សមាជិកក្រុមការងារគ្រូបណ្តុះបណ្តាលនៃសាលាភូមិន្ទចៅក្រម ដោយមានការគាំទ្រពីទីសហប្រតិបត្តិការ JICA, *ក្រមរដ្ឋប្បវេណី ភាគ ៦* (លើកទី ១ ឆ្នាំ២០១២), ទំព័រទី ៣៩។

ទោះបីជាមិនស្របនឹងល័ក្ខខ័ណ្ឌនៃវិធីធ្វើមតកសាសន៍ដោយលិខិតសម្ងាត់ក៏ដោយ ក៏មានសុពលភាពជាមតកសាសន៍ដោយលិខិតឯកជនដែរ[36] (សុពលភាពនៃទម្រង់ មាត្រា ១១៧១)។

មតកសាសន៍ដោយលិខិតសម្ងាត់ ត្រូវធ្វើឡើងដោយយោងតាមទម្រង់ខាងក្រោម ៖

- បន្ទាប់ពីធ្វើលិខិតមតកសាសន៍រួច ម្ចាស់បណ្ដាំត្រូវចុះហត្ថលេខាលើលិខិតនោះ
- ម្ចាស់បណ្ដាំត្រូវដាក់លិខិតនោះក្នុងស្រោមបិទជិត ហើយត្រូវចុះហត្ថលេខា ឬ សរសេរសញ្ញាសម្គាល់ ឬ មធ្យោបាយផ្សេងទៀតដែលអាចវិនិច្ឆ័យបានអំពីការបានបើក ឬ មិនបានបើកស្រោមលិខិតនោះ នៅមាត់ស្រោមលិខិតនោះ
- ម្ចាស់បណ្ដាំត្រូវដាក់លិខិតដែលបានបិទជិតនោះ នៅចំពោះមុខសារការីម្នាក់ និង សាក្សី ២ (ពីរ) នាក់ និង ធ្វើសេចក្ដីថ្លែងការណ៍ថា លិខិតនោះជាលិខិតមតកសាសន៍របស់ខ្លួន ហើយបើមានជនក្រៅពីសាមីខ្លួនបានសរសេរជំនួស ត្រូវធ្វើសេចក្ដីថ្លែងការណ៍អំពីឈ្មោះ និងលំនៅឋានរបស់ជនដែលបានសរសេរនោះ
- សារការីត្រូវចុះថ្ងៃខែឆ្នាំ ដែលសាមីខ្លួនបានដាក់លិខិតនោះ និង សរសេរសេចក្ដីថ្លែងការណ៍របស់ម្ចាស់បណ្ដាំនៅលើលិខិតដែលបិទជិតនោះ ហើយត្រូវចុះហត្ថលេខាលើលិខិតនោះជាមួយនឹងសាក្សី និង ម្ចាស់បណ្ដាំ[37]។ សារការីជាអ្នករក្សាទុកលិខិតមតកសាសន៍នេះ ដូច្នេះ ការបើក ការលុបចោល ការកែប្រែលើលិខិតមតកសាសន៍នឹងមិនអាចកើតមានឡើយ។

មតកសាសន៍ដោយលិខិតសម្ងាត់ មាន **គុណសម្បត្តិ** និង **គុណវិបត្តិ** ដូចជា ៖

**គុណសម្បត្តិ**

- ទោះបីអ្នកដែលមិនចេះអក្សរ ក៏អាចធ្វើមតកសាសន៍ដោយលិខិតសម្ងាត់បានដែរ
- អាចរក្សាការពារ ការធ្វើក្លែងក្លាយ ឬ ក្លែងបន្លំបាន ដោយសារតែទុកនៅសារការី
- អាចរក្សាការសម្ងាត់អំពីខ្លឹមសារនៃមតកសាសន៍បាន ដោយសារតែពុំចាំបាច់ឲ្យសារការីសូត្រឲ្យសាក្សីស្ដាប់ ដូចមតកសាសន៍តាមលិខិតយថាភូតឡើយ។

**គុណវិបត្តិ**

- ចាំបាច់មានការអន្តរាគមន៍ពីសារការី

---

[36] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមរដ្ឋប្បវេណី, *សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ គន្លីទី ៨-ទី ៩* (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០១០), ទំព័រទី ៣៨។

[37] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៥។

- ចាំបាច់ធ្វើការពិនិត្យបញ្ជាក់ ពេលអនុវត្តមតកសាសន៍[38]។

ក្រោយពីបានធ្វើការសិក្សាលំអិតអំពីទម្រង់នៃមតកសាសន៍ធម្មតាទាំង ៣ (បី) ទម្រង់ រួចមក ជាបន្តបន្ទាប់យើងនឹងធ្វើការសិក្សាពីទម្រង់នៃមតកសាសន៍ពិសេស (**ខ**) ខាងក្រោម។

**ខ.ទម្រង់នៃមតកសាសន៍ពិសេស**

ទម្រង់នៃមតកសាសន៍ពិសេស ក៏មានទាក់ទងនឹងទម្រង់នៃមតកសាសន៍ធម្មតាទាំង ៣ (បី) ខាងលើផងដែរ គ្រាន់តែការធ្វើមតកសាសន៍ពិសេសនេះ មានលក្ខណៈពិសេសជាងទម្រង់នៃមតកសាសន៍ធម្មតា។

ទម្រង់នៃមតកសាសន៍ពិសេសដែលមានចែងក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ មានដូចជា៖

- មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ
- មតកសាសន៍នៃជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត
- មតកសាសន៍នៃជនត្រូវជាប់ឃុំឃាំង ឬជនដែលនៅក្នុងនាវា យន្តហោះ
- មតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបាន។

**១.មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ**

តាមរយៈការបង្ហាញក្នុង **កថាខណ្ឌទី២** នៃ **ផ្នែកទី ២** ស្តីពីសមត្ថភាពក្នុងការធ្វើមតកសាសន៍ខាងលើ ជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ក៏មានសមត្ថភាពក្នុងការធ្វើមតកសាសន៍បានដែរ។

ដើម្បីធ្វើមតកសាសន៍ប្រភេទនេះបាន លុះត្រាតែជននៅក្រោមអាណាព្យាបាលទូទៅបានសះស្បើយមួយរយៈឡើងវិញនូវសមត្ថភាពក្នុងការយល់ដឹង និង អាចធ្វើការវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន។ លើសពីនេះទៅទៀត នៅពេលធ្វើមតកសាសន៍ត្រូវមានវត្តមានវេជ្ជបណ្ឌិតយ៉ាងតិច ២ (ពីរ) នាក់ ហើយវេជ្ជបណ្ឌិតនោះត្រូវសរសេរបញ្ជាក់បន្ថែមលើលិខិតមតកសាសន៍នោះថា នៅពេលដែលម្ចាស់បណ្តាំបានធ្វើមតកសាសន៍នោះ ម្ចាស់បណ្តាំពុំបានស្ថិតក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិស្មារតីទេ ហើយវេជ្ជបណ្ឌិតនោះត្រូវចុះហត្ថលេខាដោយបញ្ជាក់ថាខ្លួនជាវេជ្ជបណ្ឌិតផងដែរ[39]។

---

[38] សមាជិកក្រុមការងារគ្រូបណ្តុះបណ្តាលនៃសាលាភូមិន្ទចៅក្រម ដោយមានការគាំទ្រពីទីសហប្រតិបត្តិការ JICA, *ក្រមរដ្ឋប្បវេណី ភាគ ៦* (លើកទី ១ ឆ្នាំ២០១២), ទំព័រទី ៥០។

[39] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៦។

ប្រសិនបើជនដែលនៅក្រោមអាណាព្យាបាលទូទៅធ្វើមតកសាសន៍ដោយលិខិតឯកជន ឬ ធ្វើមតកសាសន៍ដោយលិខិតសម្ងាត់ ចាំបាច់ត្រូវមានវត្តមានរបស់វេជ្ជបណ្ឌិតយ៉ាងតិច ២ (ពីរ) នាក់ ដូចបានបង្ហាញខាងលើ នាពេលដែលជននោះសរសេរមតកសាសន៍ដោយផ្ទាល់ ឬ នាពេលជននោះបង្ហាញខ្លឹមសារនៃមតកសាសន៍ទៅឲ្យសារការី។ ម្យ៉ាងទៀត ប្រសិនបើជនដែលនៅក្រោមអាណាព្យាបាលទូទៅធ្វើមតកសាសន៍ដោយលិខិតយថាភូត ត្រូវតែមានវត្តមានសាក្សីផ្សេងទៀតក្រៅពីវេជ្ជបណ្ឌិតដែលបានបង្ហាញខាងលើផងដែរ[40]។

នៅមុនពេលបញ្ចប់ការគណនានូវចំណូលចំណាយក្នុងកិច្ចការអាណាព្យាបាល បើជនដែលនៅក្រោមអាណាព្យាបាលទូទៅបានធ្វើមតកសាសន៍ដែលជាប្រយោជន៍ដល់អ្នកអាណាព្យាបាល ឬ អ្នកដែលនៅជុំវិញខ្លួនរបស់អ្នកអាណាព្យាបាល នោះត្រូវចាត់ទុកមតកសាសន៍នោះជាមោឃៈ។ មូលហេតុដោយសារតែ មានការបារម្ភថា អ្នកអាណាព្យាបាលអាចប្រើល្បិចបោកប្រាស់ជននៅក្រោមអាណាព្យាបាល ឲ្យធ្វើមតកសាសន៍ដើម្បីជាផលប្រយោជន៍សម្រាប់ខ្លួន និង អ្នកនៅជុំវិញរបស់ខ្លួន។ ប៉ុន្តែ ក្នុងករណីដែលអ្នកអាណាព្យាបាលទូទៅ ជាញាតិលោហិតផ្ទាល់ សហព័ទ្ធ ឬ បងប្អូនបង្កើតរបស់ជននៅក្រោមអាណាព្យាបាលទូទៅ នោះបញ្ញត្តិខាងលើនឹងមិនត្រូវយកមកអនុវត្តឡើយ មានន័យថា មតកសាសន៍នោះមិនត្រូវទុកជាមោឃៈឡើយ ដោយសារតែ មតកសាសន៍នោះបង្កើតឡើងដើម្បីជាផលប្រយោជន៍សម្រាប់អ្នកទាំងនោះជាស្រេចរួចមកហើយ[41]។

**២.មតកសាសន៍នៃជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត**

ទោះបីជាកំពុងស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិតក៏ដោយ ប្រសិនបើមានសមត្ថភាពធ្វើមតកសាសន៍ ជននោះអាចធ្វើមតកសាសន៍ដោយលិខិតឯកជនបាន។ ម្យ៉ាងទៀត ប្រសិនបើមានពេលអាចហៅសារការីបាន ក៏អាចធ្វើមតកសាសន៍ដោយលិខិតយថាភូតបានដែរ។ ករណីដែលគ្មានសមត្ថភាព ឬ គ្មានពេលវេលា ពេលនោះ ម្ចាស់បណ្តាំក៏អាចធ្វើមតកសាសន៍ដោយផ្ទាល់មាត់ ចំពោះមុខអ្នកមានវត្តមានបានដែរ។

នីតិវិធីនៃការធ្វើមតកសាសន៍ក្នុងករណីនេះ មានដូចខាងក្រោម ៖

ប្រសិនបើជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ដោយសារតែជម្ងឺ ឬ ហេតុផ្សេងទៀត មានបំណងចង់ធ្វើមតកសាសន៍ មតកសាសន៍នេះអាចធ្វើបានដោយតម្រូវឲ្យមាន

---

[40] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ គន្ថីទី ៨-ទី ៩* (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០១០), ទំព័រទី ៣៩។

[41] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៩៥។

វត្តមានរបស់សាក្សីយ៉ាងតិច ៣ (បី) នាក់ ហើយម្ចាស់បណ្ដាំត្រូវប្រកាសខ្លឹមសារនៃមតកសាសន៍នោះ ដោយផ្ទាល់មាត់ ចំពោះជនម្នាក់ ក្នុងចំណោមសាក្សីនោះ។ ជនដែលបានទទួលការប្រកាសផ្ទាល់មាត់នោះត្រូវសរសេរជាលាយល័ក្ខណ៍អក្សរ ហើយអានឲ្យសាក្សីដទៃទៀតស្ដាប់។ នៅក្រោយពេលដែលសាក្សីនីមួយៗបានទទួលស្គាល់ថា ការសរសេរនោះត្រឹមត្រូវហើយ សាក្សីនីមួយៗនោះត្រូវចុះហត្ថលេខាលើលិខិតនោះ។

ដោយសារតែការធ្វើមតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់ អាយុជីវិត គឺធ្វើតាមវិធីពិសេស តម្រូវសាក្សីណាម្នាក់ ឬ បុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ដាក់ពាក្យសុំទៅតុលាការ នៅក្នុងអំឡុងពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានធ្វើមតកសាសន៍នោះ ដើម្បីឲ្យតុលាការធ្វើការបញ្ជាក់។ ចំពោះតុលាការវិញ អាចមានសិទ្ធិក្នុងការបដិសេធមិនធ្វើការបញ្ជាក់មតកសាសន៍នោះ ប្រសិនបើគ្មានជំនឿទុកចិត្តថា មតកសាសន៍នោះ ចេញពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្ដាំ[42]។

### ៣.មតកសាសន៍នៃជនត្រូវជាប់ឃុំឃាំង ឬជនដែលនៅក្នុងនាវា យន្តហោះ

ចំពោះជនដែលត្រូវជាប់ឃុំឃាំង ឬ ជនដែលនៅក្នុងនាវា យន្តហោះ អាចធ្វើមតកសាសន៍ដោយវិធីដូចគ្នានឹងការធ្វើមតកសាសន៍ដោយលិខិតយថាភូត ឬ មតកសាសន៍ដោយលិខិតឯកជនបាន។ ប៉ុន្តែ នៅក្នុងករណីខ្លះដែលមិនអាចធ្វើមតកសាសន៍ដោយលិខិតឯកជនបាន ដោយសារជននោះជាអនក្ខរជន ឬ ហេតុផលផ្សេងទៀត ជាហេតុត្រូវអនុវត្តដូចខាងក្រោមនេះ[43]។

- **ចំពោះជនដែលត្រូវជាប់ឃុំឃាំង**

បុគ្គលដែលជាប់ឃុំឃាំងនៅទីកន្លែងដាច់ដោយឡែក ដោយសាលក្រម សាលដីកា ឬ ដោយសារការចាត់ចែងផ្នែករដ្ឋបាល អាចធ្វើលិខិតមតកសាសន៍បាន ដោយត្រូវឲ្យមានវត្តមានរបស់នគរបាល ឬ មន្ត្រីនៃមន្ទីរឃុំឃាំងម្នាក់ និង សាក្សី យ៉ាងតិច ២ (ពីរ) នាក់។

- **ចំពោះជនដែលជាប់ក្នុងនាវា ឬ យន្តហោះ**

បុគ្គលដែលនៅក្នុងនាវា ឬ យន្តហោះ អាចធ្វើលិខិតមតកសាសន៍បាន ដោយត្រូវមានវត្តមានមេបញ្ជាការ បរិបាលនាវា យន្តហោះ ឬ បុគ្គលិកនាវា យន្តហោះម្នាក់ និង សាក្សីយ៉ាងតិច ២ (ពីរ) នាក់។

---

[42] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៧។

[43] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមរដ្ឋប្បវេណី, *សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ គន្ថីទី ៨-ទី ៩* (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០១០), ទំព័រទី ៤២។

**ជារួម** ក្នុងករណីទាំងពីរខាងលើ ម្ចាស់បណ្តាំអាចធ្វើមតកសាសន៍ដោយផ្ទាល់មាត់ ចំពោះ នគរបាល មន្ត្រីនៃមន្ទីរឃុំឃាំង មេបញ្ជាការ បរិបាលនាវា យន្តហោះ ឬ បុគ្គលិកនាវា យន្តហោះ។ ក្នុងករណីនេះ បញ្ញត្តិស្តីពីការធ្វើមតកសាសន៍ដោយលិខិតយថាភូត ត្រូវយកមកអនុវត្តដូចគ្នា ហើយពាក្យថា សារការី ត្រូវបានបកស្រាយថា ជា នគរបាល មន្ត្រីនៃមន្ទីរឃុំឃាំង មេបញ្ជាការ បរិបាលនាវា យន្តហោះ ឬ បុគ្គលិកនាវា យន្តហោះវិញ។

ប្រសិនម្ចាស់បណ្តាំបន្តនៅរស់ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីពេលដែលម្ចាស់ បណ្តាំនោះ ក្រោយមកខ្លួនត្រូវបានដោះលែងពីមន្ទីរឃុំឃាំង ឬ ចុះពីនាវា យន្តហោះវិញ មតក សាសន៍ដែលបានបង្កើតឡើងមុននោះនឹងពុំត្រូវមានអានុភាពឡើយ[44]។

**៤.មតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបាន**

នៅក្នុងករណីដែលបុគ្គលមិនអាចនិយាយបាន ធ្វើមតកសាសន៍តាមទម្រង់ណាមួយក្នុង ចំណោម មតកសាសន៍ដោយលិខិតយថាភូត មតកសាសន៍ដោយលិខិតសម្ងាត់ ឬ មតកសាសន៍ នៃជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ម្ចាស់បណ្តាំនោះអាចជំនួសការប្រាប់ បាន ដោយធ្វើសេចក្តីថ្លែងការណ៍អំពីខ្លឹមសារនៃមតកសាសន៍ ឬ សេចក្តីថ្លែងការណ៍ថា លិខិតនោះ ជាលិខិតមតកសាសន៍ តាមការប្រែរបស់អ្នកបកប្រែ ឬ សរសេរដោយដៃខ្លួនផ្ទាល់ នៅចំពោះមុខ សារការី ឬ សាក្សី។

សារការី ឬ បុគ្គលផ្សេងទៀតដែលបានកំណត់ ត្រូវអានឲ្យម្ចាស់បណ្តាំ ឬ សាក្សីស្តាប់នូវ អត្ថន័យនៃមតកសាសន៍ ក្រោយពេលបានសរសេរជាលាយលក្ខណ៍អក្សរ នូវខ្លឹមសារនៃ មតកសាសន៍នោះ។ ប៉ុន្តែប្រសិនបើម្ចាស់បណ្តាំ និង សាក្សីនោះ ជាមនុស្សថ្លង់មិនអាចស្តាប់បានទេ សារការី ឬ បុគ្គលផ្សេងទៀតដែលត្រូវបានកំណត់ អាចជំនួសការអានឲ្យស្តាប់បាន ដោយប្រាប់អំពី អត្ថន័យដែលខ្លួនបានសរសេរនោះ តាមការបកប្រែរបស់អ្នកបកប្រែ ទៅម្ចាស់បណ្តាំ ឬ សាក្សីនោះ ហើយហេតុទាំងនោះ ត្រូវសរសេរចូលទៅក្នុងលិខិតមតកសាសន៍នោះ[45]។

ក្រោយពីបានជ្រាបច្បាស់ពីទម្រង់នីមួយៗនៃមតកសាសន៍ យើងនឹងធ្វើការសិក្សាទៅលើ ចំណុចដែលត្រូវសរសេរក្នុងមតកសាសន៍ (**កថាខណ្ឌទី ២**) ខាងក្រោមជាបន្តបន្ទាប់។

[44] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៨។

[45] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៩។

**កថាខណ្ឌទី ២ ៖ ចំណុចដែលត្រូវសរសេរក្នុងមតកសាសន៍**

មានតែចំណុចដែលក្រមរដ្ឋប្បវេណីបានចែងនោះទេ ទើបអាចសរសេរក្នុងមតកសាសន៍។ ប៉ុន្តែ ម្ចាស់បណ្តាំក៏អាចសរសេរអ្វីៗផ្សេងក្រៅពីចំណុចទាំងនេះបានដែរ គ្រាន់តែពុំមានអានុភាពតាមផ្លូវច្បាប់ប៉ុណ្ណោះ។

ចំណុចដែលត្រូវសរសេរក្នុងមតកសាសន៍មានដូចជា ៖

- ការផ្តាច់មត៌កពីសន្តតិជន
- ការកំណត់ចំណែក និង ការកំណត់នូវវិធីបែងចែកមត៌ក
- ការកំណត់នូវអ្នកប្រតិបត្តិមតកសាសន៍ និង
- ចំណុចផ្សេងទៀតនៃមតកសាសន៍

**ក.ការផ្តាច់មត៌កពីសន្តតិជន**

ម្ចាស់បណ្តាំ ត្រូវសរសេរបញ្ជាក់ឲ្យបានច្បាស់ថា សន្តតិជនណាខ្លះដែលអាច និង មិនអាចទទួលបានមត៌ក ជាពិសេសប្រសិនបើមតកជនមានបំណងចង់ផ្តាច់មត៌កពីសន្តតិជនណាមួយ ត្រូវសរសេរឲ្យបានច្បាស់លាស់ក្នុងមតកសាសន៍។ នៅពេលរស់ ម្ចាស់បណ្តាំអាចដាក់ពាក្យសុំទៅតុលាការឲ្យផ្តាច់មត៌កពីជនដែលត្រូវបានសន្មតថាជាសន្តតិជន មិនឲ្យទទួលសន្តតិកម្មបាន បើជននោះបានប្រព្រឹត្តនូវសកម្មភាព ដែលបានកំណត់ដូចតទៅ ៖

- បើបានធ្វើបាបចំពោះមតកជន
- បើបានប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ
- បើមិនមកថែទាំមតកជននៅពេលដែលមានជម្ងឺ ក្នុងករណីដែលខ្លួនអាចមកបាន
- បើត្រូវបានទទួលសាលក្រម ឬ សាលដីកាផ្តន្ទាទោសឲ្យជាប់ពន្ធនាគារមួយជីវិត
- បើបានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរគួរឲ្យកត់សម្គាល់។

ម្យ៉ាងវិញទៀត មតកជនក៏អាចបង្ហាញឆន្ទៈអំពីការផ្តាច់មត៌កនេះ តាមរយៈមតកសាសន៍បានដែរ។ ប្រសិនបើមតកជនបង្ហាញឆន្ទៈក្នុងការផ្តាច់មត៌កពីសន្តតិជនតាមរយៈមតកសាសន៍ អ្នកប្រតិបត្តិមតកសាសន៍ ត្រូវដាក់ពាក្យសុំទៅតុលាការឲ្យផ្តាច់មត៌កពីសន្តតិជន ដោយគ្មានការយឺតយ៉ាវនៅក្រោយពេលដែលមតកសាសន៍នោះបានបង្កើតអានុភាព[46]។

[46] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៥១ និង មាត្រា ១១៥២។

**ខ.ការកំណត់ចំណែក និង ការកំណត់នូវវិធីបែងចែកមត៌ក**

ម្ចាស់បណ្តាំ អាចធ្វើប្រទានកម្មនូវទ្រព្យសម្បត្តិទាំងអស់ ឬ មួយផ្នែក ឬ អាចធ្វើប្រទានកម្មដោយមតកសាសន៍ តាមវិធីដែលបានកំណត់នៅក្នុងបញ្ញត្តិស្តីពីអច្ច័យទាន ក្នុងល័ក្ខខ័ណ្ឌដែលអនុលោមតាមបញ្ញត្តិស្តីពីភាគបម្រុង[47]។

ម្ចាស់បណ្តាំ អាចធ្វើអនុប្បទានទ្រព្យសម្បត្តិរបស់ខ្លួនឲ្យជនដែលត្រូវបានសន្មតថាជាសន្តតិជន ឬ តតិយជនដែលមិនមែនជាសន្តតិជនតាមមតកសាសន៍បាន។ ការធ្វើអនុប្បទានទ្រព្យសម្បត្តិចំពោះជនដែលត្រូវបានសន្មតថាជាសន្តតិជនត្រូវបានសន្មត់ថាជាការកំណត់នូវវិធីបែងចែកមតិក។ ចំណែកការធ្វើអនុប្បទានទ្រព្យសម្បត្តិ ចំពោះតតិយជន ហៅថា អច្ច័យទាន[48]។

បើម្ចាស់បណ្តាំបានធ្វើមតកសាសន៍ ដែលមានអត្ថន័យជាការធ្វើអនុប្បទាន នូវទ្រព្យសម្បត្តិជាក់លាក់ឲ្យទៅសន្តតិជនតែម្នាក់ ឬ ច្រើននាក់ មតកសាសន៍នោះត្រូវបានសន្មតថាបាន **កំណត់នូវវិធីបែងចែកមត៌ក** លើកលែងតែនៅក្នុងករណីដែលមតកសាសន៍នោះមានអត្ថន័យជាអច្ច័យទានយ៉ាងច្បាស់លាស់ ដូចជាអច្ច័យទានដែលភ្ជាប់ជាមួយនឹងបន្ទុក ជាអាទិ៍ ហើយបើតម្លៃនៃទ្រព្យសម្បត្តិដែលបានកំណត់នោះ មានចំនួនលើសពីចំណែកមតិករបស់សន្តតិជន នោះត្រូវសន្មតថាបានកំណត់ចំណែកមតិកផងដែរ[49]។

ក្នុងករណីដែលមតកជនបានធ្វើមតកសាសន៍ ចំពោះទ្រព្យសម្បត្តិតែមួយភាគនៅក្នុងចំណោមមតិក បើតម្លៃនៃទ្រព្យសម្បត្តិនោះ មានចំនួនតិចជាងចំណែកមតិក ដែលសន្តតិជននោះត្រូវទទួល លុះត្រាតែពុំមានការបង្ហាញឆន្ទៈផ្សេងទៀតនៅក្នុងមតកសាសន៍ នោះត្រូវសន្មតថាបានកំណត់ត្រឹមតែវិធីបែងចែកមតិកដែលត្រូវធ្លាក់ទៅលើសន្តតិជននោះតែប៉ុណ្ណោះ[50]។

**១.ការកំណត់ចំណែកមត៌ក**

មតកជន អាចធ្វើការកំណត់នូវចំណែកមតិកនៃសន្តតិជន តាមរយៈមតកសាសន៍បាន។ ឧទាហរណ៍ ៖ ករណីដែលជនដែលត្រូវសន្មតថាជាសន្តតិជន គឺជាប្រពន្ធ និង កូនពីរនាក់ ចំណែកមតិកតតាមផ្លូវច្បាប់គឺ ១ ភាគ ៣ ក្នុងម្នាក់ៗ ក៏ប៉ុន្តែ មតកជនអាចកំណត់ឲ្យអ្នកណាម្នាក់ ក្នុងចំណោមអ្នកទាំងនោះទទួលចំណែក ១ ភាគ ២ បាន។ ចំណែកមតិកនៃសន្តតិជនដែលមតកជន

[47] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៨៤។

[48] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ គន្ថីទី ៨-ទី ៩* (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០១០), ទំព័រទី ៨៤។

[49] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៨៥ កថាខណ្ឌទី ១។

[50] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៨៥ កថាខណ្ឌទី ២។

កំណត់នេះ ហៅថា "**ចំណែកមត៌កតាមការកំណត់**"។ ម្យ៉ាងទៀត មតកជនអាចបង្ហាញឆន្ទៈផ្សេងពីបញ្ញត្តិនៃមាត្រា ១១៦៣ នៃក្រមរដ្ឋប្បវេណី ដែលចែងអំពីចំណែកមតិករបស់អ្នកទទួលផលប្រយោជន៍ពិសេសបាន។ ប៉ុន្តែ ការកំណត់ចំណែកមតិកដែលបំពានភាគបម្រុង ត្រូវអនុលោមតាមបញ្ញតិស្តីពីភាគបម្រុង។

បើមតកជនបានកំណត់ចំណែកមតិក ចំពោះសន្តតិជនតែម្នាក់ ឬ ច្រើននាក់ ក្នុងចំណោមសន្តតិជនទាំងអស់ ចំណែកមតិករបស់សហសន្តតិជនផ្សេងទៀត ត្រូវកំណត់ដោយយោងតាមបញ្ញត្តិស្តីពីការសម្រួលចំណែកមតិកនៃក្រមរដ្ឋប្បវេណី[51]។

## ២.ការកំណត់នូវវិធីបែងចែកមត៌ក

ដោយឡែកចំពោះការកំណត់វិធីបែងចែកមតិកវិញ មតកជនអាចកំណត់តាមរយៈលិខិតមតកសាសន៍ ឬ អាចប្រគល់អាណត្តិឲ្យតតិយជនកំណត់វិធីនោះ ឬ អាចហាមឃាត់មិនឲ្យបែងចែកមតិកបាន នៅក្នុងអំឡុងពេលដែលមិនលើសពី ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលសន្តតិកម្មត្រូវបានចាប់ផ្តើមបាន[52]។

- **មតកជន កំណត់នូវវិធីបែងចែកមត៌ក**

មតកជន អាចកំណត់នូវវិធីបែងចែកមតិកបាន។ ឧទាហរណ៍ ៖ សន្តតិជន A ស្នងដី a, ឲ្យ B ស្នងដី b, ឲ្យ C ស្នងប្រាក់ ឲ្យបានប្រហាក់ប្រហែលនឹងចំណែកមតិកដែលកំណត់ដោយច្បាប់បាន។ ទោះបីជាសហសន្តតិជន A B និង C ត្រូវទទួលសន្តតិកម្មតាមផ្លូវច្បាប់ ១ ភាគ ៣ ម្នាក់ក៏ដោយ មតកជនអាចកំណត់ផ្សេងពីនោះក៏បានដែរ។

- **មតកជន ប្រគល់អាណត្តិឲ្យតតិយជនកំណត់វិធីបែងចែកមត៌ក**

មតកជន អាចប្រគល់អាណត្តិឲ្យតតិយជនកំណត់វិធីបែងចែកមតិក។ ឧទាហរណ៍ ៖ ក្នុងករណីដែលកូនមិនទាន់គ្រប់អាយុជានីតិជន ការប្រគល់អាណត្តិឲ្យឪពុកមារបស់សន្តតិជន ធ្វើការកំណត់បែងចែកមតិក។ ប៉ុន្តែ មិនអនុញ្ញាតឲ្យប្រគល់អាណត្តិ ឲ្យសន្តតិជនណាមួយបានទេ មានតែតតិយជនប៉ុណ្ណោះ។

- **មតកជន ហាមឃាត់មិនឲ្យបែងចែកមត៌កក្នុងអំឡុងពេលកំណត់មួយ**

ម្យ៉ាងវិញទៀត មតកជនអាចហាមឃាត់មិនឲ្យបែងចែកមតិកក្នុងអំឡុងពេលមួយ ដែលមិនលើសពី ៥ ឆ្នាំបានចាប់ពីពេលដែលចាប់ផ្តើមសន្តតិកម្ម។ មូលហេតុដែលអំឡុងពេលនេះត្រូវ

[51] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៨២។

[52] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៨៣។

កំណត់ត្រឹម ៥ ឆ្នាំ ដោយសារតែដើម្បីតម្រូវទៅនឹងបញ្ញត្តិស្តីពីការបែងចែកវត្ថុកម្មសិទ្ធិអវិភាគ នៃក្រមរដ្ឋប្បវេណី, មាត្រា ២១១ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២[53]។

**គ.ការកំណត់នូវអ្នកប្រតិបត្តិមតកសាសន៍**

ម្ចាស់បណ្តាំអាចកំណត់អ្នកប្រតិបត្តិមតកសាសន៍ម្នាក់ ឬ ច្រើននាក់ ឬ អាចប្រគល់អាណត្តិឲ្យតតិយជនកំណត់អ្នកប្រតិបត្តិនោះ តាមមតកសាសន៍បាន[54]។ មតកជនអាចចាត់តាំងសហសន្តតិជនណាម្នាក់ធ្វើជាអ្នកប្រតិបត្តិមតកសាសន៍ក៏បាន ជាពិសេស ក្នុងករណីដែលបានធ្វើមតកសាសន៍កំណត់ឲ្យសហសន្តតិជនណាម្នាក់ទទួលសន្តតិកម្មនូវមត៌កទាំងអស់ [55] ។ ចំពោះនីតិវិធីនៃការកំណត់អ្នកប្រតិបត្តិមតកសាសន៍ និងតួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍នឹងបកស្រាយលំអិតនៅក្នុង **ផ្នែកទី ២** ស្តីពីនីតិវិធីនៃការគ្រប់គ្រងមត៌កនៃ **ជំពូកទី ២** ។

**ឃ.ចំណុចផ្សេងទៀតនៃមតកសាសន៍**

ក្រៅពីចែងនូវចំណុចទាំងឡាយដូចបានរៀបរាប់ខាងលើ មតកជនអាចធ្វើការផ្តល់ជាដំបូន្មាន ឬ យោបល់ដល់សន្តតិជន ដើម្បីឲ្យមានភាពសុខដុមរមនានៅក្នុងក្រុមគ្រួសារ និង អាចកំណត់ចំណុចផ្សេងៗទៀតតាមចិត្តរបស់មតកជន[56]។

**កថាខណ្ឌទី ៣ ៖ ការលុបចោលនូវមតកសាសន៍**

ម្ចាស់បណ្តាំ អាចលុបចោលនូវមតកសាសន៍ មួយភាគ ឬ ទាំងមូល នៅពេលណាក៏បាន មានន័យថា ក្រោយពីបានធ្វើមតកសាសន៍រហូតដល់មុនពេលទទួលមរណភាព ម្ចាស់បណ្តាំអាចលុបចោលនូវមតកសាសន៍របស់ខ្លួនពេលណាក៏បានដែរ[57]។

ការលុបចោលមតកសាសន៍ បែងចែកជា ៣ (បី) ប្រភេទ ៖

- ការលុបចោលដោយទម្រង់មតកសាសន៍
- ការលុបចោល ដោយការចាត់ចែងនាពេលនៅរស់ និង
- ការលុបចោល ដោយការបដិសេធលិខិតមតកសាសន៍។

[53] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ គន្ថីទី ៨-ទី ៩* (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០១០), ទំព័រទី ៤៧។

[54] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៨៦។

[55] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ គន្ថីទី ៨-ទី ៩* (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០១០), ទំព័រទី ៥០។

[56] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៨៧។

[57] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៨៨។

**ក.ការលុបចោលឧទ្រង់ដោយមតកសាសន៍**

ម្ចាស់បណ្តាំ អាចលុបចោលនូវមតកសាសន៍ មួយភាគ ឬ ទាំងមូលបានតាមទម្រង់នៃមតកសាសន៍។ ទោះបីជាមតកសាសន៍នោះ ជាមតកសាសន៍ដោយលិខិតយថាភូតក៏ដោយ ក៏គេអាចលុបចោលនូវមតកសាសន៍នោះមួយភាគ ឬ ទាំងមូល តាមទម្រង់មតកសាសន៍ដោយលិខិតឯកជនក៏បាន ឬ តាមមតកសាសន៍របស់ជនដែលកំពុងតែជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិតក៏បានដែរ។

ដើម្បីលុបចោលនូវមតកសាសន៍មុន ដោយទម្រង់នៃមតកសាសន៍ គឺត្រូវធ្វើមតកសាសន៍ថ្មីមួយទៀតតាមវិធីធ្វើមតកសាសន៍ ដោយប្រើវិធីពីរ ៖

- ទីមួយ គឺសរសេរក្នុងមតកសាសន៍ថ្មីបញ្ជាក់ឲ្យបានច្បាស់អំពីការលុបចោល (ឧទាហរណ៍ ៖ "លុបចោលនូវមតកសាសន៍ ដែលចុះនាថ្ងៃទី ... ខែ ... ឆ្នាំ... ទាំងស្រុង")
- ទីពីរ គឺធ្វើមតកសាសន៍ក្រោយមានខ្លឹមសារផ្ទុយនឹងមតកសាសន៍មុន[58]។

**ខ.ការលុបចោលដោយការចាត់ចែងនាពេលរស់នៅ**

បើម្ចាស់បណ្តាំបានធ្វើអនុប្បទាន ឬ បានធ្វើសកម្មភាពផ្សេងទៀត ចំពោះវត្ថុដែលជាកម្មវត្ថុនៃមតកសាសន៍នាពេលរស់នៅ ត្រូវចាត់ទុកថា ម្ចាស់បណ្តាំបានលុបចោលមតកសាសន៍ ចំពោះផ្នែកអនុប្បទាន ឬ សកម្មភាពផ្សេងនោះ[59]។

**គ.ការលុបចោល ដោយបដិសេធលិខិតមតកសាសន៍**

លិខិតមតកសាសន៍ គឺជាភស្តុតាងតែមួយគត់ ដែលអាចសរបញ្ជាក់ថា មតកជនធ្វើការបែងចែកមតកភិកយ៉ាងដូចម្តេច។ ប្រសិនបើម្ចាស់បណ្តាំបានបំផ្លាញលិខិតនោះដោយចេតនា ត្រូវចាត់ទុកថា សាមីខ្លួនបានលុបចោលមតកសាសន៍ត្រង់ផ្នែកដែលខ្លួនបានបំផ្លាញនោះ។ ម្យ៉ាងទៀត ក្នុងករណីដែលម្ចាស់បណ្តាំបានបំផ្លាញកម្មវត្ថុនៃមតកសាសន៍ ដោយចេតនា ក៏ត្រូវចាត់ទុកថា សាមីខ្លួនបានលុបចោលនូវមតកសាសន៍របស់ខ្លួន ដូចការចាត់ចែងវត្ថុនោះនៅពេលរស់ដែរ។ ក្នុងករណីដែលលិខិតមតកសាសន៍ ត្រូវបានបំផ្លាញដោយទង្វើរបស់តតិយជន ឬ ដោយប្រធានសក្តិ អានុភាពនៃការលុបចោល មិនកើតមានឡើយ ប៉ុន្តែ ប្រសិនបើលិខិតមតកសាសន៍នោះមើលមិន

[58] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ គន្ថីទី ៨-ទី ៩* (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០១០), ទំព័រទី ៥២។

[59] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៩០។

យល់ គ្មានវិធីអ្វីផ្សេងក្រៅពីចាត់ទុកថា ផ្នែកនៃមតកសាសន៍នោះគ្មានអានុភាព[60]។ បើសិនជាមតកសាសន៍ ត្រូវបានលុបចោលទាំងស្រុងតែម្តង ត្រូវចាត់ទុកថា មតកសាសន៍ពុំត្រូវបានបង្កើតឡើងតាំងពីដើមឡើយ។

ក្រោយពីបានសិក្សា **ជំពូកទី ១** ស្តីអំពី "**មតកសាសន៍ និងល័ក្ខខ័ណ្ឌសុពលភាពនៃមតកសាសន៍**" យើងសង្កេតឃើញថា ដើម្បីបង្កើតលិខិតមតកសាសន៍ឡើង ចាំបាច់ត្រូវតែបំពេញនូវល័ក្ខខ័ណ្ឌសុពលភាពទាំងឡាយដែលមានរៀបរាប់នៅក្នុង **ជំពូកទី ១** នេះ។ នៅពេលដែលមតកសាសន៍ត្រូវបានបង្កើតឡើងរួចរាល់ នោះទាមទារឲ្យអនុវត្តមតកសាសន៍ ប៉ុន្តែដើម្បីអនុវត្តមតកសាសន៍បាន លុះត្រាតែមតកសាសន៍នោះមានអានុភាពអនុវត្តជាមុនសិន។ ដូច្នេះ យើងនឹងធ្វើការសិក្សាពីអានុភាពនៃមតកសាសន៍ និង ការអនុវត្តមតកសាសន៍នៅក្នុង **ជំពូកទី ២** ជាបន្តបន្ទាប់។

[60] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ គន្ថីទី ៨-ទី ៩* (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០១០), ទំព័រទី ៥៤។

# ជំពូកទី ២
# នីតិវិធីក្នុងការប្រតិបត្តិមតកសាសន៍

មតកសាសន៍ត្រូវបានបង្កើតឡើង ដោយការធ្វើលិខិតមតកសាសន៍ដោយបំពេញល័ក្ខខ័ណ្ឌសុពលភាពទាំងឡាយ ដែលមានរៀបរាប់នៅក្នុង **ជំពូកទី ១** ខាងលើ។ ប៉ុន្តែជាគោលការណ៍ មតកសាសន៍មានអានុភាពក្នុងការអនុវត្ត គិតចាប់ពីពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព [61] ដោយសារតែ មតកសាសន៍ គឺជាឆន្ទៈចុងក្រោយរបស់ម្ចាស់បណ្តាំក្នុងការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនក្រោយពេលដែលខ្លួនទទួលមរណភាព។ ដូច្នេះ ការអនុវត្តមតកសាសន៍ត្រូវធ្វើឡើងក្រោយពេលដែលមតកជនទទួលមរណភាព។

នៅក្នុងករណីដែលមតកសាសន៍ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ បើល័ក្ខខ័ណ្ឌបង្អង់នោះត្រូវបានបំពេញនៅក្រោយពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ទ្រព្យសម្បត្តិនោះ ត្រូវបានធ្លាក់ទៅសន្តតិជនដែលនឹងត្រូវទទួលទ្រព្យសម្បត្តិនោះ ដោយប្រតិសកម្ម គិតចាប់តាំងពីពេលដែលមតកជននោះបានទទួលមរណភាព[62]។

ឧទាហរណ៍ ៖ មតកជនបានសរសេរបញ្ជាក់ថា មតកសាសន៍នឹងមានអានុភាពលុះត្រាតែសន្តតិជនរៀបអាពាហ៍ពិពាហ៍រួច ក្រោយពេលដែលមតកជនទទួលមរណភាព។ ដូច្នេះ ក្រោយពេលដែលមតកជនទទួលមរណភាព ដើម្បីឲ្យមតកសាសន៍មានអានុភាពបាន នោះទាមទារឲ្យសន្តតិជនរៀបអាពាហ៍ពិពាហ៍ជាមុនសិន។ ផ្ទុយទៅវិញ បើសន្តតិជនបានរៀបអាពាហ៍ពិពាហ៍មុនពេលមរណភាពរបស់មតកជន តើយើងត្រូវដោះស្រាយបញ្ហានេះយ៉ាងដូចម្តេច? ក្នុងករណីនេះ ប្រសិនបើសន្តតិជនបានរៀបអាពាហ៍ពិពាហ៍មុនពេលមតកជនទទួលមរណភាព មានន័យថាល័ក្ខខ័ណ្ឌបង្អង់នោះបានសម្រេចមុនពេលមតកជនទទួលមរណភាព ដូច្នេះ យើងអាចធ្វើការបកស្រាយថា មតកសាសន៍នោះគ្មានភ្ជាប់នឹងល័ក្ខខ័ណ្ឌបង្អង់ឡើយ ហើយអានុភាពនៃមតកសាសន៍នោះ នឹងកើតឡើងចាប់ពីពេលដែលមតកជនទទួលមរណភាព។

តើទ្រព្យសម្បត្តិធ្លាក់ទៅលើសន្តតិជន ដោយប្រតិសកម្ម គិតពីពេលមតកជនទទួលមរណភាពមានន័យយ៉ាងដូចម្តេច?

ជាទូទៅ ចាប់ពីពេលដែលមតកជនបានទទួលមរណភាព រហូតដល់ពេលដែលល័ក្ខខ័ណ្ឌបង្អង់ត្រូវបានបំពេញ ក្នុងអំឡុងពេលនេះមត៌កទាំងឡាយត្រូវស្ថិតនៅក្រោមស្ថានភាពកម្មសិទ្ធិ

[61] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៩៤ កថាខណ្ឌទី ១។
[62] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៩៥ កថាខណ្ឌទី ២។

អវិភាគរបស់សហសន្តតិជន ដោយសារតែទ្រព្យសម្បត្តិទាំងឡាយនោះពុំទាន់អាចធ្វើការបែងចែកតាមសមាមាត្រនៃចំណែកមតិកបាននៅឡើយ [63] ។ នៅពេលដែលល័ក្ខខ័ណ្ឌបង្អង់ត្រូវបានបំពេញ ទ្រព្យសម្បត្តិជាក់លាក់នោះ នឹងត្រូវធ្លាក់ទៅលើសហសន្តតិជនតាមការកំណត់ចំណែកមតិក ឬ តាមការកំណត់វិធីបែងចែកមតិកដូចមានចែងក្នុងលិខិតមតកសាសន៍។ ក្នុងករណីនេះ មានលក្ខណៈដូចគ្នានឹងអានុភាពប្រតិសកម្មនៃការបែងចែកមតក (**ក្រមរដ្ឋប្បវេណី, មាត្រា ១២៧៣**) ដែលចាត់ទុកថា កម្មសិទ្ធិនៃទ្រព្យសម្បត្តិបានធ្លាក់ទៅលើសន្តតិជនតាំងពីពេលមតកជនបានទទួលមរណភាព ទោះបីជាកម្មសិទ្ធិនៃទ្រព្យសម្បត្តិជាក់ស្តែង ទើបតែទទួលបានក្រោយពេលដែលល័ក្ខខ័ណ្ឌបង្អង់ទើបតែបំពេញក៏ដោយ ដើម្បីកុំឲ្យមានភាពផ្ទុយគ្នាជាមួយនឹងទ្រឹស្តីទូទៅចែងថា អានុភាពនៃមតកសាសន៍ត្រូវបានបង្កើតចាប់ពីពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព។

ដោយឡែកចំពោះការអនុវត្តមតកសាសន៍ គឺជាការចាំបាច់ដែលខានពុំបាន ក្នុងគោលបំណងដើម្បីសម្រេចនូវខ្លឹមសារនៃមតកសាសន៍ ឬ ដើម្បីសម្រេចនូវគោលបំណងចុងក្រោយរបស់មតកជន ក្រោយពេលដែលអានុភាពនៃមតកសាសន៍នោះបានកើតឡើង។ ដើម្បីអនុវត្តមតកសាសន៍ ត្រូវឆ្លងកាត់ ៣ ដំណាក់កាល ៖ ដំណាក់កាលទី ១ នីតិវិធីត្រៀមដើម្បីអនុវត្តមតកសាសន៍ (**ផ្នែកទី ១**) ដំណាក់កាលទី ២ គឺ នីតីវិធីនៃការគ្រប់គ្រងមតិក (**ផ្នែកទី ២**) និង ដំណាក់កាលទី ៣ គឺ នីតិវិធីនៃការបែងចែកមតិក (**ផ្នែកទី ៣**) ។ យើងនឹងធ្វើការសិក្សាពីការអនុវត្តមតកសាសន៍ តាមដំណាក់កាលនីមួយៗដូចតទៅ ៖

## ផ្នែកទី ១ ៖ នីតិវិធីត្រៀមដើម្បីអនុវត្តមតកសាសន៍

### កថាខណ្ឌទី ១ ៖ ការពិនិត្យបញ្ជាក់ និង ការបើកលិខិតមតកសាសន៍

ចំពោះមតកសាសន៍ដែលបានធ្វើឡើងតាមទម្រង់នៃក្រមរដ្ឋប្បវេណីនេះ លើកលែងមតកសាសន៍តាមលិខិតយថាភូត ចាំបាច់ត្រូវឆ្លងកាត់នីតិវិធីត្រួតពិនិត្យមតកសាសន៍ មុនពេលដែលយកមតកសាសន៍នោះមកអនុវត្ត។ អ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ ត្រូវដាក់ពាក្យសុំការបញ្ជាក់លិខិតនោះដោយភ្ជាប់លិខិតមតកសាសន៍នោះជូនទៅតុលាការ ដោយគ្មានការយឺតយ៉ាវក្រោយពេលមតកជនទទួលមរណភាព។ ក្នុងករណីដែលគ្មានអ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ ពោលគឺក្រោយពេលដែលសន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍បានរកឃើញលិខិតមតកសាសន៍ បន្ទាប់ពីមតកជនទទួលមរណភាព នោះជនដែលបានរកឃើញលិខិតមតកសាសន៍នោះ

[63] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៨៨។

ត្រូវដាក់ពាក្យសុំការបញ្ជាក់ពីតុលាការ ដោយគ្មានការយឺតយ៉ាវឡើយ។

តើនីតិវិធីនៃការត្រួតពិនិត្យមតកសាសន៍ដោយតុលាការនេះ ធ្វើឡើងដើម្បីអ្វី?

នីតិវិធីនៃការត្រួតពិនិត្យមតកសាសន៍ដោយតុលាការនេះ ធ្វើឡើងដើម្បីឲ្យជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍បានដឹងឮអំពីលិខិតមតកសាសន៍ និងធ្វើឡើងដើម្បីឲ្យតុលាការបញ្ជាក់ថាលិខិតមតកសាសន៍នោះពិតជាលិខិតមតកសាសន៍ដែលត្រឹមត្រូវ ជៀសវាងកុំឲ្យមានការលួចកែប្រែក្រោយពេលដែលពិនិត្យបញ្ជាក់នេះ។ ដូច្នេះ នីតិវិធីនៃការត្រួតពិនិត្យមតកសាសន៍នេះ ពិតជាមានសារៈសំខាន់ណាស់។

លិខិតមតកសាសន៍ ជាពិសេសលិខិតដែលបិទដោយប្រថាប់ត្រា ត្រូវបើកនៅក្នុងនីតិវិធីនៃការពិនិត្យបញ្ជាក់នៅតុលាការ ដើម្បីការពារកុំឲ្យមានការលួចកែប្រែលើលិខិតមតកសាសន៍នោះក្រោមវត្តមានរបស់អ្នកសង្កេតការណ៍ជាសន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍។ ក្នុងករណីដែលលិខិតមតកសាសន៍ ត្រូវបានបើកនៅក្រៅតុលាការ បុគ្គលដែលបានបើកលិខិតមតកសាសន៍នោះនឹងត្រូវពិន័យស៊ីវិលជាប្រាក់ មិនលើសពី ១.០០០.០០០ (មួយលាន) រៀលឡើយ។ ប៉ុន្តែទោះបីជាលិខិតមតកសាសន៍នោះត្រូវបានបើកនៅក្រៅនីតិវិធីពិនិត្យបញ្ជាក់របស់តុលាការក៏ដោយក៏លិខិតមតកសាសន៍នោះមិនអាចក្លាយជាមោឃៈបានឡើយ[64]។

### កថាខណ្ឌទី ២ ៖ ការយល់ព្រម និង ការបោះបង់សន្តតិកម្ម

សន្តតិជនអាចធ្វើការយល់ព្រម ឬ បោះបង់សន្តតិកម្មបាន។ សន្តតិកម្មអាចត្រូវបានបោះបង់ដោយមានមូលហេតុផ្សេងៗ ជាពិសេសក្នុងករណីដែលមតកជនមានទ្រព្យសម្បត្តិអកម្មច្រើនជាងទ្រព្យសម្បត្តិសកម្ម ដែលជាហេតុអាចឲ្យសន្តតិជនធនក្ស័យបាន។

តើសន្តតិជនអាចធ្វើការយល់ព្រម ឬ ការបោះបង់សន្តតិកម្មបាននៅពេលណា? ហើយការយល់ព្រម និង ការបោះបង់សន្តតិកម្ម មាននីតិវិធីយ៉ាងដូចម្តេចខ្លះ?

#### ក.អំឡុងពេលនៃការយល់ព្រម ឬ បោះបង់

សន្តតិជនត្រូវធ្វើការយល់ព្រម ឬ បោះបង់សន្តតិកម្មនៅក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើម។ ប៉ុន្តែមុនអំឡុងពេល ៣ (បី) ខែបានកន្លងផុត ប្រសិនបើខ្លួនមានហេតុផលសមរម្យ សន្តតិជនអាចដាក់ពាក្យសុំទៅតុលាការឲ្យពន្យារពេលនៃការយល់ព្រម ឬ បោះបង់សន្តតិកម្មបាន។ មុនពេលដែលខ្លួនធ្វើការយល់ព្រម ឬ បោះបង់សន្តតិកម្មបាន សន្តតិជនអាចធ្វើការស្រាវជ្រាវអំពីមតិកបាន ព្រោះនៅក្នុងករណីខ្លះ មតកជនអាច

[64] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២១៣។

បន្សល់ទុកនូវកាតព្វកិច្ចច្រើនពេក ជាហេតុធ្វើឲ្យសន្តតិជន អាចធនក្ស័យបាន[65]។

**ខ.ការយល់ព្រមទទួលសន្តតិកម្ម**

សន្តតិជន អាចធ្វើការយល់ព្រមទទួលសន្តតិកម្មទាំងស្រុង ឬ យល់ព្រមទទួលសន្តតិកម្មដោយកម្រិតបាន។ បើសន្តតិជនបានយល់ព្រមទទួលសន្តតិកម្មទាំងស្រុង នោះសន្តតិជននោះត្រូវទទួលបន្តដោយគ្មានកម្រិតនូវសិទ្ធិ និង កាតព្វកិច្ចរបស់មតកជន[66] ក៏ប៉ុន្តែប្រសិនបើសន្តតិជនធ្វើការយល់ព្រមទទួលសន្តតិកម្មដោយមានកម្រិត នោះមានន័យថាសន្តតិជននោះយល់ព្រម ដោយបម្រុងទុកនូវសំណងកាតព្វកិច្ច ត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួលតាមរយៈសន្តតិកម្មតែប៉ុណ្ណោះ។ ក្នុងករណីនេះដែរ ក្នុងករណីសន្តតិជនមានច្រើននាក់ ការយល់ព្រមដោយកម្រិតអាចធ្វើទៅបាន លុះត្រាតែសន្តតិជនទាំងអស់មានការយល់ព្រមរួមគ្នា[67]។ មូលហេតុដែលតម្រូវឲ្យមានយល់ព្រមរួមគ្នានេះដោយសារតែ នៅពេលជម្រះបញ្ជីលើទ្រព្យសម្បត្តិរបស់មតកជនក្នុងការសងចំពោះម្ចាស់បំណុលរបស់មតកជន សន្តតិជនទាំងអស់ត្រូវមានការឯកភាពក្នុងការសងនោះ ។ ប្រសិនបើមានតែសន្តតិជនខ្លះបានយល់ព្រម សន្តតិជនខ្លះមិនយល់ព្រម នោះនីតិវិធីនៃការជម្រះបញ្ជីនឹងគ្មានដំណើរការល្អនោះទេ[68]។

ក្នុងករណីដែលសន្តតិជនបានយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតកជន ពុំអាចទាមទារឲ្យសន្តតិជនទទួលខុសត្រូវបំណុល ចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជននោះបានឡើយ[69]។ ដើម្បីធ្វើការយល់ព្រមទទួលសន្តតិកម្មដោយកម្រិត ចាំបាច់ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌ ហើយត្រូវដាក់ពាក្យសុំអំពីការយល់ព្រមដោយកម្រិតនោះទៅតុលាការក្នុងអំឡុងពេល ៣ (បី) ខែនៃអំឡុងពេលនៃការយល់ព្រម ឬ បោះបង់សន្តតិកម្មនោះ[70]។

ចំណុចគួរពិចារណាគឺ តាមរយៈការបកស្រាយខាងលើ ជាទូទៅ នៅក្នុងមតកសាសន៍ មតកជនបានចែងពីទ្រព្យសម្បត្តិជាក់លាក់ដើម្បីសងបំណុលទៅម្ចាស់បំណុល នោះសន្តតិជនមិនចាំបាច់បារម្ភថាខ្លួនអាចនឹងត្រូវតម្រូវឲ្យយកទ្រព្យសម្បត្តិផ្ទាល់ខ្លួន មកសងម្ចាស់បំណុលរបស់មតក

---

[65] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៤៨។

[66] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៥៤។

[67] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៥៦។

[68] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ គន្លឹះទី ៨-ទី ៩* (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០១០), ទំព័រទី ១១៧។

[69] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៥៨។

[70] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៥៧។

ជនឡើយ។ ដូច្នេះ ជាទូទៅ សន្តតិជនមិនចាំបាច់ពិចារណាដល់ការយល់ព្រមដោយកម្រិតឡើយ គ្រាន់តែឆ្លើយថាយល់ព្រមជាការស្រេច។ បញ្ញត្តិនៃការយល់ព្រមដោយកម្រិតនេះ ចែងឡើងក្នុងករណីការពារក្រែងមតកជនមិនបានគិតគូរដល់បញ្ហានេះតែប៉ុណ្ណោះ។

**គ.ការបោះបង់សន្តតិកម្ម**

សន្តតិជនដែលមានបំណងបោះបង់សន្តតិកម្ម ត្រូវដាក់ពាក្យសុំការបោះបង់សន្តតិកម្មនោះទៅតុលាការក្នុងអំឡុងពេល ៣ (បី) ខែនៃការយល់ព្រម ឬ បោះបង់សន្តតិកម្ម។ នៅពេលដែលសន្តតិជនបានបោះបង់សន្តតិកម្ម ត្រូវចាត់ទុកថា បុគ្គលនោះមិនមែនជាសន្តតិជនចំពោះសន្តតិកម្មនោះ តាំងពីដំបូងមកម្ល៉េះ[71]។

ក្រោយពេលដែលនីតិវិធីត្រៀមដើម្បីអនុវត្តមតកសាសន៍បានបំពេញ លិខិតមតកសាសន៍នោះនឹងត្រូវអនុវត្ត។ ប៉ុន្តែ មុននឹងឈានដល់ដំណាក់កាលនៃការបែងចែកមត៌កតាមលិខិតមតកសាសន៍ ត្រូវឆ្លងកាត់នីតិវិធីមួយគឺ នីតិវិធីនៃការគ្រប់គ្រងមត៌ក (**ផ្នែកទី ២**)។ មូលហេតុដែលមត៌កពុំទាន់អាចធ្វើការបែងចែកភ្លាមបន្ទាប់ពីបើកលិខិតមតកសាសន៍ ដោយសារតែមានការបារម្ភក្នុងការអនុវត្តខុសពីលិខិតមតកសាសន៍ ដូច្នេះ តម្រូវឲ្យមានអ្នកប្រតិបត្តិមតកសាសន៍យ៉ាងហោចណាស់មួយនាក់ ដើម្បីអនុវត្តលិខិតមតកសាសន៍។

## ផ្នែកទី ២ ៖ នីតិវិធីនៃការគ្រប់គ្រងមត៌ក

អ្នកប្រតិបត្តិមតកសាសន៍ គឺជាអ្នកធ្វើការគ្រប់គ្រងមត៌ក មុនពេលដែលធ្វើការបែងចែកទ្រព្យសម្បត្តិទៅឲ្យសន្តតិជនតាមចំណែករៀងៗខ្លួន។ តើអ្នកប្រតិបត្តិមតកសាសន៍ត្រូវបានជ្រើសតាំងយ៉ាងដូចម្តេច ហើយអ្នកប្រតិបត្តិមតកសាសន៍មានសិទ្ធិ ឋានៈ និង តួនាទីអ្វីខ្លះនៅក្នុងនីតិវិធីនៃការគ្រប់គ្រងមត៌កនេះ? លើសពីនេះទៅទៀត តើនៅក្នុងនីតិវិធីនៃការគ្រប់គ្រងមត៌កនេះមានដំណើរការយ៉ាងដូចម្តេចខ្លះ?

ដើម្បីស្រាយនូវចម្ងល់បញ្ហាខាងលើនេះ យើងនឹងធ្វើការសិក្សាដូចតទៅ ៖

### កថាខណ្ឌទី ១ ៖ អ្នកដែលទទួលអាណត្តិពីមតកជន

តាមរយៈការបង្ហាញនៅក្នុងចំណុចដែលត្រូវសរសេរក្នុងមតកសាសន៍ក្នុង **ជំពូកទី ១** ខាងលើ ម្ចាស់បណ្តាំអាចកំណត់អ្នកប្រតិបត្តិមតកសាសន៍ម្នាក់ ឬ ច្រើននាក់ ឬ អាចប្រគល់អាណត្តិឲ្យតតិយជនជាអ្នកកំណត់អ្នកប្រតិបត្តិមតកសាសន៍ តាមរយៈខ្លឹមសារនៃលិខិតមតកសាសន៍បាន។

[71] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៦០ និង មាត្រា ១២៦១។

ប្រសិនបើនៅក្នុងលិខិតមតកសាសន៍ ម្ចាស់បណ្តាំបានសរសេរប្រគល់អាណត្តិឲ្យតតិយជនធ្វើការកំណត់អ្នកប្រតិបត្តិមតកសាសន៍ ជនដែលបានទទួលអាណត្តិនោះ ត្រូវធ្វើការកំណត់អ្នកប្រតិបត្តិមតកសាសន៍ និង ធ្វើការជូនដំណឹងទៅសន្តតិជនឲ្យបានដឹងអំពីការកំណត់អ្នកប្រតិបត្តិមតកសាសន៍នោះ ដោយគ្មានការយឺតយ៉ាវ។ ក្នុងករណីនេះដែរ ប្រសិនបើម្ចាស់បណ្តាំមិនបានធ្វើការហាមឃាត់នោះទេ ជនដែលទទួលអាណត្តិនោះ អាចកំណត់យកខ្លួនឯងធ្វើជាអ្នកប្រតិបត្តិមតកសាសន៍ក៏បានដែរ។

ទោះបីតតិយជននោះ ទទួលអាណត្តិពីម្ចាស់បណ្តាំក្នុងការកំណត់អ្នកប្រតិបត្តិមតកសាសន៍តាមរយៈលិខិតមតកសាសន៍ក៏ដោយ មិនមែនមានន័យថា ជនដែលទទួលអាណត្តិនោះមានករណីកិច្ចត្រូវតែទទួលមុខងារនេះដោយស្វ័យប្រវត្តិនោះទេ ពោលគឺ ជនដែលទទួលអាណត្តិនោះ អាចធ្វើការបដិសេធមិនទទួលអាណត្តិនេះក៏បានដែរ។ ក្នុងករណីដែលបដិសេធមិនទទួលអាណត្តិនេះ ជនដែលទទួលអាណត្តិនេះ ត្រូវធ្វើការជូនដំណឹងអំពីការលាលែងពីអាណត្តិរបស់ខ្លួន ឲ្យទៅសន្តតិជនបានដឹងៗ ដោយគ្មានយឺតយ៉ាវឡើយ[72]។

ក្នុងករណី ជនដែលត្រូវបានប្រគល់អាណត្តិឲ្យកំណត់អ្នកប្រតិបត្តិមតកសាសន៍ពុំបានកំណត់អ្នកប្រតិបត្តិមតកសាសន៍ឲ្យបានឆាប់រហ័សដូចបានកំណត់ខាងលើនោះទេ ត្រូវចាត់ទុកថា ជនដែលត្រូវបានប្រគល់អាណត្តិឲ្យកំណត់អ្នកប្រតិបត្តិមតកសាសន៍នោះ បានលាឈប់ពីអាណត្តិរបស់ខ្លួន[73]។

## កថាខណ្ឌទី ២ ៖ ការកំណត់អ្នកប្រតិបត្តិមតកសាសន៍

### ក.ការកំណត់អ្នកប្រតិបត្តិមតកសាសន៍ដោយអ្នកទទួលអាណត្តិពីមតកជន

តាមការបង្ហាញក្នុង **កថាខណ្ឌទី១** ខាងលើ អ្នកដែលទទួលអាណត្តិពីម្ចាស់បណ្តាំ ត្រូវកំណត់អ្នកប្រតិបត្តិមតកសាសន៍។ តើបុគ្គលគ្រប់ៗរូប មានលក្ខណសម្បត្តិអាចក្លាយជាអ្នកប្រតិបត្តិមតកសាសន៍ ឬ យ៉ាងណា?

ជនគ្រប់ៗរូប លើកលែងតែជនដែលនៅក្រោមអាណាព្យាបាលទូទៅ ជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភ អនីតិជន និង ជនដែលធនក្ស័យ ពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងការធ្វើជាអ្នកប្រតិបត្តិមតកសាសន៍ឡើយ[74]។ មូលហេតុបណ្តាលមកពី អ្នកប្រតិបត្តិមតកសាសន៍ គឺជាអ្នកធ្វើសកម្មភាពគតិយុត្តនៅពេលអនុវត្តមតកសាសន៍ ហេតុនេះហើយ ការដែលកំណត់ថា ជនដែលត្រូវ

[72] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២១៥។
[73] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២១៦ កថាខណ្ឌទី ២។
[74] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២១៧។

បានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពដូចជា ជនដែលនៅក្រោមអាណាព្យាបាលទូទៅ ជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភ អនីតិជន និង ជនដែលធនក្ស័យ មិនមានលក្ខណសម្បត្តិធ្វើជាអ្នកប្រតិបត្តិមតកសាសន៍នេះ គឺជាការសមរម្យ។

ចំណុចដែលគួរពិចារណា គឺ អ្នកប្រតិបត្តិមតកសាសន៍ មានភារកិច្ចធ្វើសកម្មភាពគតិយុត្តជាច្រើន ដូច្នេះ គួរគប្បីជ្រើសរើសយកអ្នកដែលចេះច្បាប់ធ្វើជាអ្នកប្រតិបត្តិមតកសាសន៍ទើបល្អ។

ក្រោយពេលដែលកំណត់អ្នកប្រតិបត្តិមតកសាសន៍រួចហើយ ប៉ុន្តែអ្នកដែលត្រូវកំណត់ជាអ្នកប្រតិបត្តិមតកសាសន៍នោះពុំទាន់ឆ្លើយថាយល់ព្រម ឬ មិនយល់ព្រមកាន់មុខងារនោះទេ សន្តតិជន ឬ ជនដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍ផ្សេងទៀតក្នុងសន្តតិកម្មអាចកំណត់ពេលសមរម្យ ដើម្បីឲ្យជនដែលត្រូវបានកំណត់ជាអ្នកប្រតិបត្តិមតកសាសន៍ធ្វើការឆ្លើយបញ្ជាក់ឲ្យបានច្បាស់លាស់ថាខ្លួនយល់ព្រម ឬ មិនយល់ព្រមកាន់មុខងារជាអ្នកប្រតិបត្តិមតកសាសន៍នេះ។ ក្នុងករណីជនដែលត្រូវបានកំណត់ជាអ្នកប្រតិបត្តិមតកសាសន៍ មិនបានឆ្លើយបញ្ជាក់ច្បាស់លាស់ក្នុងអំឡុងពេលដែលបានកំណត់នោះទេ ត្រូវចាត់ទុកថាជននោះបានលាឈប់ពីការងារនេះ[75]។ ប៉ុន្តែប្រសិនបើជនដែលត្រូវកំណត់ជាអ្នកប្រតិបត្តិមតកសាសន៍បានយល់ព្រមកាន់មុខងារហើយ ជននោះត្រូវអនុវត្តភារកិច្ចជាអ្នកប្រតិបត្តិមតកសាសន៍នោះភ្លាមៗ[76]។

**ខ.ការកំណត់អ្នកប្រតិបត្តិមតកសាសន៍ដោយតុលាការ**

ប្រសិនបើគ្មានអ្នកប្រតិបត្តិមតកសាសន៍ ដោយមូលហេតុមតកជនមិនបានកំណត់ពីបញ្ហានេះនៅក្នុងមតកសាសន៍ ឬ ក្នុងករណីដែលអ្នកដែលត្រូវកំណត់ជាអ្នកប្រតិបត្តិមតកសាសន៍នោះមិនព្រមកាន់មុខងារ ឬ ក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍បានកាន់មុខងារហើយ តែក្រោយមកបានទទួលការអនុញ្ញាតពីតុលាការឲ្យលាឈប់ពីមុខងារ (មានការបកស្រាយនៅកថាខណ្ឌទី៥) ឬ មានមូលហេតុនៃការបាត់បង់លក្ខណសម្បត្តិជាអ្នកប្រតិបត្តិមតកសាសន៍ ឬ អ្នកប្រតិបត្តិមតកសាសន៍បានទទួលមរណភាព នោះតុលាការអាចធ្វើការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ តាមការទាមទាររបស់សន្តតិជន ឬ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍បាន[77]។

[75] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២១៦ កថាខណ្ឌទី ១។
[76] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២១៥។
[77] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២១៨។

## កថាខណ្ឌទី ៣ ៖ សិទ្ធិអំណាច ឋានៈ និង តួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍

### ក.សិទ្ធិអំណាចនៃអ្នកប្រតិបត្តិមតកសាសន៍ក្នុងសន្តតិកម្ម

អ្នកប្រតិបត្តិមតកសាសន៍ មានសិទ្ធិ និង ករណីយកិច្ចក្នុងការគ្រប់គ្រងមតិក ព្រមទាំងមានសិទ្ធិក្នុងការធ្វើសកម្មភាពផ្សេងៗទៀតដែលចាំបាច់ ដើម្បីប្រតិបត្តិមតកសាសន៍[78]។

ក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍មានច្រើននាក់ នោះការអនុវត្តភារកិច្ចត្រូវសម្រេចដោយសម្លេងលើសពីពាក់កណ្តាល ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងលិខិតមតកសាសន៍ ត្រូវអនុវត្តតាមឆន្ទៈរបស់មតកជននោះ (**ក្រមរដ្ឋប្បវេណី, មាត្រា ១១២៥**)។

ឧទាហរណ៍ ៖ ក្នុងលិខិតមតកសាសន៍បានចែងថា ប្រសិនបើមានការខ្វែងគំនិតគ្នារវាងអ្នកប្រតិបត្តិមតកសាសន៍ច្រើននាក់ ត្រូវស្តាប់យោបល់របស់បុគ្គលពិសេសណាមួយ នោះត្រូវគោរពតាមឆន្ទៈនោះ ដោយមិនចាំបាច់សម្រេចតាមសម្លេងលើសពីពាក់កណ្តាលឡើយ។

### ខ.ឋានៈរបស់អ្នកប្រតិបត្តិមតកសាសន៍ក្នុងសន្តតិកម្ម

អ្នកប្រតិបត្តិមតកសាសន៍មានសិទ្ធិ និងករណីយកិច្ចក្នុងការគ្រប់គ្រងមតិក ប៉ុន្តែប្រធាននៃសិទ្ធិ និង ករណីកិច្ចនៃមតិក គឺសន្តតិជននៃមតកជនដែលទទួលមរណភាព។ អ្នកប្រតិបត្តិមតកសាសន៍មានឋានៈត្រឹមជាអ្នកធ្វើសកម្មភាព នៅក្នុងនាមជាអ្នកប្រតិបត្តិមតកសាសន៍ ចំពោះមតិកដែលខ្លួនត្រូវប្រតិបត្តិតែប៉ុណ្ណោះ។ សកម្មភាពដែលអ្នកប្រតិបត្តិមតកសាសន៍បានធ្វើក្នុងមុខនាទីរបស់ខ្លួន ត្រូវមានអានុភាពចំពោះសន្តតិជនដែលជាប្រធាននៃសិទ្ធិ និងករណីកិច្ចនៃមតិក[79]។

ទោះបីជាសន្តតិជនជាប្រធាននៃសិទ្ធិ និង ករណីកិច្ចនៃមតិកក៏ដោយ ក្នុងករណីដែលមានវត្តមានរបស់អ្នកប្រតិបត្តិមតកសាសន៍ សន្តតិជនពុំអាចធ្វើការចាត់ចែង ឬ ធ្វើសកម្មភាពផ្សេងៗដែលនាំឲ្យរារាំងដល់ការប្រតិបត្តិមតកសាសន៍របស់អ្នកប្រតិបត្តិមតកសាសន៍ឡើយ មូលហេតុដោយសារតែ ប្រសិនបើសន្តតិជន និង អ្នកប្រតិបត្តិមតកសាសន៍មានសិទ្ធិអំណាចស្មើគ្នាក្នុងការគ្រប់គ្រងចាត់ចែងមតិក និង ធ្វើសកម្មភាពផ្សេងៗ នោះអាចនឹងមានការអនុវត្តផ្សេងគ្នាក្នុងពេលជាមួយគ្នា ហើយធ្វើឲ្យអ្នកប្រតិបត្តិមតកសាសន៍មិនអាចបំពេញមុខនាទីរបស់ខ្លួនបានពេញលេញឡើយ[80]។

---

[78] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១២០។

[79] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១២៣។

[80] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ គន្លឹះទី ៨-ទី ៩* (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០១០), ទំព័រទី ៨១។

ដូច្នេះ ក្នុងករណីមានអ្នកប្រតិបត្តិមតកសាសន៍ សិទ្ធិ និងករណីកិច្ចរបស់សន្តតិជនក្នុងការចាត់ចែងមតិកត្រូវបានកម្រិត។

### គ.តួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍ក្នុងសន្តតិកម្ម

#### ១.តួនាទីក្នុងការគ្រប់គ្រងមត៌ក

តាមរយៈការបកស្រាយខាងលើ អ្នកប្រតិបត្តិមតកសាសន៍មានសិទ្ធិក្នុងការគ្រប់គ្រងមតិក ដូច្នេះអ្នកប្រតិបត្តិមតកសាសន៍ត្រូវបំពេញតួនាទីជាអ្នកគ្រប់គ្រងមតិក។ បើបានកាន់មុខងារជាអ្នកប្រតិបត្តិមតកសាសន៍ហើយ អ្នកប្រតិបត្តិមតកសាសន៍នោះត្រូវធ្វើការគ្រប់គ្រងមតិកភ្លាម[81]។

ប្រសិនបើខ្លឹមសារនៃមតកសាសន៍ បានចែងទាក់ទងតែចំពោះទ្រព្យសម្បត្តិដែលកំណត់ជាក់លាក់ មិនមែនចែងអំពីការចាត់ចែងនូវទ្រព្យសម្បត្តិទាំងអស់នោះទេ នោះអ្នកប្រតិបត្តិមតកសាសន៍ មានសិទ្ធិ និង ករណីកិច្ចគ្រប់គ្រងបានតែទៅលើទ្រព្យសម្បត្តិដែលបានកំណត់ជាក់លាក់នោះតែប៉ុណ្ណោះ[82]។ ក្នុងករណីខាងនេះ យើងសង្កេតឃើញថា មិនមានអ្នកគ្រប់គ្រងមតិកទាំងមូលទេ។ បើគ្មានអ្នកប្រតិបត្តិមតកសាសន៍គ្រប់គ្រងមតិកទាំងមូលនោះទេ សន្តតិជន អច្ច័យលាភី ឬម្ចាស់បំណុលរបស់មតកជន អាចដាក់ពាក្យសុំទៅតុលាការឲ្យធ្វើការជ្រើសតាំងអ្នកគ្រប់គ្រងមតិកទាំងមូលជាបណ្ដោះអាសន្ន ដើម្បីរក្សាការពារមតិក រហូតដល់ពេលធ្វើការបែងចែកមតិក[83]។

តើការដាក់ពាក្យសុំគ្រប់គ្រងជាបណ្ដោះអាសន្នដើម្បីរក្សាការពារមតិកនេះមានសារៈសំខាន់យ៉ាងដូចម្ដេចខ្លះ ចំពោះអ្នកដែលមានសិទ្ធិដាក់ពាក្យសុំ?

ក្នុងចំណោមសន្តតិជនទាំងអស់ អាចមានសិទ្ធិក្នុងការគ្រប់គ្រងមតិកដូចៗគ្នា មុនពេលធ្វើការបែងចែកមតិក នោះអាចនឹងមានការពិបាកក្នុងការព្រមព្រៀងគ្នាក្នុងការចាត់ចែងថានរណាជាអ្នកគ្រប់គ្រងមតិកទាំងអស់ ដូច្នេះ ដើម្បីចៀសវាងនូវផលលំបាកនេះ ក្នុងចំណោមសន្តតិជនទាំងអស់ សន្តតិជនណាម្នាក់ ឬ ច្រើននាក់ អាចដាក់ពាក្យសុំជ្រើសតាំងអ្នកគ្រប់គ្រងមតិកជាបណ្ដោះអាសន្នបាន ក្នុងគោលបំណងឲ្យជននោះធ្វើការគ្រប់គ្រងមតិកទាំងអស់។ ចំពោះអច្ច័យលាភីវិញ ប្រសិនបើបានជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍រួចហើយ ប្រហែលជាមិនចាំបាច់មានអ្នកគ្រប់គ្រងមតិកជាបណ្ដោះអាសន្នទេ ព្រោះអ្នកប្រតិបត្តិមតកសាសន៍មានសិទ្ធិក្នុងការបែងចែកចំណែករបស់អច្ច័យលាភីជាស្រេច។ ដោយឡែកចំពោះអ្នកមានសិទ្ធិលើបំណុលរបស់មតកជនវិញ ពិតជាមានភាពចាំបាច់ណាស់ក្នុងការជ្រើសតាំងអ្នកគ្រប់គ្រងមតិកជាបណ្ដោះអាសន្ន ដោយសារ

[81] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២១៥

[82] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២២២ និង មាត្រា ១២៦៣។

[83] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៦៤ កថាខណ្ឌទី ១។

តែម្ចាស់បំណុលរបស់មតកជន មានសិទ្ធិលើបំណុលដែលត្រូវយកទ្រព្យសម្បត្តិរបស់មតកជនមកសង ប៉ុន្តែដោយសារតែមតកជនបានទទួលមរណភាព នោះសិទ្ធិលើបំណុលនោះត្រូវបានបែងចែកទៅតាមចំណែកមតិករបស់សហសន្តតិជន ហើយក្នុងករណីដែលមានម្ចាស់បំណុលលើសន្តតិជនផ្ទាល់ ម្ចាស់បំណុលនៃមតកជនអាចអនុវត្តសិទ្ធិនេះ ចំពោះចំណែកកម្មសិទ្ធិអវិភាគរបស់សន្តតិជនដែលជាកូនបំណុលបាន ដោយមានលំដាប់ខ្ពស់ជាងម្ចាស់បំណុលនៃសន្តតិជនផ្ទាល់នោះ។

ដូច្នេះ ចាំបាច់ត្រូវរក្សាការពារមតិក មុនពេលដែលមតិកនោះ ត្រូវបានបែងចែកតាមចំណែករបស់សន្តតិជន[84]។

ចំណុចដែលគួរពិចារណា គឺ អ្នកប្រតិបត្តិមតកសាសន៍មានសិទ្ធិក្នុងការគ្រប់គ្រងមតិកជាក់លាក់ដែលបានកំណត់ក្នុងមតកសាសន៍។ ប្រសិនសន្តតិជន អច្ច័យលាភី ឬ ម្ចាស់បំណុលរបស់មតកជន ដាក់ពាក្យសុំឲ្យតុលាការធ្វើការចាត់ចែងអ្នកផ្សេងធ្វើជាអ្នកគ្រប់គ្រងមតិកទាំងមូលជាបណ្តោះអាសន្ន នោះអ្នកប្រតិបត្តិមតកសាសន៍នឹងបាត់បង់សិទ្ធិរបស់ខ្លួនក្នុងការគ្រប់គ្រងមតិក។ ដូច្នេះ ជាការប្រសើរ គួរធ្វើការស្នើសុំឲ្យអ្នកប្រតិបត្តិមតកសាសន៍ធ្វើជាអ្នកគ្រប់គ្រងមតិកជាបណ្តោះអាសន្ន ដើម្បីឲ្យអ្នកប្រតិបត្តិមតកសាសន៍បានបំពេញតួនាទីរបស់ខ្លួនបាន។

### ២.តួនាទីក្នុងការធ្វើសកម្មភាពផ្សេងៗ ដែលចាំបាច់

ក្រៅពីសិទ្ធិក្នុងការគ្រប់គ្រងមតិក អ្នកប្រតិបត្តិមតកសាសន៍មានសិទ្ធិក្នុងការធ្វើសកម្មភាពផ្សេងៗដែលចាំបាច់ ដូច្នេះ អ្នកប្រតិបត្តិមតកសាសន៍ត្រូវបំពេញតួនាទីជាអ្នកធ្វើសកម្មភាពផ្សេងៗ។ តាមរយៈសិទ្ធិក្នុងការធ្វើសកម្មភាពផ្សេងៗនេះ ឧទាហរណ៍ ក្នុងករណីដែលមតកជនមានជំពាក់បំណុលនានា ម្ចាស់បំណុលរបស់មតកជនក៏អាចទាមទារឲ្យអ្នកប្រតិបត្តិមតកសាសន៍សងបំណុលបានដែរ ដែលមតកជនបានសរសេរបញ្ជាក់នៅក្នុងលិខិតមតកសាសន៍អំពីទ្រព្យជាក់លាក់សម្រាប់សងបំណុល[85]។

ក្រោយពេលសន្តតិជនយល់ព្រមទទួលសន្តតិកម្ម អ្នកប្រតិបត្តិមតកសាសន៍ត្រូវធ្វើការជូនដំណឹងជាសាធារណៈនៅក្នុងអំឡុងពេល ៥ (ប្រាំ) ថ្ងៃបន្ទាប់ពីការយល់ព្រមទទួលសន្តតិកម្ម ដល់ម្ចាស់បំណុលរបស់មតកជន និង អច្ច័យលាភី អំពីការណ៍ដែលសន្តតិជនយល់ព្រមទទួលសន្តតិកម្ម

[84] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ គន្ថីទី ៨-ទី ៩* (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០១០), ទំព័រទី ១២៥ និង ១២៦។

[85] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ គន្ថីទី ៨-ទី ៩* (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០១០), ទំព័រទី ៨០។

នោះ។ ម្ចាស់បំណុលរបស់មតកជន និង អច្ច័យលាភីត្រូវធ្វើការទាមទារសងចំណែករបស់ខ្លួនក្នុងអំឡុងពេលដែលកំណត់ ២ (ពីរ) ខែ។ ក្នុងការជូនដំណឹងជាសាធារណៈ គប្បីសរសេរបញ្ជាក់ថា ប្រសិនបើម្ចាស់បំណុលមិនបានស្នើសុំក្នុងអំឡុងពេលកំណត់នោះទេ សិទ្ធិលើបំណុលនោះនឹងត្រូវដកចេញពីការជម្រះបញ្ជី[86]។

ក្រោយពេលដែលអំឡុងពេលដែលកំណត់ខាងលើបានកន្លងផុត នោះអ្នកប្រតិបត្តិមតកសាសន៍ត្រូវធ្វើការជម្រះបញ្ជីលើទ្រព្យសម្បត្តិរបស់មតកជនដែលខ្លួនបានរក្សាទុកទៅម្ចាស់បំណុលនីមួយៗ ដែលបានស្នើសុំនៅក្នុងអំឡុងពេលដែលបានកំណត់ខាងលើ ទៅតាមសមាមាត្រនៃចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលនីមួយៗ នូវទ្រព្យសម្បត្តិជាក់លាក់ដែលមតកជនបានបម្រុងទុកជាស្រេច[87] បន្ទាប់មកទៀត ត្រូវចែកចំណែកដល់អច្ច័យលាភី ។ ចំណែកទ្រព្យសម្បត្តិដែលនៅសល់នឹងបែងចែកតាមចំណែករបស់សន្តតិជន នៅដំណាក់កាលបែងចែកមតិកនៅក្នុង **ផ្នែកទី៣** ខាងក្រោម។

ក្នុងការជម្រះបញ្ជីនេះ ប្រសិនបើចាំបាច់ត្រូវលក់មតិកដើម្បីសង អ្នកប្រតិបត្តិមតកសាសន៍ត្រូវលក់មតិកនោះតាមវិធីលក់ដោយបង្ខំ ឬ លក់ក្នុងតម្លៃខ្ពស់ជាងការវាយតម្លៃរបស់អ្នកវាយតម្លៃដែលត្រូវបានជ្រើសតាំងដោយតុលាការ។ សន្តតិជន ម្ចាស់បំណុលរបស់មតកជន ឬ អច្ច័យលាភីអាចក្លាយជាអ្នកទិញនៅក្នុងការលក់ដោយបង្ខំ ឬ ការលក់ក្នុងតម្លៃខ្ពស់នេះបាន[88]។

### ៣.តួនាទីក្នុងការធ្វើបញ្ជីសារពើភ័ណ្ឌ

បន្ទាប់ពីធ្វើការជម្រះបញ្ជីរួច ចាំបាច់អ្នកប្រតិបត្តិមតកសាសន៍ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិដែលនៅសល់ ហើយប្រគល់បញ្ជីសារពើភ័ណ្ឌនោះទៅឲ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ។ ដើម្បីឲ្យមានភាពច្បាស់លាស់ សន្តតិជនក៏អាចមានវត្តមាន នៅក្នុងពេលដែលអ្នកប្រតិបត្តិមតកសាសន៍ធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិដែរ[89]។

តើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិនេះ មានសារៈសំខាន់យ៉ាងណានៅក្នុងការប្រតិបត្តិមតកសាសន៍? បញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិនេះ ពិតជាមានភាពចាំបាច់ណាស់ ដើម្បីកំណត់ឲ្យបានច្បាស់លាស់នូវទំហំនៃកម្មវត្ថុនៃសិទ្ធិគ្រប់គ្រង និង ចាត់ចែងមិតករបស់អ្នកប្រតិបត្តិមតក

[86] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៨១។
[87] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៨៣។
[88] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៨៦។
[89] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២១៩។

សាសន៍ ព្រមទាំងជាមូលដ្ឋានដើម្បីបញ្ជាក់ករណីកិច្ចរាយការណ៍ (**មាត្រា ៦៤១**) ករណីកិច្ចប្រគល់ (**មាត្រា ៦៤២**) និង ករណីកិច្ចសងសំណង (**មាត្រា ៦៤៣**) នៃអ្នកប្រតិបត្តិមតកសាសន៍[90]។

## កថាខណ្ឌទី ៤ ៖ សោហ៊ុយនៃការប្រតិបត្តិ និងកម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍

### ក.សោហ៊ុយនៃការប្រតិបត្តិមតកសាសន៍

ចំពោះសោហ៊ុយដែលទាក់ទងនឹងការប្រតិបត្តិមតកសាសន៍ ត្រូវជាបន្ទុកនៃមតិក មានន័យថា សោហ៊ុយនានាដែលត្រូវចំណាយក្នុងការប្រតិបត្តិមតកសាសន៍ អាចកាត់ចេញពីមតិករបស់មតកជនបាន។ សោហ៊ុយដែលត្រូវចំណាយក្នុងការប្រតិបត្តិមតកសាសន៍មានដូចជា សោហ៊ុយចាំបាច់សម្រាប់ នីតិវិធីពិនិត្យបញ្ជាក់លិខិតមតកសាសន៍ សោហ៊ុយក្នុងការធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ សោហ៊ុយគ្រប់គ្រងមតិក កម្រៃអ្នកប្រតិបត្តិមតកសាសន៍ជាដើម។ ប៉ុន្តែ សោហ៊ុយក្នុងការប្រតិបត្តិមតកសាសន៍ មិនអាចបន្ថយភាគបម្រុងរបស់សន្តតិជនបានឡើយ[91]។

ឧទាហរណ៍ ៖ មតិកសរុបមាន ១០០០ ដុល្លារ ហើយសន្តតិជន "**ក**" និង សន្តតិជន "**ខ**" ត្រូវទទួលចំណែកសន្តតិកម្មស្មើគ្នា នោះភាគបម្រុងរបស់ សន្តតិជន "**ក**" គឺចំនួន ៥០០ ដុល្លារ ហើយភាគបម្រុងរបស់សន្តតិជន "**ខ**" គឺចំនួន ៥០០ ដុល្លារ។ ចំណែកនៅក្នុងការអនុវត្តមតកសាសន៍បានចំណាយសោហ៊ុយចំនួន ៥០ ដុល្លារ។ ក្នុងករណីនេះ សោហ៊ុយ ៥០ ដុល្លារត្រូវយកពីគួរកាត់ចេញពីសន្តតិជន "**ក**" ចំនួន ២៥ ដុល្លារ និង កាត់ចេញពីសន្តតិជន "**ខ**" ចំនួន ២៥ ដុល្លារ ប៉ុន្តែការកាត់ចេញនេះមិនមែនជាការកាត់បន្ថយភាគបម្រុងនោះទេ។

### ខ.កម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍

ជាទូទៅការងារនៃការប្រតិបត្តិមតកសាសន៍ដូចគ្នានឹងការងារអាណត្តិដែរ នោះការងារក្នុងការប្រតិបត្តិមតកសាសន៍អាចមានពីរករណី គឺ ៖

- ការប្រតិបត្តិមតកសាសន៍ដោយយកកម្រៃ និង
- ការប្រតិបត្តិមតកសាសន៍ដោយមិនយកកម្រៃ។

ការងារក្នុងការប្រតិបត្តិមតកសាសន៍មានភាពស្មុគស្មាញច្រើន ដូចជា ករណីកិច្ចក្នុងការគ្រប់គ្រងមតិក ការធ្វើសកម្មភាពផ្សេងៗដែលចាំបាច់ដើម្បីប្រតិបត្តិមតកសាសន៍ ព្រមទាំងការ

[90] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ គន្ថីទី ៨-ទី ៩* (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០១០), ទំព័រទី ៧៩ និង ៨០។

[91] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ គន្ថីទី ៨-ទី ៩* (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០១០), ទំព័រទី ៨៧។

ចាត់ចែងកិច្ចការនានាដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងសុចរិត ដែលជាបន្ទុកការងារមួយធ្ងន់ធ្ងរ ដូច្នេះ ការងារប្រតិបត្តិមតកសាសន៍នេះ គប្បីគួរយកកម្រៃ។

អ្នកប្រតិបត្តិមតកសាសន៍ អាចទទួលកម្រៃដូចបានកំណត់នៅក្នុងលិខិតមតកសាសន៍។ ប៉ុន្តែ ប្រសិនបើមតកសាសន៍ពុំបានកំណត់ពីកម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍នោះទេ តុលាការត្រូវកំណត់ចំនួនទឹកប្រាក់នៃកម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍នោះ តាមពាក្យសុំរបស់អ្នកប្រតិបត្តិមតកសាសន៍ បើយល់ឃើញថា សមរម្យក្នុងការបង់កម្រៃ ដោយពិចារណាទៅលើស្ថានភាពនៃមតិក ទំនាក់ទំនងរវាងមតកជន និង អ្នកប្រតិបត្តិមតកសាសន៍ និង ស្ថានភាពផ្សេងៗទៀត។

តាមន័យនេះដែរ ដោយសារតែ អាចមានករណីដែលសន្តតិជនធ្វើជាអ្នកប្រតិបត្តិមតកសាសន៍ ឬ ការប្រតិបត្តិមតកសាសន៍នោះមានភាពងាយស្រួល ដូច្នេះ មិនចាំបាច់ផ្តល់កម្រៃចំពោះការងារប្រតិបត្តិនេះក៏បានដែរ។ ប៉ុន្តែ ក្នុងករណីដែលតតិយជនជាអ្នកប្រតិបត្តិមតកសាសន៍ ទោះបីជាតិចក្តី ឬ ច្រើនក្តី តុលាការគួរតែកំណត់កម្រៃជូនអ្នកប្រតិបត្តិមតកសាសន៍ឲ្យមានភាពសមរម្យ[92]។

## កថាខណ្ឌទី ៥ ៖ សិទ្ធិជ្រើសតាំងបន្ត ការលាឈប់ និងការបញ្ឈប់អ្នកប្រតិបត្តិ

### ក.សិទ្ធិជ្រើសតាំងបន្តអ្នកប្រតិបត្តិមតកសាសន៍

ជាគោលការណ៍ អ្នកប្រតិបត្តិមតកសាសន៍មិនអាចឲ្យតតិយជន អនុវត្តកិច្ចការរបស់ខ្លួនបានឡើយ។ មូលហេតុដោយសារតែ មតកជនបានជឿទុកចិត្តទៅលើចំណេះដឹង និង សមត្ថភាពរបស់អ្នកប្រតិបត្តិមតកសាសន៍រួចហើយ ទើបប្រគល់សិទ្ធិដែលមានលក្ខណៈផ្តាច់មុខនេះដល់អ្នកនោះធ្វើជាអ្នកប្រតិបត្តិមតកសាសន៍។ ប៉ុន្តែ ក្នុងករណីដែលមានមូលហេតុដែលពុំអាចជៀសវាងបានទេ ព្រមទាំងក្នុងករណីដែលម្ចាស់បណ្តាំបានបង្ហាញឆន្ទៈ អនុញ្ញាតឲ្យតតិយជនអនុវត្តកិច្ចការជំនួសអ្នកប្រតិបត្តិមតកសាសន៍ តាមរយៈលិខិតមតកសាសន៍ នោះអាចឲ្យតតិយជនអនុវត្តកិច្ចការនោះបាន។

ក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍បានឲ្យតតិយជនអនុវត្តភារកិច្ចរបស់ខ្លួន នោះអ្នកប្រតិបត្តិមតកសាសន៍នោះត្រូវទទួលខុសត្រូវក្នុងការជ្រើសតាំង និង ការត្រួតពិនិត្យជននោះ ចំពោះអច្ច័យលាភី និង សន្តតិជន។ ប្រសិនបើអ្នកប្រតិបត្តិមតកសាសន៍ បានឲ្យតតិយជនអនុវត្តភារកិច្ចនោះ ដោយមិនបានគោរពតាមល័ក្ខខ័ណ្ឌដែលមានចែងខាងលើទេ អ្នកប្រតិបត្តិមតកសាសន៍នោះ

[92] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ គន្ថីទី ៨-ទី ៩* (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០១០), ទំព័រទី ៨៥។

ត្រូវសងសំណងនៃការខូចខាតដែលកើតឡើងដោយសារហេតុនោះ ចំពោះអច្ច័យលាភី និង សន្តតិជន[93]។

**ខ.ការលាឈប់ពីមុខងារអ្នកប្រតិបត្តិមតកសាសន៍**

ដើម្បីលាឈប់ពីពីមុខងាររបស់ខ្លួន អ្នកប្រតិបត្តិមតកសាសន៍ត្រូវមានមូលហេតុត្រឹមត្រូវ ហើយចាំបាច់ត្រូវមានការអនុញ្ញាតពីតុលាការ។ មូលហេតុដោយសារតែ មុខងាររបស់អ្នកប្រតិបត្តិមតកសាសន៍គឺធ្វើឲ្យត្រូវសម្រេចនូវគោលបំណងចុងក្រោយរបស់មតកជន ប្រៀបបីដូចជាការងារអាណាព្យាបាលមួយប្រភេទដែរ ដែលមិនអាចបោះបង់ចោលអ្នកក្រោមអាណាព្យាបាលរបស់ខ្លួនបាន។ ដូច្នេះ អ្នកប្រតិបត្តិមតកសាសន៍ពុំអាចបោះបង់មុខងាររបស់ខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវនោះទេ។ មូលហេតុត្រឹមត្រូវ ដែលអាចទទួលយកបាននោះមានដូចជា៖ ជននោះមានជម្ងឺប្រចាំកាយ ជននោះត្រូវទៅបំពេញបេសកកម្មនៅឆ្ងាយក្នុងរយៈពេលវែង ការកាន់កាប់មុខងារថ្មីមានភាពមមាញឹកច្រើន ដែលជាហេតុមិនអាចបំពេញមុខងារជាអ្នកប្រតិបត្តិមតកសាសន៍បាន[94]។

**គ.ការបញ្ឈប់មុខងាររបស់អ្នកប្រតិបត្តិមតកសាសន៍**

ដោយឡែក ប្រសិនបើមានមូលហេតុត្រឹមត្រូវ សន្តតិជន អច្ច័យលាភី ឬ អ្នកដែលពាក់ព័ន្ធនឹងផលប្រយោជន៍ អាចដាក់ពាក្យសុំទៅតុលាការឲ្យធ្វើការបញ្ឈប់មុខងាររបស់អ្នកប្រតិបត្តិមតកសាសន៍បាន។ មូលហេតុត្រឹមត្រូវនៃការបញ្ឈប់មានដូចជា អ្នកប្រតិបត្តិមតកសាសន៍ខ្ជិលច្រអូសក្នុងការបំពេញមុខងារ ការបាត់ខ្លួនរបស់អ្នកប្រតិបត្តិមតកសាសន៍ដោយគ្មានមូលហេតុច្បាស់លាស់ អ្នកប្រតិបត្តិមតកសាសន៍មានជម្ងឺរយៈពេលវែងដែលជាឧបសគ្គក្នុងការប្រតិបត្តិមតកសាសន៍[95]។

ប្រសិនបើអ្នកប្រតិបត្តិមតកសាសន៍ ក្លាយជាជននៅក្រោមហិតូបត្ថម្ភ ឬ ធ្លាក់ខ្លួនស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ឬ អ្នកប្រតិបត្តិមតកសាសន៍បានក្ស័យធនក្នុងអំឡុងពេលកំពុងអនុវត្តមតកសាសន៍ អ្នកប្រតិបត្តិមតកសាសន៍នោះត្រូវបាត់បង់នូវឋានៈជាអ្នកប្រតិបត្តិមតកសាសន៍ដោយស្វ័យប្រវត្តិ ហេតុនេះហើយ សន្តតិជន ឬ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ អាចដាក់ពាក្យសុំទៅតុលាការឲ្យជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ថ្មីបាន ដោយពុំចាំបាច់ស្នើសុំបញ្ឈប់អ្នកប្រតិបត្តិមតកសាសន៍ចាស់ឡើយ។

---

[93] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ គន្លឹះទី ៨-ទី ៩* (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០១០), ទំព័រទី ៨៣។

[94] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២២៧ កថាខណ្ឌទី ១។

[95] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២២៧ កថាខណ្ឌទី ២។

ភារកិច្ចរបស់អ្នកប្រតិបត្តិមតកសាសន៍ ត្រូវបញ្ចប់នៅពេលដែលបានបញ្ចប់ការអនុវត្តមតកសាសន៍[96]។

## ផ្នែកទី ៣ ៖ នីតិវិធីនៃការបែងចែកមត៌ក

### កថាខណ្ឌទី ១ ៖ ពេលដែលធ្វើការបែងចែកមត៌ក

ជាទូទៅ ករណីមតកជនគ្មានបន្សល់ទុកនូវបំណុល ក្រោយពេលដែលមតកជនបានទទួលមរណភាព ១ (មួយ) ខែ សន្តតិជនអាចចាប់ផ្តើមពិភាក្សាបែងចែកមត៌កបាននៅពេលណាក៏បានដែរ[97]។ តាមភាពពិតជាក់ស្តែង ក្នុងអំឡុងពេល ១ (មួយ) ខែ បន្ទាប់ពីមតកជនបានទទួលមរណភាពនេះ គេត្រូវធ្វើការស្រាវជ្រាវរកសន្តតិជនរបស់មតកជនឲ្យអស់ ឧទាហរណ៍ តើតាំងពីដើមមកមតកជនធ្លាប់រៀបអាពាហ៍ពិពាហ៍មុន និង មានកូន ឬទេ? ហើយកូននោះត្រូវបានទទួលស្គាល់ឬទេ? បន្ទាប់ពីកំណត់សន្តតិជនរួចមក ក្នុងចំណោមសន្តតិជនទាំងអស់ តើសន្តតិជនណាខ្លះយល់ព្រមទទួលស្គាល់ ឬ បោះបង់សន្តតិកម្ម? រួចកំណត់នូវទំហំចំណែករបស់សន្តតិជននីមួយៗ ហើយបន្ទាប់មកទៀតធ្វើការបែងចែកមត៌កនោះ។ តាមការប៉ាន់ស្មានដំណាក់កាលទាំងអស់ខាងលើ អាចធ្វើបានក្នុងអំឡុងពេល ១ (មួយ) ខែ និង ហេតុផលមួយទៀត គឺចាំបាច់ត្រូវផ្តល់ការគោរពចំពោះវិញ្ញាណក្ខន្ធមតកជន ដូច្នេះ បានជាគេកំណត់អំឡុងពេល ១ (មួយ) ខែ បន្ទាប់ពីមរណភាពរបស់មតកជន ទើបអាចធ្វើការបែងចែកមត៌កបាន[98]។

ប៉ុន្តែ តាមការបកស្រាយនៅក្នុង ចំណុច **ខ** នៃ **កថាខណ្ឌទី ២** ស្តីពី ចំណុចដែលត្រូវសរសេរក្នុងមតកសាសន៍ក្នុង **ផ្នែកទី ៣** នៃ **ជំពូកទី ១** បង្ហាញឲ្យឃើញថា មតកជនអាចកំណត់ក្នុងមតកសាសន៍ថា ហាមឃាត់មិនឲ្យបែងចែកមត៌កក្នុងអំឡុងពេល មិនលើសពី ៥ (ប្រាំ) ឆ្នាំ គិតពីពេលដែលចាប់ផ្តើមសន្តតិកម្មបាន។ ករណីនេះសន្តតិជនពុំអាចធ្វើការបែងចែកមត៌កបានឡើយក្នុងអំឡុងពេលដែលហាមឃាត់នេះ ដូច្នេះ ពេលដែលធ្វើការបែងចែកត្រូវពន្យារហូតដល់ពេលដែលបានកំណត់ក្នុងមតកសាសន៍បានកន្លងផុត[99]។

---

[96] សមាជិកក្រុមការងារគ្រូបណ្តុះបណ្តាលនៃសាលាភូមិន្ទចៅក្រម ដោយមានការគាំទ្រពីទីសហប្រតិបត្តិការ JICA, *ក្រមរដ្ឋប្បវេណី ភាគ ៦* (លើកទី ១ ឆ្នាំ២០១២), ទំព័រទី ៥៩។

[97] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៦៦ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១។

[98] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ គន្លឹះទី ៨-ទី ៩* (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០១០), ទំព័រទី ១២៨។

[99] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៦៦ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២។

ក្នុងករណីមួយទៀត តាមការបកស្រាយនៅក្នុងនីតិវិធីគ្រប់គ្រងមតិកនៃ **ផ្នែកទី ២** ខាងលើ យើងសង្កេតឃើញថា មុននឹងឈានដល់ដំណាក់កាលនៃការបែងចែកមតិកនេះ ត្រូវឆ្លងកាត់នីតិវិធីមួយចំនួនដូចជា ៖ ការពិនិត្យបញ្ជាក់លិខិតមតកសាសន៍ដោយតុលាការ ផ្តល់ឱកាសឲ្យសន្តតិជនយល់ព្រម ឬ បោះបង់សន្តតិកម្ម ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ បន្ទាប់មកអ្នកប្រតិបត្តិមតកសាសន៍ត្រូវបំពេញតួនាទីដូចជា ការគ្រប់គ្រងមតិក ការជូនដំណឹងជាសាធារណៈដល់ម្ចាស់បំណុលរបស់មតកជន ការជម្រះបញ្ជីលើទ្រព្យសម្បត្តិរបស់មតកជនដោយសងបំណុលលើម្ចាស់បំណុលនីមួយៗ ការកាត់ចំណែកមតិកដល់អច្ច័យលាភី ធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ រួចរាយការណ៍ និង ប្រគល់បញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិនោះទៅសន្តតិជន។ យើងសង្កេតឃើញថា នៅក្នុងនីតិវិធីទាំងនេះបានប្រើអស់រយៈពេលជាច្រើន លើសពី ១ (មួយ) ខែ ទៅទៀត ដូច្នេះ ក្នុងករណីនេះ មតិកនឹងត្រូវបែងចែកបន្ទាប់ពីនីតិវិធីដែលបានរៀបរាប់ខាងលើបានកន្លងផុត។

**ជារួម** ពេលដែលអាចបែងចែកមតិករបស់មតកជនអាស្រ័យទៅលើករណីនីមួយៗ ដូចបានរៀបរាប់ខាងលើ។

### កថាខណ្ឌទី ២ ៖ វិធីនៃការបែងចែកមតិក

តាមការកំណត់របស់ក្រមរដ្ឋប្បវេណី វិធីនៃការបែងចែកមតិករបស់មតកជនមានពីរ គឺ ៖

- ការបែងចែកមតិកតាមសន្តតិវិធី និង
- ការបែងចែកមតិកដោយតុលាការ

#### ក.ការបែងចែកមតិកតាមសន្តតិវិធី

##### ១.មូលដ្ឋាននៃការបែងចែកមតិក

តាមរយៈការបង្ហាញនៅក្នុង **កថាខណ្ឌទី ២** នៃ **ផ្នែកទី ៣** ស្តីពីចំណុចដែលត្រូវសរសេរក្នុងមតកសាសន៍នៃ **ជំពូកទី ១** ជាគោលការណ៍ នៅពេលធ្វើលិខិតមតកសាសន៍ មតកជនត្រូវសរសេរអំពីការកំណត់ចំណែកមតិក ឬ វិធីបែងចែកមតិកទៅឲ្យជនដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ជាសន្តតិជនរបស់ខ្លួន។ ដូច្នេះ នៅពេលធ្វើការបែងចែកមតិក គេនឹងយកខ្លឹមសារនៃ **មតកសាសន៍** ធ្វើជាមូលដ្ឋានក្នុងការបែងចែកមតិករបស់មតកជនទៅឲ្យសន្តតិជន។

នៅក្នុងលិខិតមតកសាសន៍ពុំបានកំណត់នូវចំណែកមតិក ឬ វិធីបែងចែកមតិកនោះទេ តើគេត្រូវធ្វើការបែងចែកមតិកយ៉ាងដូចម្តេច?

នៅក្នុងករណីនេះ ការបែងចែកមតិកត្រូវធ្វើការពិចារណាទៅលើប្រភេទ និង លក្ខណៈនៃវត្ថុ ឬ សិទ្ធិដែលមាននៅក្នុងមតិក ឬ អាយុ មុខរបរ ស្ថានភាពផ្លូវកាយ និង ផ្លូវចិត្ត ស្ថានភាពជីវភាព

របស់សន្តតិជននីមួយៗ និង ស្ថានភាពផ្សេងៗទៀត[100]។ នៅពេលធ្វើការពិភាក្សាបែងចែកមតិកឲ្យសន្តតិជន ត្រូវពិចារណាដល់ចំណុចទាំងអស់នេះ ប៉ុន្តែ ក្នុងករណីដែលសន្តតិជនទាំងអស់បានព្រមព្រៀងគ្នានូវវិធីបែងចែកមតិកផ្សេងពីនេះ ការព្រមព្រៀងនោះក៏មានអានុភាពក្នុងការបែងចែកមតិកដែរ ប្រសិនបើខ្លឹមសារនៃការបែងចែកនោះមិនផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់របស់ខ្មែរយើងនោះទេ[101]។

**២.ការបែងចែកមត៌កក្នុងករណីដែលអវត្តមានសន្តតិជនខ្លះ**

ក្នុងករណីដែលមតកជនបានកំណត់ចំណែករបស់សន្តតិជន ឬ បានកំណត់វិធីបែងចែកមតិកដោយមតកសាសន៍រួចរាល់ ប៉ុន្តែជនដែលត្រូវបានសន្មតថាជាសន្តតិជនបានទទួលមរណភាពនៅមុនពេលចាប់ផ្តើមសន្តតិកម្ម ឬ ជនដែលត្រូវបានសន្មតថាជាសន្តតិជននោះបាត់បង់សិទ្ធិទទួលសន្តតិកម្មដោយក្លាយខ្លួនជាអភ័ព្វបុគ្គលនៃសន្តតិកម្ម ឬ ជនដែលត្រូវបានសន្មតថាជាសន្តតិជននោះត្រូវបានកាត់កាល់ នោះជននោះពុំអាចទទួលសន្តតិកម្មបានឡើយ។ ចំណែកការកំណត់នៅក្នុងមតកសាសន៍អំពីចំណែករបស់ជននោះ ត្រូវធ្វើចំពោះអ្នកទទួលសន្តតិកម្មជំនួសរបស់ជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ[102]។

តើនរណាជាអ្នកទទួលសន្តតិកម្មជំនួសរបស់ជនដែលត្រូវបានសន្មតថាជាសន្តតិជន?

ក្នុងករណីដែលបានកំណត់ខាងលើ ជាទូទៅ ជនដែលត្រូវសន្មតថាជាសន្តតិជនជំនួសរបស់ជនដែលត្រូវបានសន្មតថាជាសន្តតិជន គឺកូនរបស់ជននោះ ដែលជាបច្ឆាញាតិផ្ទាល់របស់ជនដែលត្រូវសន្មតថាជាសន្តតិជន។ ចំណែក បុគ្គលដែលមិនមែនជាបច្ឆាញាតិផ្ទាល់របស់ជនដែលត្រូវសន្មតថាជាសន្តតិជន មិនមានលក្ខណសម្បត្តិក្លាយជាសន្តតិជនជំនួសបានឡើយ[103]។

ទោះជាយ៉ាងណាក៏ដោយ ក្នុងករណីបើគ្មានអ្នកទទួលសន្តតិកម្មជំនួសជនដែលត្រូវបានសន្មតថាជាសន្តតិជននោះដូចបានកំណត់ខាងលើទេ ឬ ក្នុងករណីដែលជនដែលត្រូវសន្មតថាជាសន្តតិជននោះបានបោះបង់សន្តតិកម្ម នោះការកំណត់ចំពោះជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ ពុំត្រូវបានបង្កើតអានុភាពឡើយ។ ប៉ុន្តែ ទោះបីជាមានសន្តតិជនជំនួស ឬ គ្មានសន្តតិជន

[100] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៦៧ កថាខណ្ឌទី ១។

[101] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ គន្លីទី ៨-ទី ៩* (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០១០), ទំព័រទី ១៣០។

[102] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៩៦ កថាខណ្ឌទី ១

[103] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៥៧ ថ្មី។

ជំនួសរបស់ជនដែលត្រូវសន្មតថាជាសន្តតិជនក៏ដោយ ក៏មតកជនអាចសម្តែងឆន្ទៈផ្សេងពីការចែងខាងលើផងដែរ ដោយសារតែគេគោរពឆន្ទៈរបស់មតកជនជាចម្បង[104]។

**៣.ការបែងចែកមត៌កក្នុងករណីអច្ច័យទានមោឃៈ**

ក្នុងករណីដែលអច្ច័យទានពុំបានបង្កើតអានុភាព ដោយសារតែអច្ច័យលាភីទទួលមរណភាព ដោយសារអច្ច័យលាភីក្លាយជាអភ័ព្វបុគ្គល ដោយសារអច្ច័យលាភីបោះបង់អច្ច័យទាន ឬដោយសារហេតុផ្សេងទៀត ជាគោលការណ៍ នោះទ្រព្យសម្បត្តិដែលអច្ច័យលាភីនឹងត្រូវទទួលបាននឹងធ្លាក់ទៅលើសន្តតិជនរបស់មតកជនវិញ[105]។

ឧទាហរណ៍ ៖ នៅក្នុងលិខិតមតកសាសន៍ មតកជនបានបង្ហាញឆន្ទៈក្នុងការធ្វើអច្ច័យទាន ១ ភាគ ៤ នៃទ្រព្យសម្បត្តិទៅឲ្យ "**ក**" និង ធ្វើអច្ច័យទាន ១ ភាគ ៤ នៃទ្រព្យសម្បត្តិទៀតទៅឲ្យ "**ខ**" ដែល "**ក**" និង "**ខ**" ជាបងប្អូនបង្កើតនឹងគ្នា ហើយ "**ក**" បានទទួលមរណភាពមុនពេលដែលលិខិតមតកសាសន៍បង្កើតអានុភាពក្នុងការអនុវត្ត។ ក្នុងករណីនេះ មិនមែនមានន័យថា "**ខ**" ដែលជាបងប្អូនបង្កើតរបស់ "**ក**" អាចធ្វើលទ្ធកម្មលើចំណែករបស់ "**ក**" នោះទេ ប៉ុន្តែផ្ទុយមកវិញ "**ខ**" មិនអាចធ្វើលទ្ធកម្មលើចំណែកដែល "**ក**" នឹងទទួលបានឡើយ។ មានន័យថា "ខ" អាចទទួលអច្ច័យទានបានតែ ១ ភាគ ៤ ប៉ុណ្ណោះ ចំណែក ១ ភាគ ៤ ទៀតដែល "**ក**" នឹងអាចទទួលបាននោះ ជាទូទៅត្រូវធ្លាក់ទៅសន្តតិជនតាមផ្លូវច្បាប់វិញ។

ប៉ុន្តែប្រសិនបើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងដែលបានសរសេរក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈរបស់មតកជន[106]។ ឧទាហរណ៍ ៖ ក្នុងករណីខាងលើ ប្រសិនបើនៅក្នុងលិខិតមតកសាសន៍ មតកជនបានបង្ហាញឆន្ទៈពិសេសថា ក្នុងករណីដែល "**ក**" ឬ "**ខ**" ទទួលមរណភាពមុនពេលដែលលិខិតមតកសាសន៍បង្កើតអានុភាពក្នុងការអនុវត្ត "**ក**" ឬ "**ខ**" អាចទទួលបានចំណែក ១ ភាគ ៤ ទៀតលើចំណែករបស់ខ្លួនដែលទទួលបានពីអ្នកទទួលមរណភាព នោះ ១ ភាគ ៤ ដែល "**ក**" នឹងត្រូវទទួលបាននឹងធ្លាក់ទៅលើ "**ខ**" ដែលជាបងប្អូនបង្កើតរបស់ "**ក**" មានន័យថា "**ខ**" អាចទទួលអច្ច័យទាន ១ ភាគ ២ នៃទ្រព្យសម្បត្តិទាំងអស់របស់មតកជន។

ផ្ទុយទៅវិញ ប្រសិនបើមត៌ករបស់មតកជន មិនអាចបែងចែកតាមសន្តតិវិធីដូចរៀបរាប់ខាងលើនោះទេ តើគេត្រូវធ្វើការបែងចែកមត៌កនោះយ៉ាងដូចម្តេច (**ខ**) ?

[104] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៩៦ កថាខណ្ឌទី ២ និង កថាខណ្ឌទី ៣។
[105] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៩៨ កថាខណ្ឌទី ១។
[106] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៩៨ កថាខណ្ឌទី ២។

### ខ.ការបែងចែកមត៌កដោយតុលាការ

ក្នុងករណីដែលការពិភាក្សារវាងសន្តតិជនអំពីការបែងចែកមតិកពុំបានសម្រេច ឬ ក្នុងករណីដែលសន្តិជនពុំអាចពិភាក្សាគ្នាបានទេ សន្តិជនម្នាក់ ឬ ច្រើននាក់អាចដាក់ពាក្យសុំទៅតុលាការឲ្យធ្វើការបែងចែកមតិកនោះបាន។ ជាទូទៅ តុលាការមិនអាចធ្វើការបែងចែកមតិកដោយឆន្ទានុសិទ្ធិរបស់ខ្លួនបានឡើយ ប្រសិនបើគ្មានការដាក់ពាក្យសុំពីសន្តិជន។

ក្នុងការពិចារណាបែងចែកមតិកក្នុងករណីនេះ តុលាការត្រូវធ្វើការពិចារណាដោយឈរលើ **"ទំនៀមទម្លាប់នៅក្នុងតំបន់"** និង **"មតិលើសពីពាក់កណ្តាលរបស់សន្តតិជន"**។ ចំពោះមតិលើសពីពាក់កណ្តាលរបស់សន្តតិជន ភាគច្រើនគឺមតិដែលសន្តតិជនបានពិភាក្សាគ្នាក្នុងការបែងចែក ប៉ុន្តែពុំអាចធ្វើទៅបាន មូលហេតុដោយសារតែក្នុងចំណោមសន្តតិជនទាំងអស់ មានសន្តតិជនណាម្នាក់ ឬ ភាគតិចមិនសុខចិត្តសម្របទៅតាមមតិភាគច្រើន ទើបតម្រូវឲ្យតុលាការជាអ្នកសម្របសម្រួលក្នុងករណីនេះ ហើយយកតាមមតិភាគច្រើន ដោយមិនធ្វើឲ្យបាត់បង់ផលប្រយោជន៍មតិភាគតិច។ ប៉ុន្តែ ទោះបីជាមានមតិភាគច្រើនក៏ដោយក្តី ប្រសិនបើតុលាការយល់ឃើញថា មតិភាគច្រើននោះមិនសមរម្យ តុលាការក៏គួរតែស្តាប់តាមមតិភាគតិចផងដែរ[107]។

ចំពោះទ្រព្យសម្បត្តិដែលមិនអាចទទួលការព្រមព្រៀងអំពីការបែងចែក ឬ មិនអាចទទួលការព្រមព្រៀងថាបុគ្គលណាត្រូវទទួលទ្រព្យសម្បត្តិនោះ តុលាការអាចលក់ ហើយធ្វើការបែងចែកប្រាក់ដែលបានពីការលក់នោះទៅសន្តតិជនបាន[108]។ ឧទាហរណ៍ ៖ បន្ទាប់ពីដាក់ពាក្យសុំទៅតុលាការឲ្យធ្វើការបែងចែកមតិក មានដីមួយឡូត៍ដែលសន្តតិជនបានខ្វែងគំនិតគ្នាក្នុងបែងចែក។ ជាដំណោះស្រាយ តុលាការអាចលក់ដីឡូត៍នេះបានតាមនីតិវិធីលក់ឡៃឡុង។ ប៉ុន្តែប្រសិនបើសាលក្រមអំពីការបែងចែកមិនបានចូលជាស្ថាពរទេ ការលក់ក៏មិនអាចធ្វើបានដែរ ដូច្នេះ សេចក្តីសម្រេចបញ្ចប់នៃសាលក្រមអំពីការបែងចែកមតិកក្នុងករណីនេះ គឺ ត្រូវលក់អចលនវត្ថុដែលមាននៅក្នុងបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិដែលភ្ជាប់ជាមួយនេះ ហើយកាត់នូវសោហ៊ុយចាំបាច់ពីថ្លៃលក់នោះ ហើយចំណែកនៅសល់ប៉ុន្មាននោះ ត្រូវបែងចែកឲ្យសន្តតិជនស្មើៗគ្នា[109]។

---

[107] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ គន្លឹះទី ៨-ទី ៩* (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០១០), ទំព័រទី ១៣៣។

[108] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៧១។

[109] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ គន្លឹះទី ៨-ទី ៩* (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០១០), ទំព័រទី ១៣៤។

**កថាខណ្ឌទី ៣ ៖ ជនដែលទទួលស្គាល់ក្រោយការបែងចែកមត៌ក និង ការទាមទារ**

ប្រសិនបើមានកូន ឬ បច្ឆាញាតិផ្ទាល់ណាមិនទាន់ត្រូវបានទទួលស្គាល់ដោយមតកជន កូន ឬ បច្ឆាញាតិផ្ទាល់របស់មតកជននោះ អាចដាក់ពាក្យបណ្តឹងទាមទារឲ្យទទួលស្គាល់នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីមរណភាពរបស់មតកជន បើខ្លួនទើបតែដឹងពីទំនាក់ទំនងញាតិជាមួយមតកជន ក្រោយពេលដែលមតកជនទទួលមរណភាព[110]។

ក្នុងករណីដែលការទទួលស្គាល់ក្រោយមរណភាពរបស់មតកជន ប៉ុន្តែការទទួលស្គាល់នោះត្រូវបានធ្វើឡើងក្រោយការបែងចែកមតិក ប្រសិនបើការពិភាក្សាដើម្បីបែងចែកមតិកត្រូវបានធ្វើឡើងដោយមានវត្តមានរបស់សន្តតិជនទាំងអស់ដោយខ្វះតែវត្តមានរបស់ជននោះមួយ នោះការពិភាក្សាបែងចែកមតិកនោះមានសុពលភាព ដោយសារតែនៅពេលបែងចែកពុំទាន់ទទួលស្គាល់ជននោះនៅឡើយទេ នោះជននោះពុំទាន់ក្លាយជាសន្តតិជននៅឡើយ។

ផ្ទុយទៅវិញ ក្នុងករណីដែលមតកជនបានទទួលស្គាល់ជននោះជាកូននៅពេលរស់ ប៉ុន្តែដោយសារតែសន្តតិជនផ្សេងទៀតមិនបានដឹង ហើយដកជនដែលមតកជនបានទទួលស្គាល់នោះចេញពីការពិភាក្សាបែងចែកមតិក ឬ ក្នុងករណីដែលការទទួលស្គាល់ក្រោយមរណភាពរបស់មតកជន ប៉ុន្តែការទទួលស្គាល់នោះត្រូវបានធ្វើឡើងមុនការបែងចែកមតិក ហើយសន្តតិជនផ្សេងទៀតមិនបានយកចិត្តទុកដាក់មិនឲ្យជននោះចូលរួមក្នុងការពិភាក្សាបែងចែកមតិក ពេលនេះយើងសង្កេតឃើញថាការបែងចែកមិនបានធ្វើឡើងក្រោមវត្តមានរបស់សន្តតិជនទាំងអស់នោះទេ នោះការបែងចែកដែលធ្វើឡើងនេះ ត្រូវមោឃៈ។ ក្នុងករណីនេះ ជនដែលត្រូវបានទទួលស្គាល់ក្រោយអាចទាមទារឲ្យសន្តតិជនផ្សេងទៀតធ្វើការបែងចែកមតិកជាថ្មីឡើងវិញ[111]។

ការទាមទារឲ្យធ្វើការបែងចែកមតិកជាថ្មីនេះ ហៅថាការទាមទារឲ្យធ្វើបដិទានសន្តតិកម្ម។ ការទាមទារឲ្យធ្វើបដិទានសន្តតិកម្មនេះ ការទាមទារត្រូវធ្វើឡើងក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលបែងចែកមតិកបានកន្លងផុត[112]។

ចំណុចដែលគួរពិចារណានោះគឺ ប្រសិនក្នុងអំឡុងពេល ៥ ឆ្នាំ ក្រោយការបែងចែកមតិក ជនដែលទើបត្រូវបានទទួលស្គាល់ក្រោយមរណភាពរបស់មតកជន នៅតែអាចទាមទារឲ្យធ្វើការ

[110] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១០០១ កថាខណ្ឌទី ៥។

[111] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ គន្ថីទី ៨-ទី ៩* (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០១០), ទំព័រទី ១៣៧ និង ១៣៨។

[112] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១៣០៤។

បែងចែកចំណែកមត៌កសារជាថ្មី នោះនឹងមានគុណវិបត្តិមួយត្រង់ថា ក្នុងអំឡុងពេល ៥ ឆ្នាំនេះមត៌ក ដែលបានបែងចែករួច អាចនឹងត្រូវបានធ្វើការវិវឌ្ឍន៍ ឬ ក៏អាចត្រូវបានបាត់រូបរាង។ ដូច្នេះ ជាការប្រសើរ គប្បីត្រូវស្នើសុំឲ្យទទួលស្គាល់ក្រោយមរណភាពរបស់មតកជនឲ្យបានឆាប់រហ័ស និងស្នើសុំឲ្យធ្វើបដិទានសន្តតិកម្មឲ្យបានឆាប់រហ័យក្រោយដែលខ្លួនត្រូវបានទទួលស្គាល់។

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាលើប្រធានបទស្តីពី "**សន្តតិកម្មតាមមតកសាសន៍នៅកម្ពុជាបច្ចុប្បន្ន**" ទាំងមូលរួចមក យើងខ្ញុំសូមធ្វើសេចក្តីសន្និដ្ឋានដូចតទៅ ៖

នៅមុនពេលដែលម្ចាស់បណ្តាំទទួលមរណភាព ម្ចាស់បណ្តាំអាចធ្វើមតកសាសន៍បាននៅពេលណាក៏បានដែរ ប៉ុន្តែនៅពេលធ្វើមតកសាសន៍ តម្រូវឲ្យម្ចាស់បណ្តាំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការវិនិច្ឆ័យ ត្រិះរិះពិចារណាឲ្យបានច្បាស់លាស់ ដើម្បីសរបញ្ជាក់ឲ្យបានច្បាស់លាស់ថា មតកសាសន៍បានស្តែងចេញពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំ។ ម្ចាស់បណ្តាំ មិនត្រឹមតែអាចធ្វើសន្តតិកម្មនូវទ្រព្យសម្បត្តិទៅឲ្យសន្តតិជនតាមលិខិតមតកសាសន៍នេះប៉ុណ្ណោះទេ ប៉ុន្តែម្ចាស់បណ្តាំក៏អាចធ្វើអច្ច័យទានតាមរយៈលិខិតមតកសាសន៍នេះផងដែរ។

មតកសាសន៍ ត្រូវបានបង្កើតឡើងដោយម្ចាស់បណ្តាំដោយឯកតោភាគី ដោយមិនចាំបាច់មានការយល់ព្រមពីសន្តតិជនឡើយ ចំណែកទម្រង់ និង ចំណុចដែលត្រូវសរសេរក្នុងមតកសាសន៍ត្រូវធ្វើឡើងតាមការកំណត់នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។ តាមរយៈក្រមរដ្ឋប្បវេណី ទម្រង់នៃមតកសាសន៍មានបីសំខាន់ៗ គឺ មតកសាសន៍ដោយលិខិតយថាភូត មតកសាសន៍ដោយលិខិតឯកជន និង មតកសាសន៍ដោយលិខិតសម្ងាត់។ ម្ចាស់បណ្តាំ អាចជ្រើសរើសយកទម្រង់មួយណាក៏បានដែរមកធ្វើជាលិខិតមតកសាសន៍ ដោយសារនេះជាស្វ័យសម្រេចរបស់ម្ចាស់បណ្តាំ។ លើសពីនេះទៅទៀត ក្នុងលិខិតមតកសាសន៍ មតកជនត្រូវសរសេរបញ្ជាក់ឲ្យបានច្បាស់លាស់នូវចំណុចមួយចំនួនដូចជា ការកំណត់ចំណែក ឬ ការកំណត់នូវវិធីបែងចែកមត៌ក ការកំណត់អ្នកប្រតិបត្តិមតកសាសន៍ មិនតែប៉ុណ្ណោះ ប្រសិនបើមតកជនចង់ផ្តាច់មត៌កពីសន្តតិជនណាមួយ ត្រូវសរសេរបញ្ជាក់ឲ្យបានច្បាស់លាស់នៅក្នុងលិខិតមតកសាសន៍នោះ។ បន្ថែមពីលើនេះដែរ មតកជនក៏អាចសរសេរនៅក្នុងលិខិតមតកសាសន៍នូវផ្តល់ជាដំបូន្មាន ឬ យោបល់ដល់សន្តតិជន ដើម្បីឲ្យមានភាពសុខដុមរមនានៅក្នុងក្រុមគ្រួសារបានដែរ។ នៅមុនពេលដែលម្ចាស់បណ្តាំទទួលមរណភាព ម្ចាស់បណ្តាំក៏អាចធ្វើការលុបចោលនូវមតកសាសន៍មួយភាគ ឬ ទាំងមូលក៏បានដែរ តាមរយៈការលុបចោលដោយទម្រង់មតកសាសន៍ដោយសរសេរក្នុងមតកសាសន៍ថ្មីឲ្យបានច្បាស់ថា លុបចោលនូវមតកសាសន៍ចាស់ ឬ សរសេរមតកសាសន៍ថ្មីឲ្យមានខ្លឹមសារផ្ទុយនឹងមតកសាសន៍ចាស់។ មិនតែប៉ុណ្ណោះ ការធ្វើសកម្មភាពចាត់ចែងទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃមតកសាសន៍ ក៏ត្រូវចាត់ទុកថាម្ចាស់បណ្តាំបានលុបចោលមតកសាសន៍ដែរ។ មិនតែប៉ុណ្ណោះ ការបំផ្លាញចោលដោយចេតនារបស់ម្ចាស់បណ្តាំ ក៏ចាត់ទុកជាការលុបចោលលិខិតមតកសាសន៍ផងដែរ។ មតកសាសន៍ដែលបង្កើតចុង

ក្រោយគេ ជាមតកសាសន៍ដែលនឹងមានអានុភាពក្នុងការអនុវត្ត ក្រោយពេលដែលម្ចាស់បណ្តាំទទួលមរណភាព។

ក្រោយពេលដែលមតកសាសន៍បង្កើតអានុភាពក្នុងការអនុវត្ត ចាំបាច់ដំបូងបង្អស់ អ្នកដែលថែរក្សាមតកសាសន៍ ឬ សន្តតិជនដែលបានរកឃើញលិខិតមតកសាសន៍ត្រូវដាក់ពាក្យសុំការបញ្ជាក់ពីតុលាការនូវលិខិតមតកសាសន៍នោះ ដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់ថា នេះជាលិខិតមតកសាសន៍ ជៀសវាងមានការលួចបន្លំពីតតិយជន។ បន្ទាប់ពីតុលាការបានធ្វើការបញ្ជាក់លិខិតមតកសាសន៍រួច លិខិតមតកសាសន៍នោះចាំបាច់ត្រូវធ្វើការបើកនៅក្នុងនីតិវិធីតុលាការ ផ្ទុយទៅវិញប្រសិនបើមតកសាសន៍ត្រូវបានបើនៅក្រៅនីតិវិធីតុលាការ អ្នកដែលបើកមតកសាសន៍នោះនឹងត្រូវពិន័យជាទឹកប្រាក់ចំនួនមួយលានរៀល។ ក្រោយពេលដែលលិខិតមតកសាសន៍ត្រូវបានបើក ជនដែលកំណត់ថាជាសន្តតិជន ត្រូវធ្វើការយល់ព្រម ឬ បោះបង់នូវសន្តតិកម្មនោះ ក្នុងអំឡុងពេល ៣ ខែ ប៉ុន្តែជាការប្រសើរ គប្បីធ្វើការស្រាវជ្រាវនូវទ្រព្យសម្បត្តិរបស់មតកជនសិន រួចធ្វើការយល់ព្រម ឬ បោះបង់ក្នុងកាន់តែលឿនកាន់តែប្រសើរ ដើម្បីឲ្យដំណើរការអនុវត្តមតកសាសន៍បានឆាប់រហ័ស។ ប៉ុន្តែក្នុងអំឡុងពេលនោះ គប្បីធ្វើការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ឡើង ដើម្បីឲ្យគេបានអនុវត្តតួនាទីជាអ្នកប្រតិបត្តិនូវមតកសាសន៍។ ក្រោយពេលដែលសន្តតិជនយល់ព្រមទទួលសន្តតិកម្មហើយ អ្នកប្រតិបត្តិមតកសាសន៍ត្រូវធ្វើការជូនដំណឹងជាសាធារណៈដល់ម្ចាស់បំណុលរបស់មតកជន ប្រសិនបើមាន និង ធ្វើការជូនដំណឹងទៅអច្ច័យលាភីដើម្បីឲ្យគេបានដឹងថា បានចាប់ផ្តើមអច្ច័យទានហើយ។ ក្រោយពីធ្វើការចាត់ចែងសងបំណុល និង អច្ច័យទានរួចរាល់ ទ្រព្យសម្បត្តិដែលនៅសល់នឹងចែកឲ្យសន្តតិជន។ អ្នកប្រតិបត្តិមតកសាសន៍ត្រូវបញ្ចប់ភារកិច្ចរបស់ខ្លួនក្រោយពេលដែលបានធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ និងប្រគល់ជូនសន្តតិជនដោយគ្មានយឺតយ៉ាវ។

សន្តតិជនត្រូវធ្វើការបែងចែកមតិកតាមការចែងនៅក្នុងលិខិតមតកសាសន៍ ប៉ុន្តែបើមិនមានចែងនោះទេ សន្តតិជនត្រូវធ្វើការបែងចែកដោយពិភាក្សាគ្នាដោយពិចារណាទៅលើ ប្រភេទ និង លក្ខណៈនៃវត្ថុ អាយុ មុខរបរ ស្ថានភាពជីវភាព ស្ថានភាពផ្លូវកាយ និង ចិត្តរបស់សន្តតិជន។ ប៉ុន្តែប្រសិនបើសន្តតិជនពុំអាចពិភាក្សាគ្នាបាននោះទេ សន្តតិជនអាចធ្វើការដាក់សុំឲ្យតុលាការធ្វើការបែងចែកជំនួស ដោយតុលាការឈរលើគោលការណ៍ទំនៀមទម្លាប់ក្នុងតំបន់ និង មតិលើសពាក់កណ្តាលរបស់សន្តតិជនមកធ្វើជាមូលដ្ឋាននៃការបែងចែកមតិក។ ប្រសិនបើតុលាការយល់ឃើញ

ថា មតិភាគតិចមានសមរម្យជាង តុលាការក៏អាចយកតាមមតិភាគតិចដែរ។ ក្រោយពេលដែលមតិកត្រូវបានបែងចែកនោះ ការធ្វើសន្តតិកម្មតាមលិខិតមតកសាសន៍នឹងត្រូវបញ្ចប់។

តាមរយៈការស្រាវជ្រាវនេះ យើងសង្កេតឃើញថា ការធ្វើសន្តតិកម្មតាមមតកសាសន៍ពិតជាមានប្រយោជន៍ណាស់ ព្រោះវាមិនត្រឹមតែអាចកាត់បន្ថយជម្លោះក្នុងការបែងចែកមតិករវាងសន្តតិជននោះទេ ប៉ុន្តែវាថែមទាំងជាវិធីទូទាត់បំណុលមួយដ៏ល្អផងដែរ។ ការធ្វើសន្តតិកម្មតាមមតកសាសន៍ត្រូវគោរពតាមក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ទាំងទម្រង់ និងចំណុចដែលត្រូវសរសេរ ប៉ុន្តែតាមរយៈការស្រាវជ្រាវ យើងសង្កេតឃើញថា មានមាត្រាមិនទាន់មានភាពគ្រប់គ្រាន់ ដែលចែងមកមានភាពស្រពេចស្រពិល ដូច្នេះ យើងសង្ឃឹមថា ចំណុចទាំងនោះនឹងត្រូវបានពិចារណាកែសម្រួលនាពេលអនាគតជាក់ជាមិនខាន។ យើងខ្ញុំសង្ឃឹមថា ការធ្វើសន្តតិកម្មតាមរយៈលិខិតមតកសាសន៍នេះ នឹងមានការចាប់អារម្មណ៍ពីសំណាក់មនុស្សជាតិទូទៅ ហើយប្រសិនបើដូច្នេះ នេះជាជោគជ័យធំបំផុតនៃការស្រាវជ្រាវរបស់យើងខ្ញុំ។

# ឯកសារយោង


❖ **ច្បាប់**

- ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។
- ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១។

❖ **សៀវភៅ**

- សមាជិកក្រុមការងារគ្រូបណ្តុះបណ្តាលនៃសាលាភូមិន្ទចៅក្រម ដោយមានការគាំទ្រពីទីភ្នាក់ងារសហប្រតិបត្តិការJ ICA , ***ក្រមរដ្ឋប្បវេណី ភាគ ៦***, (ភ្នំពេញ៖ លើកទី ១, ២០១២)។
- សាស្ត្រាចារ្យ ណូម៉ូរ៉ា តូយ៉ូហ៊ីរ៉ូ, ***សេចក្តីផ្តើមនីតិរដ្ឋប្បវេណី***,( ភ្នំពេញ៖ លើកទី ៥, ២០១១)។
- ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, ***សេចក្តីកំណត់ចំពោះ មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ : គន្ថីទី ៨-ទី៩***, (ភ្នំពេញ៖ ក្រសួងយុត្តិធម៌ ២០១០)។
- East-West Management Institute, Inc (EWMI) និង គម្រោងអនុវត្តច្បាប់ភូមិបាល របស់ធនាគារអភិវឌ្ឍន៍អាស៊ី, ***សៀវភៅសិក្សា និង ស្រាវជ្រាវច្បាប់ភូមិបាលកម្ពុជា***, ភ្នំពេញ ២០០៣។

# សេចក្ដីផ្ដើម

# ជំពូកទី១
# មតកសាសន៍ និង លក្ខខណ្ឌ
# សុពលភាពនៃមតកសាសន៍

# ជំពូកទី២
# នីតិវិធីក្នុងការប្រតិបត្តិ
# មតកសាសន៍

# សេចក្ដីសន្និដ្ឋាន

# ឯកសារយោង

# ឧបសម្ព័ន្ធ